USAID FROM THE AMERICAN PEOPLE

LMPPI Lower Mekong Public Policy Initiative

CDRI Cambodia Development Resource Institute

# ការសិក្សាពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃការផ្លាស់ប្តូរគោលនយោបាយស្រូវនៅវៀតណាមទៅលើគោលនយោបាយស្រូវនៅកម្ពុជា និងកសិករដាំស្រូវអន្តរក្លូង បណ្តាខេត្តនៅភាគអាគ្នេយ៍




អៀ សុធី   ស៊ឹម សុខចេង   ឈឹម ឈុន   និង   ខៀវ ភិរម្យ



ឯកសារពិភាក្សាលេខ ១១៣

ខែមករា ឆ្នាំ២០១៨

ឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI

ឯកសារពិភាក្សាលេខ ១១៣

# ការសិក្សាពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃការផ្លាស់ប្ដូរគោលនយោបាយស្រូវនៅវៀតណាមទៅលើគោលនយោបាយស្រូវនៅកម្ពុជា និងកសិករដាំស្រូវអន្តរក្នុងបណ្ដាខេត្តនៅភាគអាគ្នេយ៍

អៀ សុធី   ស៊ឹម សុខចេង   ឈឹម ឈុន និង ខៀង តិរម្យ

វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ភ្នំពេញ ខែមករា ឆ្នាំ២០១៨

© ២០១៨ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ-CDRI)
រក្សាសិទ្ធិគ្រប់យ៉ាង

ISBN-13: 97899963-891-1-5

**ការសិក្សាពីគោលនយោបាយស្រូវ៖ ផលពាក់ព័ន្ធនៃការផ្លាស់ប្តូរគោលនយោបាយស្រូវនៅវៀតណាមទៅលើគោលនយោបាយស្រូវនៅកម្ពុជា និងកសិករដាំស្រូវអង្ករក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍**

**សូមយោងឯកសារនេះថា៖**

Ear Sothy, Sim Sokcheng, Chhim Chhun and Khiev Pirom 2017. *Rice Policy Study: Implications of Rice Policy Changes in Vietnam for Cambodia's Rice Policy and Rice Producers in South-Eastern Cambodia.* CDRI Working Paper Series No. 114. Phnom Penh: CDRI.

**វិទ្យាស្ថាន** CDRI
អគារលេខ ៥៦ ផ្លូវលេខ ៣១៥ ខ័ណ្ឌទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
ទូរស័ព្ទ៖ +៨៥៥២៣ ៨៨១៣៨៤, ៨៨១៧០១, ៨៨១៩១៦, ៨៨៣៦០៣
ទូរសារ៖ +៨៥៥២៣ ៨៨០៧៣៤
អ៊ីមែល៖ cdri@cdri.org.kh http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ុំ ចាន់ថា
បកប្រែដោយ៖ យូ សិទ្ធីរិទ្ធ
បោះពុម្ពនៅប្រទេសកម្ពុជាដោយ Donbosco printing រាជធានីភ្នំពេញ

# មាតិកា


សេចក្តីថ្លែងអំណរគុណ ........ vii

សេចក្តីសង្ខេប ........ viii

១. សេចក្តីផ្តើម ........ 1

១.១ ប្រវត្តិនៃការសិក្សា ........ 1

១.២ គោលដៅ ........ 2

២. វិធីសាស្ត្រ ........ 3

៣. ការប្រមូលទិន្នន័យ និងការជ្រើសយកសំណាក ........ 4

៤. ការសិក្សាឯកសារមានស្រាប់ ........ 6

៤.១ ទិដ្ឋភាពទូទៅនៃវិស័យស្រូវអង្ករនៅកម្ពុជា ........ 6

៤.២ ស្រូវអង្ករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ........ 11

៤.៣ ទិដ្ឋភាពទូទៅនៃវិស័យស្រូវអង្ករនៅវៀតណាម ........ 11

៥. លទ្ធផលរកឃើញសំខាន់ៗតាមវិធីសាស្ត្របែបគុណវិស័យ ........ 14

៥.១ គោលនយោបាយកសិកម្ម និងស្រូវ នៅវៀតណាម ........ 14

៥.២ សម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះក្នុងវិស័យឯកជនវៀតណាម ........ 15

៥.៣ ស្ថានភាពវិស័យស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ........ 17

៥.៤ គោលនយោបាយស្រូវនៅកម្ពុជា ........ 19

៦. លទ្ធផលរកឃើញសំខាន់ៗតាមវិធីសាស្ត្របែបបរិមាណវិស័យ ........ 22

៦.១ លក្ខណៈនៃសំណាក ........ 22

៦.២ ព័ត៌មានផ្នែកប្រជាសាស្ត្រ ........ 23

៦.៣ ប្រភពនៃប្រាក់ចំណូលគ្រួសារ ........ 26

៦.៤ ផលិតកម្មបន្លែ និងធាតុចូល ........ 27

៦.៥ បន្ទុកចំណាយ និងអត្ថប្រយោជន៍ក្នុងចំណោមដំណាំស្រូវ ........ 29

*៦.៥.១ ទំហំដី ........ 29*

*៦.៥.២ ពូជស្រូវ ........ 29*

*៦.៥.៣ ទិន្នផលស្រូវ ........ 30*

៦.៦ ធាតុចូលនៃដំណាំស្រូវ ........ 30

*៦.៦.១ ការលក់ស្រូវ ........ 32*

*៦.៦.២ ចំណាយនិងផលចំណេញនៃការដាំស្រូវ IR504 និងពូជស្រូវផ្សេងទៀត ........ 32*

៧. ការពិភាក្សា៖ ការវិភាគអ្នកពាក់ព័ន្ធ ........ 35

៨. សេចក្តីសន្និដ្ឋាន ........ 36

៩. ការផ្តល់យោបល់ផ្នែកគោលនយោបាយ ........ 38

ឯកសារយោង ........ 39

ឧបសម្ព័ន្ធ ........ 40

ឧបសម្ព័ន្ធ១៖ ការប្រមូលទិន្នន័យ និងការជ្រើសយកសំណាក ........ 40

ឧបសម្ព័ន្ធ២៖ គោលនយោបាយកសិកម្ម និងគោលនយោបាយស្រូវវៀតណាម ........ 44

ឧបសម្ព័ន្ធ៣៖ គោលនយោបាយស្រូវថ្មីនៅកម្ពុជា ........ 48

បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI ........ 51

# បញ្ជីតារាង


តារាង ១៖ សមតុល្យស្រូវអង្ករឆ្នាំ២០១៥ (តោន)....1
តារាង ២៖ ក្របខ័ណ្ឌវិភាគ និងឧបករណ៍ស្រាវជ្រាវ....3
តារាង ៣៖ អង្ករនាំចេញបែងចែកតាមប្រទេស (%)....16
តារាង ៤៖ ព័ត៌មានលំអិតលើសំណាក (%)....23
តារាង ៥៖ ព័ត៌មានទូទៅលើគ្រួសារ (%)....23
តារាង ៦៖ កម្រិតអប់រំរបស់មេគ្រួសារ (%)....24
តារាង ៧៖ មុខរបរបន្ទាប់បន្សំ (%)....25
តារាង ៨៖ ការប្រើប្រាស់ស្បៀងអាហារ និងការប្រើប្រាស់មិនមែនស្បៀងអាហារ ក្នុងមួយគ្រួសារ (ដុល្លារ/ថ្ងៃ)....25
តារាង ៩៖ ប្រាក់ចំណូលគ្រួសារ (ដុល្លារ/ឆ្នាំ)....27
តារាង ១០៖ មុខបន្លែមានដាំដោយគ្រួសារសំណាក (%)....28
តារាង ១១៖ ថ្លៃលក់បានសរុប និង ចំណាយលើធាតុចូលសរុប សម្រាប់បន្លែ (ដុល្លារ/ឆ្នាំ)....28
តារាង ១២៖ ធាតុចូលសម្រាប់បន្លែ (ដុល្លារ)....28
តារាង ១៣៖ ទំហំដីគិតតាមរយៈពេលដាំដុះស្រូវ....29
តារាង ១៤៖ វិធីសាបព្រោះ (%)....30
តារាង ១៥៖ ទិន្នផលស្រូវ (តោន/ហិកតា)....30
តារាង ១៦៖ ធាតុចូលសម្រាប់ផលិតកម្មស្រូវ....31
តារាង ១៧៖ គ្រួសារមានប្រើកម្លាំងពលកម្ម និងម៉ាស៊ីន (%)....31
តារាង ១៨៖ ប្រភពទឹក (%)....31
តារាង ១៩៖ ថ្លៃឯកតាស្រូវ និងអង្ករ (រៀល/គីឡូក្រាម)....32
តារាង ២០៖ ការប្រៀបធៀបស្រូវ IR504 ជាមួយនឹងពូជស្រូវផ្សេងទៀត (វដ្តផលិតកម្មមួយ)....33


## តារាងឧបសម្ព័ន្ធ


តារាង A1៖ ការជ្រើសយកសំណាកសម្រាប់សម្ភាសន៍គ្រួសារ....41
តារាង A2៖ បញ្ជីអ្នកឆ្លើយសម្ភាសន៍សម្រាប់ផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃស្រូវ....42
តារាង A3៖ សម្ភាសន៍ KIIs និង FDGs នៅក្នុងតំបន់សិក្សា....43
តារាង A4៖ សម្ភាសន៍ជាមួយវិស័យសាធារណៈនៅវៀតណាម....43
តារាង A5៖ ប្រភពនៃសេវាផ្សព្វផ្សាយ មតិណែនាំ និងជំនួយគាំទ្រ ទទួលបានដោយកសិករ (%)....50

# បញ្ជីរូបភាព


រូបភាព ១៖ ផែនទីនៃតំបន់សិក្សា ..... 4
រូបភាព ២៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ឆ្នាំ១៩៩៦-២០១២ ..... 6
រូបភាព ៣៖ ការងារបែងចែកតាមវិស័យ ឆ្នាំ១៩៩៨-២០១២ ..... 7
រូបភាព ៤៖ ផលិតកម្មស្រូវកម្ពុជា ឆ្នាំ១៩៨០-២០១៥ (លានតោន) ..... 7
រូបភាព ៥៖ ផលិតកម្មស្រូវ ឆ្នាំ២០១៥ (%) ..... 8
រូបភាព ៦៖ ការនាំចេញអង្ករនៅកម្ពុជា ឆ្នាំ២០០០-២០១៥ (HS1006) ..... 8
រូបភាព ៧៖ ការនាំចេញអង្កររបស់កម្ពុជាបែងចែកតាមតំបន់ ឆ្នាំ២០១៥ (បរិមាណ) ..... 9
រូបភាព ៨៖ ការនាំចេញអង្កររបស់កម្ពុជាបែងចែកតាមប្រទេស ឆ្នាំ២០១៥ (បរិមាណ) ..... 10
រូបភាព ៩៖ ការនាំចូលអង្កររបស់កម្ពុជា ឆ្នាំ២០១៥ (បរិមាណ) ..... 10
រូបភាព ១០៖ ផ្ទៃដីដាំស្រូវនៅវៀតណាម ..... 12
រូបភាព ១១៖ ការនាំចេញអង្កររបស់វៀតណាម ឆ្នាំ២០០០-២០១៥ (HS1006) ..... 12
រូបភាព ១២៖ ការនាំចេញអង្កររបស់វៀតណាម គិតតាមប្រទេស ឆ្នាំ២០១០-២០១៥ (HS1006) ..... 13
រូបភាព ១៣៖ ការនាំចូលអង្កររបស់វៀតណាម គិតតាមប្រទេស ២០១៥ ..... 13
រូបភាព ១៤៖ លំហូរស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ..... 19
រូបភាព ១៥៖ គ្រួសារទទួលបានសេវាផ្សព្វផ្សាយយ៉ាងហោចណាស់ម្តង (%) ..... 21
រូបភាព ១៦៖ អ្នកផ្តល់សេវាផ្សព្វផ្សាយ (%) ..... 21
រូបភាព ១៧៖ កម្មសិទ្ធិដីគិតតាមភូមិ (%) ..... 24
រូបភាព ១៨៖ មុខរបរចម្បង (%) ..... 24
រូបភាព ១៩៖ ចំណាយប្រើប្រាស់ក្នុងគ្រួសារ (%) ..... 25
រូបភាព ២០៖ ប្រភពប្រាក់ចំណូលគ្រួសារ (%) ..... 26
រូបភាព ២១៖ ប្រាក់ចំណូលបែងចែកតាមប្រភេទគ្រួសារ (%) ..... 26
រូបភាព ២២៖ គ្រួសារមានដាំបន្លែ (%) ..... 27
រូបភាព ២៣៖ គ្រួសារបានលក់បន្លែដាំខ្លួនឯង ក្នុង ១២ខែ មុនពេលធ្វើអង្កេត (%) ..... 28
រូបភាព ២៤៖ ពូជស្រូវបែងចែកតាមរយៈពេល (%) ..... 29
រូបភាព ២៥៖ ចំនួនថ្ងៃរហូតដល់ទុំ ..... 30
រូបភាព ២៦៖ ការលក់ស្រូវ ..... 32

# បញ្ជីអក្សរកាត់

| | |
|---|---|
| CDRI | វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា<br>(Cambodia Development Resource Institute) |
| CPS | មជ្ឈមណ្ឌលសិក្សាគោលនយោបាយ<br>(Centre for Policy Studies) |
| LMPPI | កម្មវិធីផ្ដួចផ្ដើមគោលនយោបាយសាធារណៈមេគង្គក្រោម<br>(Lower Mekong Public Policy Initiative) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ<br>(Ministry of Agriculture, Forestry and Fisheries) |
| MARD | ក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទ<br>(Ministry of Agriculture and Rural Development) |
| S&T | វិទ្យាសាស្ត្រនិងបច្ចេកវិទ្យា<br>(Science and Technology) |
| USAID | ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ<br>(United States Agency for International Development) |

# សេចក្តីថ្លែងអំណរគុណ

ការស្រាវជ្រាវនេះមិនអាចអនុវត្តទៅបានទេ បើសិនគ្មានជំនួយគាំទ្រហិរញ្ញវត្ថុពី កម្មវិធីផ្តួចផ្តើមគោលនយោបាយសាធារណៈមេគង្គក្រោម (LMPPI) និងទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)។ក្រុមអ្នកនិពន្ធសូមថ្លែងអំណរគុណដល់ LMPPI សម្រាប់ជំនួយគាំទ្រផ្នែករដ្ឋបាល និងឡូជីស្ទិក។ សូមអរគុណផងដែរដល់បណ្ឌិត Dang Kim Sun បណ្ឌិត Tran Cong Thang លោកស្រី Pham Thi Kim Dung បណ្ឌិត Nguyen Van Giap ព្រមទាំង ទីប្រឹក្សា និងអ្នកមានយោបល់ជាច្រើននាក់ទៀតដែលបានចែករំលែកព័ត៌មាន និងផ្តល់មតិលើការសិក្សានេះ។ មួយចំណែកទៀត សូមអរគុណដល់ ដៃគូស្រាវជ្រាវនានា ក្រុមអ្នកស្រាវជ្រាវនៃមជ្ឈមណ្ឌលសិក្សាគោលនយោបាយ (CPS) បណ្ឌិត Nguyen Van Kien និងក្រុមអ្នកស្រាវជ្រាវនៃសាកលវិទ្យាល័យ An Giang សម្រាប់កិច្ចសហការដ៏ល្អប្រសើរ។ សូមអរគុណជាអនេកដល់ អ្នកឆ្លើយសម្ភាសន៍នានាទាំងនៅកម្ពុជា និងវៀតណាម ចំពោះសហប្រតិបត្តិការ និងការផ្តល់ព័ត៌មានដ៏មានតម្លៃរបស់គាត់ និងដល់ មន្ត្រីរដ្ឋាភិបាលថ្នាក់មជ្ឈឹមនិងថ្នាក់ខេត្ត កសិករ ឈ្មួញ និងអ្នកនាំចេញនានា ដែលបានចំណាយពេលយ៉ាងសប្បុរសជួយចែករំលែកគំនិត និងចំណេះដឹងជាច្រើន។ ក្រុមអ្នកនិពន្ធក៏សូមអរគុណដល់ថ្នាក់ដឹកនាំ និងបុគ្គលិករដ្ឋបាលនៃវិទ្យាស្ថាន CDRI ដែលបានផ្តល់ជំនួយគាំទ្រផ្នែកឡូជីស្ទិកដ៏សំខាន់ដល់ការសិក្សាស្រាវជ្រាវនេះ។

# សេចក្ដីសង្ខេប

កន្លងមកមានការសិក្សាជាច្រើនហើយស្ដីពី ផលិតកម្មស្រូវនៅកម្ពុជា ប៉ុន្តែមិនទាន់មានមួយណាបានផ្តោតចំទៅលើទីតាំងភូមិសាស្ត្រនៃផលិតកម្មស្រូវ ជាពិសេស ក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍ រួមមាន ព្រៃវែង តាកែវ និងស្វាយរៀង។ កសិករនៅតំបន់នេះផលិតជាសំខាន់នូវ ស្រូវមានតម្លៃទាប (IR504) ដែលភាគច្រើនគេនាំចេញជាស្រូវសើមទៅវៀតណាម។ នាពេលថ្មីៗនេះ រដ្ឋាភិបាលវៀតណាមបានសម្រេចរៀបចំគោលនយោបាយសេដ្ឋកិច្ចនិងកសិកម្មឡើងវិញ ដោយងាកចេញពីស្រូវមានតម្លៃទាប ទៅផ្តោតលើស្រូវមានតម្លៃខ្ពស់ និងដំណាំផ្សេងទៀត។ គេជឿថាការប្រែប្រួលក្នុងគោលនយោបាយនេះ នឹងមានផលប៉ះពាល់ធ្ងន់ធ្ងរទៅលើផលិតកម្មស្រូវនៅកម្ពុជា ជាពិសេសជីវភាពរស់នៅរបស់កសិករក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍។ ឯកសារនេះព្យាយាមពិនិត្យពីផលពាក់ព័ន្ធនៃការផ្លាស់ប្តូរក្នុងគោលនយោបាយស្រូវនៅវៀតណាម ទៅលើផលិតកម្មស្រូវ និងប្រាក់ចំណូលគ្រួសារនៅជនបទ នៅភាគខាងកើត និងភាគខាងត្បូងប្រទេសកម្ពុជា នៅជិតព្រំប្រទល់ប្រទេសវៀតណាម។ បទសម្ភាសន៍ ការពិភាក្សាតាមក្រុមស្នូល និងអង្កេតគ្រួសារ បង្ហាញថា វៀតណាមត្រូវចំណាយពេលយ៉ាងហោចណាស់ ៣ ឆ្នាំ ដើម្បីដាក់អនុវត្តឲ្យបានពេញលេញនូវគោលនយោបាយរៀបចំឡើងវិញនេះ។ ដូច្នេះក្នុងរយៈពេលខ្លី ឈ្មួញ និងអ្នកនាំចេញវៀតណាមនឹងបន្តទិញស្រូវពីកម្ពុជា បើសិននៅតែមានទីផ្សារសម្រាប់អង្ករមានតម្លៃទាប។ គួរកត់សំគាល់ថា ប្រមាណ ២០% នៃគ្រួសារក្នុងអង្កេត រកចំណូលបានជាងពាក់កណ្តាលពីដំណាំស្រូវ ហើយនឹងត្រូវប៉ះពាល់ធ្ងន់ធ្ងរបើសិនឈ្មួញវៀតណាមឈប់ទិញស្រូវគាត់។ គ្រួសារភាគច្រើនបានឆ្លើយសម្ភាសន៍ប្រាប់ថា ការដាំស្រូវជាមុខរបរចម្បងរបស់ខ្លួន។ ទោះយ៉ាងនេះក្តី ការងារក្រៅកសិដ្ឋានជាប្រភពចំណូលចម្បងរបស់ពួកគាត់ ដោយតំណាងឲ្យប្រមាណ ៣៥% នៃចំណូលសរុប។ សម្ភាសន៍ជាមួយឈ្មួញក្នុងមូលដ្ឋានបង្ហាញថា ដោយសារសមត្ថភាពកែច្នៃនៅមានកម្រិត រោងម៉ាស៊ីនកិនស្រូវក្នុងស្រុកពុំមានសមត្ថភាពស្រូបយកផលស្រូវនៅសល់បានទេ បើសិនតម្រូវការពីវៀតណាមមានវិបត្តិ។

# ១. សេចក្តីផ្តើម

## ១.១ ប្រវត្តិនៃការសិក្សា

ថៃ វៀតណាម និង កម្ពុជា តែងមានឈ្មោះល្បីនៅក្នុងផលិតកម្ម និងការនាំចេញអង្ករ។ នៅឆ្នាំ២០១៥ ថៃជាប្រទេសនាំចេញអង្ករច្រើនជាងគេលំដាប់ទី២ ដោយបាននាំចេញប្រមាណ ៩,៨ លានតោន (តម្លៃ ៤,៥ ប៊ីលានដុល្លារ) ហើយបន្ទាប់មកគឺ វៀតណាម ដែលបាននាំចេញប្រមាណ ៦,៦ លានតោន (២,៨ ប៊ីលានដុល្លារ)។ ថៃនាំចេញអង្ករមានគុណភាពខ្ពស់(អង្ករក្រអូប)ជាសំខាន់ រីឯវៀតណាមផលិតនិងនាំចេញភាគច្រើននូវ អង្ករមិនក្រអូប (ឬអង្ករគុណភាពទាប) ។

ស្រូវអង្ករជាស្បៀងអាហារមូលដ្ឋាននៅកម្ពុជា ហើយជាដំណាំសំខាន់ និងជាប្រភពចំណូលចម្បងសម្រាប់ ៨៥% នៃគ្រួសារនៅជនបទ។ វារួមចំណែកប្រមាណ ៤,៥% នៃ ផសស និង ២០% នៃចំណូលគ្រួសារសរុប។ ចំណូលគ្រួសារបានពីដំណាំផ្សេងៗ តំណាងឲ្យ ២០,១% នៃចំណូលគ្រួសារសរុប ហើយចំណូលបានពីស្រូវអង្ករ មានចំណែកជាង ៥០% ក្នុងចំណូលពីដំណាំ។ ចំណែកនៃចំណូលបានពីដំណាំ កើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ ដោយសារកំណើនទិន្នផលសម្រេចបានតាមការប្រើធាតុចូលកាន់តែល្អ និងកំណើនថ្លៃផលដំណាំ។ ការកាត់បន្ថយភាពក្រីក្រយ៉ាងលឿននៅតំបន់ជនបទ ពី ៥៩% ក្នុងឆ្នាំ២០០៤ មកត្រឹម ២៤% ក្នុងឆ្នាំ២០១១ គឺទទួលបានដោយផ្ទាល់អំពី កំណើនថ្លៃអង្ករ (២៤%) និងកំណើនផលិតកម្មស្រូវ (២៣%) ។ ប៉ុន្តែជោគជ័យនេះអាចប្រែប្រួលបញ្ច្រាសមកវិញ បើសិនមានការប៉ះទង្គិចតែបន្តិចទៅលើប្រាក់ចំណូលមាន ដោយការប៉ាន់ស្មាន ការបាត់បង់ជាមធ្យមត្រឹម ០,៣០ដុល្លារ ក្នុងចំណូលប្រចាំថ្ងៃ អាចរុញច្រានប្រជាជនកម្ពុជារហូតដល់ ៣ លាននាក់ ឲ្យធ្លាក់ចូលក្នុងភាពក្រីក្រ ហើយអត្រាភាពក្រីក្របច្ចុប្បន្នត្រូវកើនឡើងរហូតដល់ ៤០%។

តារាង១៖ សមតុល្យស្រូវអង្ករឆ្នាំ២០១៥ (តោន)

| រាយមុខ | តោន |
|---|---|
| ផលិតកម្ម (ស្រូវ) | 9324170 |
| ពូជ | 684500 |
| ផលអាចប្រើការបាន (ស្រូវ) | 8639670 |
| ផលអាចប្រើការបាន (គិតជាអង្ករ) | 4751819 |
| ការប្រើប្រាស់សរុប (អង្ករ) | 2703447 |
| ការប្រើប្រាស់នៅជនបទ (អង្ករ) | 2241229 |
| ទីផ្សារទីប្រជុំជនក្នុងមូលដ្ឋាន (អង្ករ) | 186846 |
| ពាណិជ្ជកម្មអន្តរខេត្ត (អង្ករ) | 275372 |
| អង្ករនាំចេញ | 538000 |
| អង្ករប្រើប្រាស់សរុប | 3241447 |
| ការនាំចេញក្រៅផ្លូវការ (គិតជាអង្ករ) | 1510371 |
| ការនាំចេញសរុប (គិតជាអង្ករ) | 2048371 |
| ការនាំចេញក្រៅផ្លូវការ (គិតជាស្រូវ) | 2746130 |

ប្រភព៖ Frédéric Lançon (CIRAD) 2016

ទោះបីមានការជឿនលឿនទៅមុខនិងគោលនយោបាយណែនាំច្រើនយ៉ាងណាក្តីក៏ស្រូវអង្ករនៅតែជាបញ្ហាចម្រូងចម្រាសខ្លាំងនៅកម្ពុជា ជាពិសេសទាក់ទងនឹងទីផ្សារ។ កម្ពុជាផលិតស្រូវបានប្រមាណ ៩,៣ លានតោននៅឆ្នាំ២០១៤ បើគិតទាំងស្រូវក្រអូប និងមិនក្រអូប (MAFF 2015)។ នៅឆ្នាំ២០១៥ កម្ពុជាបាននាំចេញអង្ករជាផ្លូវការប្រមាណ កន្លះលានតោន ទៅសហភាពអឺរ៉ុប និងបណ្តាប្រទេសអាស៊ាន (MAFF 2015b; UN Comtrade 2017)។ ស្រូវនៅសល់

បានលក់ចេញក្រៅផ្លូវការទៅប្រទេសជិតខាង មាន ថៃ និង វៀតណាម។ កសិករនៅតាមព្រំដែនក្នុងបណ្ដាខេត្តនៅភាគអាគ្នេយ៍ តែងមានទម្លាប់លក់ស្រូវប្រាំងភាគច្រើនរបស់គាត់ទៅវៀតណាម តាមរយៈឈ្មួញវៀតណាម ឬឈ្មួញកម្ពុជា។ ដូច្នេះហើយ ទីផ្សារក្នុងមូលដ្ឋានបានវិវត្តតាមបែបបទមួយដែលតម្រូវការ និងថ្លៃស្រូវប្រាំង គឺឈ្មួញវៀតណាមជាអ្នកកំណត់ ហើយអស្ថិរភាពថ្លៃ និងភាពមិនច្បាស់លាស់នៃទីផ្សារដែលផុសចេញមក បានបង្អាក់ចិត្តកសិករក្នុងការធ្វើវិនិយោគទៅលើផលិតកម្មស្រូវអង្ករមានគុណភាពខ្ពស់។

ផ្អែកលើទិន្នន័យបានពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF 2015b) ការសិក្សាថ្មីមួយដើម្បីជួយគាំទ្រដល់ គម្រោងស្ដីពីការធ្វើពាណិជ្ជកម្មស្រូវអង្ករកម្ពុជា បានគណនា ការប្រើប្រាស់អង្ករក្នុងមនុស្សម្នាក់ និងតារាងតុល្យការនៃការផ្គត់ផ្គង់និងតម្រូវការអង្ករ (តារាង១) ។ គេប៉ាន់ស្មានថា ទីផ្សារក្នុងស្រុកត្រូវការអង្ករ ២,៧ លានតោន។ ដោយសារ តួលេខអង្ករនាំចេញផ្លូវការក្នុងឆ្នាំ២០១៥ មានត្រឹម ០,៥៤លានតោន ដូច្នេះ អង្ករនៅសល់ប៉ាន់ស្មាន ២,០៥ លានតោន ត្រូវជា ២,៧ លានតោនស្រូវ ទំនងបាននាំចេញទៅ ថៃ និង វៀតណាម។ ដោយសារស្រូវភាគច្រើននាំចេញទៅវៀតណាម ដូច្នេះវៀតណាមបាននាំចូលមិនតិចជាង ២ លានតោនស្រូវនោះទេ។

ថ្មីៗនេះរដ្ឋាភិបាលវៀតណាមបានផ្លាស់ប្ដូរគោលនយោបាយកសិកម្ម ជាពិសេស គោលនយោបាយស្រូវ ដោយងាកចេញពី ស្រូវមានទិន្នផលខ្ពស់តែគុណភាពទាប (ស្រូវមិនក្រអូប) ទៅផ្ដោតលើ ស្រូវមានទិន្នផលទាបតែគុណភាពខ្ពស់ (ស្រូវក្រអូប)។ លក្ខណៈនាំចេញអង្កររបស់វៀតណាម បានផ្លាស់ប្ដូរច្រើនក្នុងប៉ុន្មានឆ្នាំថ្មីៗ។ ជាក់ស្ដែង ការនាំចេញអង្ករផ្កាម្លិះ(អង្ករក្រអូប) បានកើន ៦៦% ពីឆ្នាំ២០១២ (ជិត ៦០០.០០០តោន) ដល់ឆ្នាំ២០១៣ (ជាង ៩០០.០០០តោន) ក្នុងនេះ អង្ករក្រអូបមានរហូតដល់ ១៤% នៃអង្ករនាំចេញសរុប។ ម៉្យាងទៀត ទីផ្សារអង្កររបស់វៀតណាម បានផ្លាស់ប្ដូរពីអាហ្វ្រិកមកអាស៊ី ជាពិសេសប្រទេសចិន។ អង្ករក្រអូបកំពុងដើរតួនាទីកាន់សំខាន់ក្នុងការនាំចេញរបស់វៀតណាម ហើយនិន្នាការនេះទំនងបន្តទៅមុខទៀត ព្រោះ ក្រសួងកសិកម្មនិងអភិវឌ្ឍន៍ជនបទ (MARD) វៀតណាមបានបញ្ជាក់ថា វៀតណាមគួរផ្ដោតខ្លាំងថែមទៀតលើការផលិតអង្ករមានតម្លៃខ្ពស់សម្រាប់នាំចេញ។ តាមនេះគេរំពឹងថា វៀតណាមនឹងផលិត និងនាំចេញអង្ករគុណភាពទាបកាន់តែតិចឡើង ហើយ ឈ្មួញ និង/ឬ អ្នកនាំចេញនឹងត្រូវការអង្ករមានតម្លៃខ្ពស់កាន់តែច្រើនឡើង ហើយទិញអង្ករមានគុណភាពទាបកាន់តែតិចឡើង ទាំងពីផលិតករវៀតណាម និងកម្ពុជា។

ការផ្លាស់ប្ដូរគោលនយោបាយកសិកម្មនៅប្រទេសជាតិខាង ជាពិសេសវៀតណាម អាចមានផលវិបាកធ្ងន់ធ្ងរសម្រាប់កសិករដាំស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ជាពិសេសកសិករដាំស្រូវប្រាំង។ ការធ្លាក់ចុះយ៉ាងខ្លាំងនូវតម្រូវការអង្ករពីវៀតណាម ដោយសារការផ្លាស់ប្ដូរគោលនយោបាយនាំចេញអង្កររបស់វៀតណាម នឹងមានឥទ្ធិពលអវិជ្ជមានខ្លាំងទៅលើចំណូលរបស់កសិករដាំស្រូវនៅកម្ពុជា លើកលែងតែពួកគាត់ងាកទៅដាំស្រូវខុសពីមុន ឬក៏ផ្លាស់ប្ដូរទៅធ្វើសកម្មភាពកសិកម្ម ឬសេដ្ឋកិច្ចផ្សេងទៀត ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្ដូរតម្រូវការទីផ្សារ។

## ១.២ គោលដៅ

ការសិក្សានេះមានគោលដៅចម្បងៗដើម្បី៖

- ពិនិត្យពីផលពាក់ព័ន្ធនៃការផ្លាស់ប្ដូរគោលនយោបាយស្រូវនៅវៀតណាម សម្រាប់ផលិតកម្មស្រូវអង្ករ និងប្រាក់ចំណូលគ្រួសារនៅជនបទ នៅភាគខាងកើតនិងខាងត្បូងប្រទេសកម្ពុជា នៅជិតព្រំដែនប្រទេសវៀតណាម។
- វាយតម្លៃពីឥទ្ធិពលនៃការផ្លាស់ប្ដូរក្នុងរបៀបរបបធ្វើផលិតកម្មស្រូវអង្ករ ដើម្បីឆ្លើយតបនឹងការផ្លាស់ប្ដូរក្នុងតម្រូវការទីផ្សារ។
- បង្ហាញជម្រើសផ្អែកគោលនយោបាយដល់រដ្ឋាភិបាល ដើម្បីជួយឲ្យផលិតករស្រូវអង្ករអាចជៀសផុតពីវិបត្តិប្រាក់ចំណូល។

# ២. វិធីសាស្ត្រ

ការសិក្សានេះប្រើប្រាស់ទាំងវិធីសាស្ត្របែបគុណវិស័យ និងបែបបរិមាណវិស័យ ដោយមានប្រើកម្រងសំណួរទាំងបែបគុណវិស័យ និងបែបបរិមាណវិស័យ ដើម្បីធ្វើសម្ភាសន៍តួអង្គនានានៅក្នុងខ្សែសង្វាក់តម្លៃអង្ករ។ ឧបករណ៍ស្រាវជ្រាវបីប្រភេទត្រូវបានបង្កើតឡើង និងប្រើប្រាស់ ដើម្បីទទួលបានព័ត៌មានផ្សេងៗ (តារាង២)។

តារាង២៖ ក្របខ័ណ្ឌវិភាគ និងឧបករណ៍ស្រាវជ្រាវ

| | ឧបករណ៍ស្រាវជ្រាវ | អ្នកពាក់ព័ន្ធ | លទ្ធផលរំពឹងទុក |
|---|---|---|---|
| វិធីសាស្ត្របែបបរិមាណវិស័យ | កម្រងសំណួរបែបបរិមាណវិស័យ | កសិករដាំស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា | ទិន្នន័យពីផលិតផលកសិកម្ម និងលក្ខណៈគ្រួសារ ដូចជាចំណាយផលិតកម្ម ប្រាក់ចំណូល និងរបៀបធ្វើកសិកម្ម ការវិភាគចំណាយនិងផលចំណេញលើពូជស្រូវផ្សេងៗ |
| វិធីសាស្ត្របែបគុណវិស័យ | សម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានគន្លឹះ (KII) | **កម្ពុជា:**<br>អ្នកកសាងគោលនយោបាយ<br>ឈ្មួញស្រូវអង្ករ<br>រោងម៉ាស៊ីនកិនស្រូវ<br>អ្នកនាំចេញស្រូវអង្ករ<br>**វៀតណាម:**<br>អ្នកកសាងគោលនយោបាយ<br>ឈ្មួញស្រូវអង្ករ<br>រោងម៉ាស៊ីនកិនស្រូវ<br>អ្នកនាំចេញអង្ករ | ព័ត៌មានពីតម្រូវការនិងការផ្គត់ផ្គង់ និងការនាំចេញនាំចូលស្រូវអង្ករ<br>ការយល់ឃើញពីវិបត្តិតម្រូវការពីវៀតណាម<br>ប្រតិកម្មនិងការផ្តល់មតិលើគោលនយោបាយស្រូវរបស់វៀតណាម និងផលិតកម្មស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា |
| | ការពិភាក្សាតាមក្រុមស្នូល (FGD) | កសិករដាំស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា | ការលំបាកក្នុងការដាំស្រូវ ប្រតិកម្មនិងជម្រើសផ្សេងទៀតរបស់គាត់ បើសិនមានវិបត្តិតម្រូវការពីវៀតណាម |

# ៣. ការប្រមូលទិន្នន័យ និងការជ្រើសយកសំណាក

ការសិក្សាឆ្លងប្រទេសនេះរួមមានការធ្វើសម្ភាសន៍ជាមួយតួអង្គខុសៗគ្នាជាច្រើន។ដូច្នេះវិទ្យាស្ថានស្រាវជ្រាវផ្នែកគោលនយោបាយបីគឺ វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) មជ្ឈមណ្ឌលសម្រាប់ការសិក្សាពីគោលនយោបាយ (CPS) និងសាកលវិទ្យាល័យ An Giang (AGU) បានសហការគ្នាប្រមូល និងវិភាគទិន្នន័យ។ ទិន្នន័យនៅកម្ពុជា CDRI និង PCS ទទួលបន្ទុកប្រមូល ដោយ CDRI ប្រមូលទិន្នន័យនៅផ្នែកខាងក្រោមនៃខ្សែសង្វាក់តម្លៃស្រូវអង្ករ ហើយ PCS ប្រមូលទិន្នន័យនៅផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃ។ ទិន្នន័យនៅវៀតណាម ប្រមូលឡើងដោយ AGU និង CDRI ។ AGU បានធ្វើសម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ (KII) ជាមួយតំណាងក្រុមហ៊ុនក្នុងវិស័យឯកជនវៀតណាម ហើយ CDRI បានធ្វើ KII ជាមួយស្ថាប័នក្នុងវិស័យសាធារណៈវៀតណាម និងក្រុមផ្តល់គំនិតនានា។ ការប្រមូលទិន្ន័យនៅកម្ពុជាធ្វើតាម អង្កេតគ្រួសារ KII និងការពិភាក្សាតាមក្រុមស្នូល (FGDs)។ កម្រងសំណួរអង្កេតបែបបរិមាណវិស័យ ត្រូវបានរចនារៀបចំឡើងស្របតាមគោលដៅនៃការសិក្សានេះ។

ដោយសារការសិក្សាស្រាវជ្រាវនេះផ្តោតលើ តំបន់នៅភាគអាគ្នេយ៍ប្រទេសកម្ពុជាជាប់នឹងព្រំប្រទល់វៀតណាម នោះ ក្រុមស្រាវជ្រាវបានជ្រើសយកខេត្ត ៣ គឺ តាកែវ ស្វាយរៀង និង ព្រៃវែង ធ្វើជាតំបន់សិក្សា ហើយបានជ្រើសយកដោយចៃដន្យមកធ្វើសម្ភាសន៍សរុបទាំងអស់ ៦០០ គ្រួសារ ពោលគឺ ២០០ គ្រួសារក្នុងមួយខេត្ត ឬ ២០ គ្រួសារក្នុងភូមិនីមួយៗនៃភូមិទាំង ១០ ក្នុងខេត្តនីមួយៗ (សរុប ៣០ ភូមិក្នុងខេត្តទាំង ៣)។

រូបភាព១: ផែនទីនៃតំបន់សិក្សា



ដើម្បីប្រមូលព័ត៌មាននៅផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃស្រូវអង្ករ មានការធ្វើ KII ១០រោងម៉ាស៊ីនកិនស្រូវ អ្នកនាំចេញ តំណាងសមាគមកិនស្រូវ និង មន្ត្រីរដ្ឋាភិបាលមានបទពិសោធន៍ក្នុងវិស័យស្រូវអង្ករនិងចំណេះដឹងជ្រៅជ្រះលើឧស្សាហកម្មស្រូវអង្ករនៅកម្ពុជា។ សម្រាប់ផ្នែកទាបនៃខ្សែសង្វាក់តម្លៃនេះ បានធ្វើ KII ១៥ ជាមួយ អាជ្ញាធរមូលដ្ឋាន មន្ត្រីមន្ទីរកសិកម្មខេត្ត មន្ទីរពាណិជ្ជកម្មខេត្ត រោងម៉ាស៊ីនកិនស្រូវក្នុងមូលដ្ឋាន ឈ្មួញនិងអ្នកនាំចេញដែលមានទីតាំងនៅក្នុងតំបន់សិក្សា ។ ដើម្បីបានព័ត៌មានបែបគុណវិស័យ មានការធ្វើ FGDs ជាមួយកសិករដាំស្រូវក្នុងខេត្តនីមួយៗ។ ការប្រមូលទិន្នន័យនៅវៀតណាម រួមមាន KIIs ជាមួយ អ្នកតំណាងវិស័យសាធារណៈ ក្រុមផ្តល់គំនិតផ្នែកស្រាវជ្រាវ និង វិស័យឯកជន ជាពិសេស អ្នកជាប់ពាក់ព័ន្ធនឹងការធ្វើជំនួញជាមួយកម្ពុជា (ព័ត៌មានលំអិតលើការប្រមូលទិន្នន័យ និងការជ្រើសយកសំណាក មានចុះក្នុងឧបសម្ព័ន្ធ១)។

# ៤. ការសិក្សាឯកសារមានស្រាប់

## ៤.១ និន្នាការទូទៅនៃវិស័យស្រូវអង្ករនៅកម្ពុជា

កសិកម្មបាននិងកំពុងដើរតួនាទីសំខាន់បំផុតមួយ ក្នុងសេដ្ឋកិច្ចកម្ពុជា។ តាំងពីដើមរៀងមក ការធ្វើកសិកម្មគឺជាមុខរបរចម្បងរបស់ប្រជាជនកម្ពុជា។ កំណើនសេដ្ឋកិច្ចរឹងមាំក្នុងពីរទសវត្សរ៍ចុងក្រោយនេះ បាននាំឲ្យមានការផ្លាស់ប្តូរយ៉ាងលឿនក្នុងរចនាសម្ព័ន្ធសេដ្ឋកិច្ច។ ចំណែកនៃវិស័យឧស្សាហកម្មនៅក្នុង ផសស បានកើនឡើងមួយជាពីរ ពីត្រឹម ១៥% ក្នុងឆ្នាំ១៩៩៦ ដល់ ជិត ៣០% ក្នុងឆ្នាំ២០១៣ រីឯចំណែកវិស័យកសិកម្មវិញ បានថយចុះជិតពាក់កណ្តាលពី ៤៣% មកត្រឹម ២៤%។ ចំណែកនៃវិស័យសេវាកម្មបន្តនៅថេរ ត្រឹមប្រមាណ ៤០% (រូបភាព ២ និង ៣)។ ថ្វីបើវិស័យកសិកម្មមានចំណែកថយចុះក្នុង ២០ ឆ្នាំចុងក្រោយក្តី ប៉ុន្តែគេនៅតែចាត់ទុកវាថាជា កម្លាំងជំរុញសំខាន់ និងជាគ្រឹះនៃសេដ្ឋកិច្ចរឹងប៉ឹងនិងធន់មាំល្អ ហើយវានៅតែជាប្រភពចំណូលចម្បងនៃប្រជាជនកម្ពុជាភាគច្រើន ជាពិសេស នៅតាមជនបទ។ គួរកត់សម្គាល់ថា កំណើនកសិកម្មនៅតែរឹងមាំនៅប្រមាណ ៥,៤% ក្នុងទូទាំងអំឡុងពេលវិបត្តិហិរញ្ញវត្ថុសកលក្នុងពេលដែលឧស្សាហកម្មបានរងផលប៉ះពាល់យ៉ាងខ្លាំង ដោយមានអត្រាកំណើនធ្លាក់ចុះរហូតដល់ ០,១%។ តាំងពីពេលនោះមក រដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ពិសេសលើការអភិវឌ្ឍកសិកម្ម ដោយមានគោលនយោបាយផ្តោតលើការកសាងប្រទេសកម្ពុជាឲ្យក្លាយអ្នកនាំចេញដ៏សំខាន់មួយក្នុងទីផ្សារពិភពលោកនូវ អង្ករដែលគេហៅថា "មាសស" របស់កម្ពុជា។

រូបភាព២៖ ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ឆ្នាំ១៩៩៦-២០១២




ប្រភព៖ សូចនាករសំខាន់ៗសម្រាប់តំបន់អាស៊ី និងប៉ាស៊ីហ្វិក (ADB 1014)

រូបភាព៣៖ ការងារបែងចែកតាមវិស័យ ឆ្នាំ១៩៩៨-២០១២




ប្រភព៖ សូចនាករសំខាន់ៗនៃទីផ្សារការងារ (ILO 2014)

ដំណាំជាក្បាលម៉ាស៊ីនទី៣ នៃសេដ្ឋកិច្ច ដោយតំណាងឲ្យ ៩% នៃកំណើន ផសស ។ ជាយូរយារមកហើយ ស្រូវអង្ករជាដំណាំចម្បងគេនៅកម្ពុជា ហើយសព្វថ្ងៃតំណាងឲ្យប្រមាណ ៥០% នៃផលដំណាំសរុប។ ផលិតកម្មស្រូវបានកើនឡើងយ៉ាងខ្លាំង ចាប់ពី ១,៧ លានតោននៅឆ្នាំ១៩៨០ ដល់ ៩,៣លានតោននៅឆ្នាំ២០១៥។ ពូជដាំដុះ រួមមាន ពូជស្រូវប្រពៃណីមិនក្រអូប ស្រូវ IR (ភាគច្រើនស្រូវប្រាំង) និង ស្រូវក្រអូប (ស្រូវវស្សា)។ ទោះបីនៅខ្វះខាតស្ថិតិជាផ្លូវការក្តី គេបានប៉ាន់ស្មាននាពេលថ្មីៗថា ស្រូវ IR តំណាងឲ្យពី មួយភាគបី ទៅ មួយភាគបួន នៃផលស្រូវសរុប។ ពីឆ្នាំ១៩៨០ ដល់ ១៩៩២ ស្រូវភាគច្រើនជាស្រូវវស្សា។ ផលិតកម្មស្រូវប្រាំងបានចាប់កើនសន្ទុះនៅឆ្នាំ១៩៩៤ ដោយកើនពីត្រឹម ០,៤លានតោននៅឆ្នាំ១៩៨០ ដល់ ២,២ លានតោននៅឆ្នាំ២០១៥ ឬ កំណើន ២៣% នៃផលិតកម្មស្រូវសរុប (រូបភាព៥)។ ផលស្រូវនៅកម្ពុជាបានកើនឡើងយ៉ាងខ្លាំងចាប់ពីឆ្នាំ២០១៥ មក ដោយសារជាសំខាន់ ការកែលំអ និងពង្រីកប្រព័ន្ធស្រោចស្រព ហើយថ្លៃលក់ស្រូវនៅកសិដ្ឋានក៏បានខ្ពស់គួរឲ្យពេញចិត្ត។

រូបភាព៤៖ ផលិតកម្មស្រូវកម្ពុជា ឆ្នាំ១៩៨០-២០១៥ (លានតោន)




ប្រភព៖ MAFF Annual Report 2016

រូបភាព៥៖ ផលិតកម្មស្រូវ ឆ្នាំ២០១៥ (%)




ប្រភព៖ MAFF Annual Report 2016

ទោះបីផលិតកម្មស្រូវកើនលឿនក្តី ក៏ការនាំចេញអង្ករបស់កម្ពុជានៅតែមានកម្រិតទាប។ ជាក់ស្តែងនៅឆ្នាំ ២០០០ កម្ពុជាផលិតស្រូវបានប្រមាណ ៤ លានតោន (រូបភាព៤) ប៉ុន្តែអាចនាំចេញអង្ករបានត្រឹមតែ ៦០០០តោន ប៉ុណ្ណោះនៅឆ្នាំនោះ (រូបភាព៦) ដែលឆ្លុះបញ្ចាំងពីសមត្ថភាពកិនស្រូវនិងនាំចេញកម្រិតទាប។ការនាំចេញអង្ករស្ទុះឡើង ពី៥១.០០០តោននៅឆ្នាំ២០១០ដល់១៧៤.៥០០តោននៅឆ្នាំ២០១១បន្ទាប់ពីរដ្ឋាភិបាលបានអនុម័តគោលនយោបាយ ផលិតស្រូវ និងនាំចេញអង្ករនៅឆ្នាំ២០១០។ នៅឆ្នាំ២០១៥ កម្ពុជាបាននាំចេញអង្ករ ជិតដល់ ៤៦៦.០០០តោន មាន តម្លៃជិតដល់ ២៨៥ លានដុល្លារអាមេរិក។ អង្ករនាំចេញនៅតែមានកម្រិតទាប បើធៀបនឹងបរិមាណស្រូវផលិតបាន (៩.៣លានតោននៅឆ្នាំ២០១៥) ។ ជិតពាក់កណ្តាល (៤៧%) នៃអង្ករនាំចេញរបស់កម្ពុជា ជាអង្ករក្រអូប។

រូបភាព៦៖ ការនាំចេញអង្ករនៅកម្ពុជា ឆ្នាំ២០០០-២០១៥ (HS1006)




ប្រភព: UN Comtrade Trade Database 2017

កំណើនផលិតកម្មបានរួមចំណែកឲ្យកើតមានអតិរេកស្រូវអង្ករអាចនាំចេញបាន ហើយផលស្រូវនេះត្រូវបានដឹក ជញ្ជូនក្រៅផ្លូវការទៅថៃ និងវៀតណាម ដោយអ្នកជំនួញមានដើមទុនច្រើន។ បរិមាណតិចឬច្រើន ល្បាយស្រូវអង្ករពូជ ខុសៗគ្នា និងវត្តមានអង្ករនៅក្នុងនោះ គឺអាស្រ័យលើកម្រិតថ្លៃខុសគ្នាប៉ុណ្ណានៅលើទីផ្សារនានានៅជិតខាងនោះ ក្នុងឆ្នាំ ជាក់លាក់ណាមួយ។ តាមធម្មតា អតិរេកស្រូវអង្ករប្រមាណមួយភាគបីហូរទៅថៃ ហើយសល់ពីនោះហូរទៅវៀតណាម។ តាមច្រកទិសនីមួយៗ មានការដឹកស្រូវអង្ករច្រើនពូជលាយឡំគ្នា ប៉ុន្តែអតិរេកស្រូវក្រអូបភាគច្រើនគេលក់ទៅឲ្យរោង ម៉ាស៊ីនកិនស្រូវថៃនៅតាមព្រំដែន រីឯស្រូវ IR ភាគច្រើនគេលក់ទៅឲ្យវៀតណាម។

ដើម្បីថែរក្សាទុកតម្លៃបន្ថែមឲ្យបានច្រើននៅក្នុងទីផ្សារក្នុងស្រុក និងបង្កើតការងារបន្ថែម កម្ពុជាមានទិសដៅនាំចេញអង្ករច្រើនថែមទៀត។ នៅឆ្នាំ២០១០ រដ្ឋាភិបាលបានអនុម័ត និងផ្សព្វផ្សាយ គោលនយោបាយផលិតកម្មនិងនាំចេញស្រូវអង្ករ ដោយកំណត់គោលដៅនាំចេញអង្ករឲ្យបាន ១ លានតោននៅត្រឹមឆ្នាំ២០១៥។ ជាលទ្ធផល ទីផ្សារស្រូវអង្ករនៅកម្ពុជាបានផ្លាស់ប្តូរយ៉ាងច្រើន។ វិនិយោគចម្បងៗទៅលើរោងម៉ាស៊ីនកិនស្រូវធំៗ និងរោងចក្រសំអាតគ្រាប់អង្ករឲ្យភ្លឺរលោង មានធ្វើឡើងជាបន្តបន្ទាប់ ហើយការនាំចេញអង្ករកំពុងកើនឡើង។ យោងតាម UN Comtrade database (2017) ការនាំចេញ មានដល់ ០,៣៥ លានតោននៅឆ្នាំ២០១៣ និង ០,៤៧ លានតោននៅឆ្នាំ២០១៥ គឺនៅទាបជាងគោលដៅ ១លានតោននោះខ្លាំងណាស់។ តាមការប៉ាន់ស្មាន ការនាំចេញអង្ករក្នុងឆ្នាំ២០១៦ មានប្រហែលគ្នានឹងឆ្នាំ២០១៥ ដែរ។ ជាក់ស្តែង បរិមាណនាំចេញបានកត់ត្រាពីខែមករា ដល់វិច្ឆិកា ២០១៦ មានប្រមាណ ០,៤៨លានតោន។

កម្ពុជានាំចេញអង្ករជាចម្បងទៅអឺរ៉ុប ហើយបន្ទាប់មកទៅអាស៊ី។ អង្ករកម្ពុជាអាចចូលទីផ្សាអឺរ៉ុបបានដោយសេរី ព្រោះទទួលបានលក្ខខណ្ឌអនុគ្រោះ (អ្វីគ្រប់យ៉ាងក្រៅពីអាវុធ) សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ដូចមានបង្ហាញក្នុងរូបភាព ៧ និង ៨ ក្នុងអង្ករនាំចេញពីកម្ពុជានៅឆ្នាំ២០១៥ មាន ៧១% បាននាំចេញទៅអឺរ៉ុប ដែលមានជាអាទិ៍ ប្រទេសបារាំង(១៥%) ប៉ូឡូញ(១១%) ហូឡង់(៨%) អ៊ីតាលី(ប្រមាណ ៥%) ហើយនិង អង់គ្លេស បែលហ្ស៊ិក ឆែក (ប្រមាណ ៤%ក្នុងប្រទេសនីមួយៗ) ។ នៅអាស៊ី កម្ពុជានាំចេញភាគច្រើនទៅប្រទេសចិន(១៤%) និង ម៉ាឡេស៊ី(១០%)។

ចំណុចគួរឲ្យភ្ញាក់ផ្អើលសម្រាប់ប្រទេសនាំចេញអង្ករ គឺ កម្ពុជាក៏មាននាំចូលអង្ករដែរ តែក្នុងចំនួនតិចតួចត្រឹមប្រមាណ ៦៨.០០០ តោន មានតម្លៃ ១១ លានដុល្លារក្នុងឆ្នាំ២០១៥ និងត្រឹម ២៤.០០០ តោនក្នុងឆ្នាំ២០១៤ (UN Comtrade 2017)។ នៅឆ្នាំ២០១៥ កម្ពុជាបាននាំចូលអង្ករ ៨៨%ពីវៀតណាម ១០%ពីថៃ និង ១%ពីសហរដ្ឋអាមេរិក (រូបភាព៩)។

រូបភាព៧៖ ការនាំចេញអង្កររបស់កម្ពុជាបែងចែកតាមតំបន់ ឆ្នាំ២០១៥ (បរិមាណ)




ប្រភព៖ UN Comtrade 2017

រូបភាព៨៖ ការនាំចេញអង្ករបស់កម្ពុជាបែងចែកតាមប្រទេស ឆ្នាំ២០១៥ (បរិមាណ)




ប្រភព៖ UN Comtrade 2017

រូបភាព៩៖ ការនាំចូលអង្ករបស់កម្ពុជា ឆ្នាំ២០១៥ (បរិមាណ)




ប្រភព៖ UN Comtrade 2017

## ៤.២ ស្រូវអង្ករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា

### *កម្រិតធ្វើកសិកម្ម*

ខេត្តតាមព្រំដែននៅភាគអាគ្នេយ៍ប្រទេសកម្ពុជា រួមមាន តាកែវ ស្វាយរៀង និង ព្រៃវែង ជាច្រករបៀងពាណិជ្ជកម្ម ជាពិសេសសម្រាប់កសិកម្ម។ ផលិតកម្មស្រូវរួមចំណែកយ៉ាងច្រើនដល់សេដ្ឋកិច្ចនៅតំបន់នេះ ដែលមានផ្ទៃដីដាំស្រូវនៅរដូវវស្សាប្រមាណ ៦៤៨.០០០ ហិកតា ត្រូវជាប្រមាណ ២៥% នៃផ្ទៃដីដាំស្រូវសរុបទូទាំងប្រទេស (MAFF 2015b)។ ពូជស្រូវគេនិយមដាំបំផុត គឺ ស្រូវ IR ជាពិសេស IR504។

កសិករនៅភាគអាគ្នេយ៍កម្ពុជា មានទំនាក់ទំនងរយៈពេលវែងជាមួយឈ្មួញមកពីវៀតណាម។ ឈ្មួញវៀតណាមផ្តល់ឲ្យកសិករនូវ ស្រូវពូជ ជាពិសេស IR504 ជី និងធាតុចូលចាំបាច់ផ្សេងៗទៀត។ ការផ្តល់នេះជួនកាលជាការឲ្យខ្ចីមុន ដែលជួយកាត់បន្ថយសម្ពាធកង្វះសាច់ប្រាក់របស់កសិករក្នុងរយៈពេលខ្លី។ ប៉ុន្តែក្នុងប្រតិបត្តិការជំនួញប្រភេទនេះ កសិករកម្ពុជាមានកាតព្វកិច្ចត្រូវលក់ស្រូវរបស់ខ្លួនទៅឲ្យឈ្មួញវៀតណាមវិញ។

### *ការចែកចាយ និងការលក់*

ស្រូវភាគច្រើននៅភាគអាគ្នេយ៍ គេនាំចេញទៅវៀតណាមភ្លាមៗបន្ទាប់ពីការប្រមូលផល ព្រោះឈ្មួញវៀតណាមមានឡូជីស្ទិកប្រកបដោយប្រសិទ្ធភាព បរិមាណទិញធំ និងការលក់ចេញលឿន។ ក្នុងរដូវប្រមូលផល ឈ្មួញវៀតណាមទៅដល់វាលស្រែកសិករកម្ពុជាដោយផ្ទាល់ ហើយទិញស្រូវនៅថ្នាល់កន្លែងដោយបង់ប្រាក់ឲ្យមុន។

ប្រព័ន្ធឡូជីស្ទិករបស់ឈ្មួញវៀតណាម មានប្រសិទ្ធភាពខ្លាំងណាស់។ ពួកគេអាចចូលទៅដល់វាលស្រែភាគច្រើនដោយប្រើរថយន្តដឹកទំនិញ និងផ្លូវទឹក ហើយផ្ទុកស្រូវបានច្រើន និងដឹកបញ្ជូនទៅរោងម៉ាស៊ីនកិនស្រូវវៀតណាមតែម្តង។ ដោយសារមានទុនបង្វិលគ្រប់គ្រាន់ និងការលក់ចេញលឿន ឈ្មួញវៀតណាមអាចទិញស្រូវបានយ៉ាងច្រើនក្នុងរយៈពេលយ៉ាងខ្លី ហើយសមត្ថភាពនេះសំខាន់ជាខ្លាំងក្នុងរដូវប្រមូលផល។ ជាលទ្ធផល ឈ្មួញវៀតណាមមានកម្លាំងទិញស្រូវធំខ្លាំងណាស់។

### *ថ្លៃស្រូវ*

ដោយសារមានកម្លាំងទិញខ្លាំង ឈ្មួញវៀតណាមតែងក្លាយជាអ្នកកំណត់ថ្លៃ។ ថ្លៃនេះ ឈ្មួញនិងរោងម៉ាស៊ីនកិនស្រូវកម្ពុជាតែងអនុវត្តតាម ព្រោះទិញស្រូវក្នុងបរិមាណតិចជាងដោយសារកង្វះទុនបង្វិល។

ថ្លៃស្រូវប្រែប្រួលខ្លាំង ទៅតាមការឡើងចុះតម្រូវការពីឈ្មួញវៀតណាម។ បើសិនមានកង្វះស្រូវក្នុងស្រុកនៅវៀតណាមថ្លៃស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជារំពឹងថានឹងកើនឡើង។ប្រសិនបើមានកង្វះតម្រូវការពីឈ្មួញវៀតណាមអតិរេកស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា រំពឹងថានឹងកើនឡើង ព្រោះតម្រូវការរបស់ឈ្មួញ និងរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជាមានកម្រិតទាប។ តម្រូវការក្នុងស្រុកនូវស្រូវអង្ករ មិនអាចដើរតួនាទីរក្សាស្ថិរភាពថ្លៃបានទេ។

## ៤.៣ និន្នាភាពទូទៅនៃវិស័យស្រូវអង្ករនៅវៀតណាម

វៀតណាមជាប្រទេសផលិតស្រូវធំជាងគេក្នុងតំបន់អាស៊ាន បន្ទាប់ពីថៃ។ ស្រូវជាដំណាំសំខាន់ជាងគេនៅវៀតណាម ហើយដើរតួនាទីសំខាន់ក្នុងការអភិវឌ្ឍកសិកម្មក្នុងប្រទេស។ នៅឆ្នាំ២០១២ ស្រូវគ្របដណ្តប់លើប្រមាណ ៤០% នៃផ្ទៃដីកសិកម្មសរុប ហើយផ្ទៃដីស្រែសរុបប្រមាណ ៤ លានហិកតា គ្មានការផ្លាស់ប្តូរអ្វីច្រើនទេតាំងពីឆ្នាំ១៩៩០មក (រូបភាព១០)។ តំបន់ដាំស្រូវចម្បងៗ រួមមាន ដីសណ្តទន្លេក្រហម (០,៦ លានហិកតា) និងដីសណ្តទន្លេមេគង្គ (១,៩ លានហិកតា)។ តំបន់ទាំងពីរនេះតំណាងឲ្យ ៥១% នៃដីដាំស្រូវសរុបនៅវៀតណាម។ ប៉ុន្តែចំណែកនៃ ដីដាំស្រូវក្នុងផ្ទៃដីកសិកម្មសរុបនៅវៀតណាម បានថយចុះ ពីជិត ៦០% ក្នុងឆ្នាំ១៩៩៦ មកត្រឹម ៤០% ក្នុងឆ្នាំ២០១២ ដែលឆ្លុះបញ្ចាំងពីកំណើនដំណាំផ្សេងៗទៀត។

ផលិតកម្មស្រូវនៅវៀតណាមបានកើនឡើងពីប្រមាណ ៣០ លានតោនក្នុងឆ្នាំ១៩៩៦ ដល់ប្រមាណ ៤៥ លានតោនក្នុងឆ្នាំ២០១២។ ដីដណ្តទន្លេមេគង្គរួមចំណែកប្រមាណ ៥៥% នៃផលិតកម្មស្រូវសរុប ហើយ ដីដណ្តទន្លេក្រហមប្រមាណ ១៧% ។ ផលិតកម្មស្រូវស្ទើរតែទាំងអស់ (៩៥%) ក្នុងដីសណ្តទន្លេមេគង្គត្រូវបាននាំចេញ រីឯស្រូវដាំដុះនៅភាគខាងជើង គឺសម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ផលិតម្មស្រូវដែលបានកើនឡើង ទោះបីផ្ទៃដីដាំស្រូវនៅថេរក្តី គឺដោយសារទិន្នផលបានកើនឡើង។ ទិន្នផលស្រូវជាមធ្យមនៅវៀតណាម មានប្រហែល ៥,៦ តោន/ហិកតា។

រូបភាព១០៖ ផ្ទៃដីដាំស្រូវនៅវៀតណាម




ប្រភព: Adapted from Slide Presentation Dr. Tran Cong Thang 2016, cited from GSO

រូបភាព១១ និង ១២ បង្ហាញពីការប្រែប្រួលការនាំចេញអង្ករបស់វៀតណាម គិតតាមឆ្នាំ និងតាមប្រទេស។ ការនាំចេញអង្ករបានស្ទុះឡើងពីឆ្នាំ២០០១ ដល់ ២០១១ ពីជិត ២ លានតោន (០,៦ ប៊ីលានដុល្លារ) ដល់ប្រមាណ ៧លានតោន (៣,៦ ប៊ីលានដុល្លា)។ បន្ទាប់មកអង្ករនាំចេញបានធ្លាក់ចុះបន្តិចវិញ មកត្រឹមជាមធ្យមប្រមាណ ៦,៥ លានតោន/ឆ្នាំ ពីឆ្នាំ២០១៣-១៥។

រូបភាព១១៖ ការនាំចេញអង្កររបស់វៀតណាម ឆ្នាំ២០០០-២០១៥ (HS1006)




ប្រភព: UNCOMTRADE 2017។ សំគាល់: ទិន្នន័យមានមិនពេញលេញសម្រាប់ឆ្នាំ២០១២

រចនាសម្ព័ន្ធនាំចេញរបស់វៀតណាមបាននិងកំពុងផ្លាស់ប្តូរ។ ដូចមានបង្ហាញក្នុង រូបភាព១២ ទីផ្សារនាំចេញធំបំផុតរបស់វៀតណាមនៅឆ្នាំ២០១០ គឺ តំបន់អាស៊ាន (ប្រមាណ ៥០%) និងអាហ្វ្រិក (ប្រមាណ ២០%)។ ប៉ុន្តែពីឆ្នាំ

២០១៣ ដល់ ២០១៥ គោលដៅនាំចេញអង្ករធំបំផុតរបស់វៀតណាមគឺ ប្រទេសចិនដែលតំណាងឲ្យប្រមាណ ៣៥% នៃអង្ករនាំចេញសរុប។ នៅឆ្នាំ២០១៥ បណ្តាប្រទេសអាស៊ានមានចំណែកប្រមាណ ៣៥% ក្នុងការនាំចេញអង្កររបស់វៀតណាម រីឯបណ្តាប្រទេសនៅអាហ្វ្រិក មានប្រមាណ ១០%។

រូបភាព១២៖ ការនាំចេញអង្កររបស់វៀតណាម គិតតាមប្រទេស ឆ្នាំ២០១០-២០១៥ (HS1006)




ប្រភព: UNCOMTRADE 2016. សំគាល់: ទិន្នន័យមានមិនពេញលេញទេសម្រាប់ឆ្នាំ២០១២

រូបភាព១៣៖ ការនាំចូលអង្កររបស់វៀតណាម គិតតាមប្រទេស ២០១៥




ប្រភព៖ UNCOMTRADE 2017

វៀតណាមជាប្រទេសនាំចេញអង្ករយ៉ាងធំមួយក៏ពិតមែន ប៉ុន្តែក៏មាននាំចូលអង្ករពី ៥០.០០០ ទៅ ៦០.០០០ តោន/ឆ្នាំ ហើយភាគច្រើនពីប្រទេសចិន (៤៨%) និងថៃ (២៧%) (រូបភាព១៣)។ គួរឲ្យភ្ញាក់ផ្អើលដែរដែលក្នុងទិន្នន័យមូលដ្ឋានUNCOMTRADE 2017 គ្មានឃើញកំណត់ត្រាអ្វីពី ការនាំចូលពីកម្ពុជាទេ។ ទោះបីស្ថិតិជាផ្លូវការមិនមានបង្ហាញតួលេខក្តី ក៏គេប៉ាន់ស្មានថា វៀតណាមនាំចូលមិនតិចជាង ២ លានតោនស្រូវ/ឆ្នាំ ពីកម្ពុជានោះទេ (តារាង១)។

# ៥. លទ្ធផលរកឃើញសំខាន់ៗតាមវិធីសាស្ត្របែបគុណវិស័យ

## ៥.១ គោលនយោបាយកសិកម្ម និងស្រូវ នៅវៀតណាម

កសិកម្មបានដើរតួនាទីយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចវៀតណាម ហើយផលិតកម្មស្រូវចូលរួមចំណែកយ៉ាងច្រើនក្នុងការអភិវឌ្ឍកសិកម្ម។ ដំណាំស្រូវជាប្រភពចំណូលដ៏សំខាន់សម្រាប់ប្រជាជននៅជនបទ ក្នុងនេះមាន គ្រួសាររហូតដល់ ៧០%(ប្រមាណ ៩ លានគ្រួសារ)ជាកសិករដាំស្រូវ។ចាប់ពីទសវត្សរ៍១៩៨០មកក្នុងទិសដៅផ្គត់ផ្គង់ប្រជាជនរហូតដល់ជាង៥០លាននាក់នៅពេលនោះនិងប្រមាណ៩៣លាននាក់ក្នុងឆ្នាំ២០១៦គោលនយោបាយស្រូវបានផ្តល់អាទិភាពដល់បរិមាណតាមរយៈដំណាំមានទិន្នផលខ្ពស់។ វិនិយោគលើប្រព័ន្ធស្រោចស្រព ជាចំណុចផ្តោតចម្បងរបស់រដ្ឋាភិបាល។ បន្ទាប់ពីបានដាំដុះស្រូវតាមបែបប្រពលវប្បកម្មអស់ ៣ ទសវត្សរ៍មក វៀតណាមបានក្លាយជាប្រទេសនាំចេញអង្ករនាំមុខគេក្នុងពិភពលោក។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ អត្រាកំណើនផលស្រូវ និងទិន្នផលនៅវៀតណាម បានថយចុះវិញ។ ការប្រើប្រាស់អស់ធនធានធម្មជាតិ ការបំពុលបរិស្ថាន សមត្ថប្រកួតប្រជែងចុះខ្សោយ ការផ្លាស់ប្តូរតម្រូវការនៅអន្តរជាតិ និងក្នុងស្រុក ឧស្សាហូបនីយកម្មយ៉ាងលឿន នគរូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ សុទ្ធសឹងជាកត្តាតម្រូវឲ្យវៀតណាមរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច ព្រមទាំងគោលនយោបាយកសិកម្ម (Dang 2014)។

ម៉្យាងទៀត បទសម្ភាសន៍ជាមួយអ្នកកសាងគោលនយោបាយផ្សេងៗ បានបង្ហាញដូចគ្នាថា រដ្ឋាភិបាលវៀតណាមមានបំណងធ្វើការផ្លាស់ប្តូរពីដំណាំស្រូវមានតម្លៃទាប ទៅផលិតស្រូវមានតម្លៃខ្ពស់ ឬដំណាំមានតម្លៃខ្ពស់ផ្សេងទៀត។ ពួកគេមានយោបល់ថា ការដាំតែស្រូវមានទិន្នផលខ្ពស់តែតម្លៃទាប គឺមិនអាចលើកកម្ពស់ជីវភាពកសិករបានទេ ហើយកន្លងមកបាននាំឲ្យខូចខាតបរិស្ថានថែមទៀត។ ទោះបីមានគោលនយោបាយជួយគាំទ្រជាច្រើនក្តី ក៏កសិករមានអត្រាចំណេញតិចខ្លាំងណាស់ក្នុងផលិតកម្មស្រូវរបស់ខ្លួន រីឯឈ្មួញ និងអ្នកនាំចេញអាចរកចំណេញបានយ៉ាងច្រើន។ ថ្លៃលក់ស្រូវនៅកសិដ្ឋានទាបពេក មិនអាចឲ្យកសិករបានចំណេញច្រើនទេ បើតាមសំដីអ្នកឆ្លើយសម្ភាសន៍ម្នាក់។ ពួកគេមានមតិទៀតថា ទោះបីវៀតណាមបាននាំចេញអង្ករច្រើនសន្ធឹកទៅទីផ្សារអន្តរជាតិក្តី ប៉ុន្តែអត្រាចំណេញបានតិចជាងកសិផលផ្សេងៗទៀត។ ពួកគេបានសង្កេតឃើញថា ទីផ្សារអង្ករអន្តរជាតិមានការប្រកួតប្រជែងខ្លាំងណាស់ ហើយអ្នកនាំចេញមិនមានកម្លាំងចរចាច្រើនទេ សូម្បីប្រទេសនាំចេញអង្ករយ៉ាងធំដូចវៀតណាមក្តី។ ការនាំចេញអង្ករក៏ស្មុគស្មាញ និងមានចំណាយច្រើនដែរ។ ប្រទេសខ្លះដូចជាហ្វីលីពីនជាដើម តម្រូវឲ្យក្រុមហ៊ុននាំចេញបរទេសធ្វើការដេញថ្លៃដើម្បីបានសិទ្ធិនាំចូលអង្ករ ហើយវិធីនេះធ្វើឲ្យថ្លៃធ្លាក់ចុះសឹងដល់ចំណុចស្មើដើមគ្មានចំណេញសោះ។

សរុបមក ទាំងក្នុងបទសម្ភាសន៍ និងការពិភាក្សា អ្នកកសាងគោលនយោបាយ និងអ្នកស្រាវជ្រាវពីគោលនយោបាយស្រូវ មានមតិស្របគ្នាថា ដោយសារការបំពុលដីនិងទឹកកម្រិតខ្ពស់ និងការប្រែប្រួលតម្រូវការទីផ្សារ វៀតណាមមិនគួរពឹងផ្អែកតែលើផលិតកម្មតាមបែបប្រពលវប្បកម្មនូវស្រូវមានតម្លៃទាបនោះទេ ប៉ុន្តែត្រូវធ្វើពិពិធកម្មដោយងាកទៅផលិតស្រូវមានតម្លៃខ្ពស់ ឬដំណាំ/ផលិតផលកសិកម្មផ្សេងដែលមានតម្លៃខ្ពស់វិញ។ ប៉ុន្តែទាំងអស់គ្នាសុទ្ធតែបារម្ភពី ការផ្លាស់ប្តូរចំណុចផ្តោតនេះដែលត្រូវការពេលជាច្រើនឆ្នាំ ទើបអាចបំផុសការយល់ដឹងក្នុងចំណោមកសិករបាន ហើយក៏ត្រូវការធនធានច្រើនគ្រប់គ្រាន់ដែរទើបអាចអនុវត្តគោលនយោបាយនេះបានជោគជ័យ។ ការសិក្សាឡើងវិញដោយ Tran and Nguyen (2015) ក៏បានលើកពីចំណុចខ្វះខាតក្នុងគោលនយោបាយរៀបចំមុខដំណាំឡើងវិញ ពោលគឺ ការយល់ដឹងមិនបានស្មើគ្នាល្អពីគោលនយោបាយក្នុងចំណោមកសិក។ មូលនិធិដើម្បីជួយគាំទ្រគោលនយោបាយ មិនមានគ្រប់គ្រាន់ទេ ជាពិសេសសម្រាប់ហេដ្ឋារចនាសម្ព័ន្ធនិងការស្រោចស្រព។កាន់តែសំខាន់ថែមទៀតក្នុងពេលកំពុងផ្លាស់ប្តូរទីផ្សារសម្រាប់ដំណាំថ្មីៗមិនមានស្ថិរភាពទេហើយមិនអាចស្រូបយកកំណើនយ៉ាងធំក្នុងផលិតកម្មបានឡើយ។ស្រដៀងគ្នាដែរ សម្ភាសន៍ KII ជាមួយបណ្ឌិត Dang Kimsun បង្ហាញថា ពេលខ្លះវាលំបាកនឹងផ្លាស់ប្តូរផ្នត់គំនិតនិងអាកប្បកិរិយារបស់កសិករ ជាពិសេសនៅពេលពួកគាត់ធ្លាប់ធ្វើអ្វីមួយជាយូរឆ្នាំ ហើយទីផ្សារ និងបណ្តាញផ្សេងៗក៏មានស្រាប់។ ដូច្នេះ ត្រូវមានពេល និងធនធានច្រើនសម្រាប់ធ្វើការផ្លាស់ប្តូរក្នុងខ្សែសង្វាក់តម្លៃស្រូវអង្ករ ដើម្បីឲ្យផលិតកម្ម និងទីផ្សារអាចផ្លាស់ប្តូរបានក្នុងពេលជាមួយគ្នា។

## ៥.២ សម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះក្នុងវិស័យឯកជនវៀតណាម

### *បទពិសោធន៍កសិករវៀតណាមនៅខេត្ត An Giang*

សម្ភាសន៍ KII ជាមួយកសិករវៀតណាម សាកលវិទ្យាល័យ An Giang បានធ្វើឡើងនៅក្នុងខេត្ត An Giang ដោយប្រើកម្រងសំណួរពាក់កណ្តាលរៀបរយ។ An Giang ស្ថិតក្នុងចំណោមខេត្តផលិតបានច្រើនៗជាងគេនូវ ស្រូវស្រាលមានទិន្នផលខ្ពស់នៅតំបន់ដីសណ្តទន្លេមេគង្គ។ នៅមុនទសវត្សរ៍១៩៨០ កសិករផលិតភាគច្រើននូវស្រូវឡើងទឹកមួយដងក្នុងរដូវវស្សា (ឧសភា-ធ្នូ) ដោយឆ្លាស់គ្នាជាមួយនឹងសណ្តែក និងល្ង (ធ្នូ-ឧសភា) ។ នៅក្រោយពីឆ្នាំ១៩៨៥ កសិករនៅតំបន់ខ្លះក្នុងខេត្ត An Giang បានប្រើពូជស្រូវស្រាលមានទិន្នផលខ្ពស់ ហើយផ្លាស់ប្តូរទៅដាំស្រូវឲ្យបានពីរដង។ ដំណាំស្រូវទី១ ហៅថា "ស្រូវរដូវត្រជាក់-រដូវស្លឹកឈើលាស់" ត្រូវដាំដុះពីខែវិច្ឆិកា-កុម្ភៈ ហើយ ដំណាំស្រូវទី២ ហៅថា "ស្រូវរដូវក្តៅ-រដូវភ្លៀង" ត្រូវដាំដុះពីខែឧសភា-សីហា។ ចាប់ពីខែសីហា ដល់វិច្ឆិកា ដីស្រែត្រូវទឹកជន់លិចហើយទទួលបានដីល្បាប់ និងជីជាតិថែមទៀត។ ចាប់ពីទសវត្សរ៍១៩៩០ មក កសិករជាច្រើននាក់ទៀតបានផ្លាស់ប្តូរមកដាំស្រូវឲ្យបានពីរដង ហើយនៅក្រោយឆ្នាំ២០០០ មានកសិករកាន់តែច្រើនបានផ្លាស់ប្តូរមកដាំស្រូវឲ្យបានបីដង។ ឥឡូវនេះ មានដីស្រែជាងពីរភាគបី (១៦៥.000 ហិកតា) ក្នុងខេត្ត An Giang ត្រូវបានកែប្រែមកដាំស្រូវឲ្យបានបីដង។

នៅមុនឆ្នាំ២០១០ កសិករភាគច្រើនតែងប្រើស្រូវពូជដែលគាត់លៃស្តុកទុកដោយខ្លួនឯង។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗមានកសិករកាន់តែច្រើនបានប្រើប្រាស់គ្រាប់ពូជមានការបញ្ជាក់គុណភាពត្រឹមត្រូវ ព្រោះគាត់បានទទួលស្គាល់ពីសារៈសំខាន់របស់វា។ ក្នុងបទសម្ភាសន៍ជាមួយកសិករប្រាំនាក់ មានបួននាក់មិនបានប្រើ គ្រាប់ពូជ IR50404 ទេ ដោយបានប្រើពូជ DS1, IR6976, OM6976 និង ពូជ IR ផ្សេងៗទៀត។

កសិករដែលកំពុងដាំស្រូវ IR50404 លើដីមួយកន្លែងតូចត្រឹម១,៥ហិកតា។ ចំណាយផលិតកម្មសរុបក្នុងដីមួយហិកតា មានប្រមាណ ១១.៩៤៥.000ដុង (៥២៩ដុល្លារ) ក្នុងនេះ ការប្រមូលផលមានចំណែកធំជាងគេ (១៧%) បន្ទាប់មកគឺ ការរៀបចំដី (១៦%) ជីនិងថ្នាំសម្លាប់សត្វចង្រៃ (១៤%) និង ពលកម្មសម្រាប់ដាក់ថ្នាំសម្លាប់សត្វចង្រៃនិងជី (១១,៦%)។ ស្រូវ IR50404 បានផ្តល់ទិន្នផល ៩,៣តោន/ហិកតា ប៉ុន្តែលក់បានថ្លៃទាប (ប្រមាណ 0,២២ដុល្លារក្នុងស្រូវមួយគ.ក)។

បួនគ្រួសារផ្សេងទៀតដែលកំពុងដាំស្រូវមិនមែនពូជ IR50404 បានប៉ាន់ស្មានថា ចំណាយសរុបរបស់គាត់ក្នុងការដាំស្រូវមួយដង មានពី ៥00ដុល្លារ ទៅ ១.១00ដុល្លារ/ហិកតា ហើយបានទិន្នផលត្រឹម ៦,៧ ទៅ ៨,0 តោន/ហិកតា គឺទាបជាង ស្រូវ IR50404 ប៉ុន្តែលក់បានថ្លៃខ្ពស់ជាងដល់ 0,២២ ទៅ 0,២៩ដុល្លារ/គ.ក។ ដូច្នេះស្រូវមិនមែនពូជ IR50404 អាចរួមចំណែកបានច្រើនជាង ក្នុងការលើកស្ទួយជីវភាពកសិករ។

កសិករឆ្លើយសម្ភាសន៍មានមធ្យោបាយខុសៗគ្នា ដើម្បីលក់ស្រូវរបស់ខ្លួន។ កសិករប្រហែលពាក់កណ្តាលមានកិច្ចសន្យាជាលាយលក្ខណ៍អក្សរជាមួយឈ្មួញឬក្រុមហ៊ុន មុនពេលចាប់ផ្តើមដាំស្រូវ។ កសិករប្រហែលពាក់កណ្តាលទៀតគ្មានកិច្ចសន្យាជាផ្លូវការទេ ប៉ុន្តែមានការព្រមព្រៀងដោយផ្ទាល់មាត់ជាមួយឈ្មួញលើការទិញនិងលក់ស្រូវ នៅពេលជិតប្រមូលផល។ គួរកត់សំគាល់ថា អ្នកមានកិច្ចសន្យាគាត់ពេញចិត្តនឹងថ្លៃបានកំណត់ រីឯអ្នកគ្មានកិច្ចសន្យាច្រើនតែរួមសហការជាមួយកសិករនៅជិតខាង ដើម្បីចរចាថ្លៃជាមួយឈ្មួញ។ បទសម្ភាសន៍បង្ហាញថា កសិករគ្មានកិច្ចសន្យាមិនសូវពេញចិត្តនឹងថ្លៃលក់បានទេ។

### *បទពិសោធន៍របស់ឈ្មួញ និងអ្នកនាំចេញវៀតណាម*

ក្រុមស្រាវជ្រាវមកពីសាកលវិទ្យាល័យ An Giang បានធ្វើ KII បី ជាមួយឈ្មួញវៀតណាម និង KII បីទៀតជាមួយអ្នកនាំចេញ។ ក្នុងចំណោមឈ្មួញទាំងបី មានម្នាក់ធ្លាប់ធ្វើជំនួញនៅកម្ពុជា ដោយកាលពីមុនគាត់ធ្លាប់ចូលមកកម្ពុជាទិញស្រូវដោយខ្លួនឯង តែឥឡូវគាត់ទិញស្រូវពីកម្ពុជាតាមរយៈភ្នាក់ងារផ្សេងៗ ដែលគាត់បង់កម្រៃឲ្យ 0,0៩ដុល្លារ/គ.ក ស្រូវ។

ម្ចាស់ក្រុមហ៊ុនមួយបានពន្យល់ពីបទពិសោធន៍របស់គាត់ក្នុងការធ្វើជំនួញនៅកម្ពុជា។ថ្លៃប្រែប្រួលទៅតាមប្រភេទស្រូវ និងពេលទិញ។ គាត់ត្រូវប្រកួតប្រជែងជាមួយ ឈ្មួញថៃដែលឲ្យថ្លៃខ្ពស់ជាង។ ប៉ុន្តែឈ្មួញវៀតណាមមានប្រៀបខាងភូមិសាស្ត្រព្រោះនៅជិតព្រំដែន រីឯឈ្មួញថៃមិនអាចចូលដល់តំបន់ដាច់ស្រយាលទេ។ ស្រូវ IR50404 មកពីកម្ពុជា មានគុណភាពទាបជាងស្រូវមកពីវៀតណាម។ ស្រូវកម្ពុជាមានសម្បកក្រាស់ជាង ដូច្នេះកិនបានអង្ករតិចជាង។ តួយ៉ាង អត្រាការកិនស្រូវគឺ ០,៧៨ សម្រាប់ស្រូវ IR504 វៀតណាម និង ០,៧២ សម្រាប់ស្រូវ IR504 កម្ពុជា។

ហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជាមិនសូវល្អទេ (ផ្លូវមិនគ្រប់គ្រាន់ និងមិនល្អ)។ របៀបរបបស្ថាប័ននៅព្រំដែនមិនសូវមានប្រសិទ្ធភាពទេ។ ក្នុងករណីខ្លះ ឈ្មួញត្រូវតែប្រើច្រកក្រៅផ្លូវការដើម្បីនាំចូលអង្ករមកពីកម្ពុជា។ ឈ្មួញវៀតណាមត្រូវតែទិញស្រូវតាមរយៈឈ្មួញកណ្ដាលកម្ពុជា។

ក្នុងចំណោមក្រុមហ៊ុនទាំងបី មានពីរ (Phat Tai និង Quang Phat) បានទិញ និងនាំចេញទាំងអង្ករ IR504 និងអង្ករមានគុណភាពខ្ពស់ រីឯក្រុមហ៊ុន Loc Troi ធ្វើជំនួញតែអង្ករមានគុណភាពខ្ពស់ប៉ុណ្ណោះ។ Loc Troi ទិញស្រូវភាគច្រើនពីតំបន់ដីសណ្ដទន្លេមេគង្គ ហើយដើម្បីធានាគុណភាពបានវិនិយោគលើសម្ភារបរិក្ខារសម្រាប់ត្រួតពិនិត្យផលិតផលនិងរបៀបដាំដុះ ត្រួតពិនិត្យសំណល់ជាតិគីមី និងជៀសវាងការលាយឡំពូជស្រូវចូលគ្នា។ ក្រុមហ៊ុននេះនាំចេញជាសំខាន់ទៅហុងកុង(៧០,៧% នៃចំនួនសរុប) ចិន(១៣,៤%) ហើយនិង សិង្ហបុរី អឺរ៉ុប សហរដ្ឋអាមេរិកសរុបប្រមាណ ១៥%។

ក្រុមហ៊ុនពីរទៀតនោះ បាននាំចេញស្ទើរតែទាំងអស់ទៅចិន (៩០% នៃចំនួនសរុប) ហើយ ១០% ទៀតបានដឹកទៅអាហ្វ្រិក ម៉ាឡេស៊ី និងហ្វីលីពីន។ អង្ករ IR50404 មានប្រមាណ ៥៥% ក្នុងការនាំចេញសរុបរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនទាំងពីរបានរាយការណ៍ថា ចូលចិត្តនាំចេញអង្ករមានគុណភាពខ្ពស់ ព្រោះមានអត្រាចំណេញច្រើនជាង។ ពួកគេចង់នាំចេញទៅសហរដ្ឋអាមេរិក និងអឺរ៉ុប ប៉ុន្តែក៏ចង់ថែរក្សាទីផ្សារមានស្រាប់នៅចិន និងអាហ្វ្រិកដែរ។ ពួកគេលើកថាវៀតណាមនៅតែមានសក្ដានុពលធំក្នុងការផលិតអង្ករមានគុណភាពទាប។ ចិនមានតម្រូវការច្រើនណាស់នូវអង្ករមានគុណភាពទាបដែលគេប្រើភាគច្រើនសម្រាប់ផលិតម្សៅ រីឯប្រទេសអាហ្វ្រិក ត្រូវការវាសម្រាប់ហូប។

តារាង៣៖ អង្ករនាំចេញបែងចែកតាមប្រទេស (%)

| ឈ្មោះក្រុមហ៊ុន | ចិន | ម៉ាឡេស៊ី | កោះGuam | ហ្វីលីពីន | ហុងកុង | សិង្ហបុរី | អឺរ៉ុប | ស.រ.អា | អាហ្វ្រិក |
|---|---|---|---|---|---|---|---|---|---|
| Phat Tai | 90.00 | 8.00 | 1.00 | 1.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 |
| Loc Troi Group | 13.45 | 0.00 | 0.00 | 0.00 | 70.77 | 5.17 | 4.39 | 6.22 | 0.00 |
| Quang Phat | 90.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 0.00 | 10.00 |

ក្រុមហ៊ុននាំចេញទាំងបី បានយល់ស្របថា ទីផ្សារសម្រាប់អង្ករមានគុណភាពខ្ពស់ ផ្ដល់ចំណេញបានច្រើនជាងទីផ្សារសម្រាប់អង្ករមានគុណភាពទាប។ ទោះយ៉ាងនេះក្ដី ប្រទេសខ្លះចូលចិត្តអង្ករមានគុណភាពខ្ពស់ ហើយខ្លះទៀតចូលចិត្តអង្ករគុណភាពទាប។ អ្នកនាំចេញត្រូវចេះបត់បែនទៅតាម តម្រូវការរបស់អតិថិជន។ រហូតមកទល់បច្ចុប្បន្ន វៀតណាម មិនមានផ្ដល់អាទិភាពដល់អង្ករប្រភេទណាមួយទេ ហើយស្ថានភាពនេះបានទុកឲ្យទីផ្សារជួយកំណត់ផលិតកម្ម។ ក្រុមហ៊ុន Loc Troi បានលើកយោបល់ថា រដ្ឋាភិបាលត្រូវមានយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ស្រូវអង្ករ និងមិនមែនត្រឹមតែសម្រាប់ផលិតកម្មនិងកសិករប៉ុណ្ណោះទេ ប៉ុន្តែក៏សម្រាប់ទាំងភ្នាក់ងារផ្សេងទៀតនៃខ្សែសង្វាក់តម្លៃទៀតផង។ កាន់តែសំខាន់ទៀត វៀតណាមគួរមានសញ្ញាពាណិជ្ជកម្មអង្ករ សម្រាប់ទីផ្សារអន្តរជាតិ។ រដ្ឋាភិបាលគួរជួយគាំទ្រក្រុមហ៊ុន ក្នុងការអភិវឌ្ឍ និងលើកស្ទួយអង្ករវៀតណាម។ Quang Phat បានទាយទុកថា ទីផ្សារសម្រាប់អង្ករ IR504 នៅតែមានលំនឹងល្អនៅឆ្នាំក្រោយ ប៉ុន្តែវាក៏អាស្រ័យលើអាកាសធាតុនៅប្រទេសនាំចេញផ្សេងទៀត ដូចជា ឥណ្ឌា និងទីផ្សារសកល ជាដើម។ ក្រុមហ៊ុននៅតែបន្តទិញអង្ករ IR504 ប៉ុន្តែក្នុងចំនួនផ្អែកលើទីផ្សារ។ ក្រុមហ៊ុនលើកមតិដែរថា អត្រាការប្រាក់នៅធនាគារគួរតែថយចុះ។

## ៥.៣ ស្ថានភាពវិស័យស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា

### *ផលិតកម្មស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា*

កម្ពុជាមានរដូវធំៗពីរគឺ រដូវប្រាំង និង រដូវវស្សា។ រដូវវស្សាចាប់ផ្ដើមពីខែមិថុនា ដល់ ធ្នូ ហើយរដូវប្រាំងពីពាក់កណ្ដាលខែធ្នូ ដល់ខែមេសា។ កាលពីមុន ដោយសារកង្វះប្រព័ន្ធស្រោចស្រព កសិករអាចដាំស្រូវតែក្នុងរដូវវស្សា ហើយទុកដីឲ្យនៅទំនេរក្រោយពេលប្រមូលផលរួច។ ឥឡូវនេះដោយសារការអភិវឌ្ឍសេដ្ឋកិច្ច ការកែលំអប្រព័ន្ធស្រោចស្រព និងការប្រែប្រួលអាកាសធាតុ កសិករខ្លះអាចដាំស្រូវបានទាំងនៅរដូវវស្សា និងរដូវប្រាំង។ ពូជស្រូវថ្មីៗជាច្រើនបានផុសឡើង សម្រាប់រដូវទាំងពីរ។ ពូជស្រូវអាចបែងចែកជាប្រភេទ ដោយផ្អែកលើរយៈពេលឲ្យផល គឺមាន ស្រូវស្រាល (តិចជាង ៩០ ថ្ងៃ) ស្រូវកណ្ដាល(០៩-១៥០ ថ្ងៃ) និង ស្រូវធ្ងន់ (លើសពី ១៥០ ថ្ងៃ)។ ទី២ គេអាចបែងចែកវាជា ពូជស្រូវក្រអូប(មានតម្លៃខ្ពស់[1]) និងពូជស្រូវមិនក្រអូប(តម្លៃទាប)។ជាទូទៅពូជស្រូវក្រអូបត្រូវមានរយៈពេលដុះលូតលាស់យូរជាងពូជមិនក្រអូប។ ជាធម្មតាស្រូវក្រអូប ជាពូជស្រូវកណ្ដាល ឬស្រូវធ្ងន់ រីឯស្រូវមិនក្រអូប ជាពូជស្រូវស្រាល។

ពូជស្រូវផ្សេងៗមានដាំនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ក្នុងរដូវទាំងពីរ។ ដោយសារលក្ខខណ្ឌអាកាសធាតុនិងដីកសិករក្នុងតំបន់នេះដាំស្រូវក្រអូបនៅរដូវវស្សា និងស្រូវមិនក្រអូបនៅរដូវប្រាំង។ តាមធម្មតាកសិករហៅស្រូវរបស់គាត់តាមឈ្មោះរដូវ ដូចជា ស្រូវវស្សាសំដៅដល់ស្រូវក្រអូប និង ស្រូវប្រាំងសំដៅដល់ស្រូវមិនក្រអូប។ ដោយសារការផ្លាស់ប្ដូរក្នុងតម្រូវការ កសិករមាននិន្នាការថ្មីមួយ គឺ ដាំស្រូវមិនក្រអូប (ភាគច្រើនពូជ IR) ក្នុងរដូវវស្សាផងដែរ។

ផ្អែកលើការពិភាក្សាតាមក្រុមស្នូល (FGDs) ក្នុងខេត្តទាំងបី កសិករតែងដាំស្រូវប្រាំង ឬស្រូវ IR សម្រាប់លក់និងដាំស្រូវវស្សាសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ កសិករខ្លះក៏មានលក់ស្រូវវស្សារបស់ខ្លួនដែរ ប៉ុន្តែក្នុងចំនួនភាគរយយ៉ាងតូច។ នៅរដូវប្រាំង កសិករដាំដុះស្រូវពូជ IR ជាសំខាន់ ហើយពួកគាត់ភាគច្រើនដាំស្រូវ IR504 ដែលជាពូជស្រូវស្រាល។ យោងតាម FGDs ស្រូវនេះត្រូវមានការប្រើធាតុចូលច្រើនណាស់ ដូចជា ជីគីមី ថ្នាំសម្លាប់សត្វចង្រៃ ហើយកសិករត្រូវទៅស្រែជាញឹកញាប់ដើម្បីដាក់វា។ កសិករម្នាក់បានប្រាប់ថា ពួកគាត់ត្រូវបាញ់ថ្នាំសម្លាប់សត្វចង្រៃ[2] ជារៀងរាល់បី ឬបួនថ្ងៃម្ដង។

ការពិភាក្សា FGDs បានឲ្យដឹងថា ទោះបីជាស្រូវ IR504 ទាមទារការប្រឹងប្រែងច្រើនក្ដី ប៉ុន្តែកសិករក្នុងខេត្តទាំងបីចូលចិត្តដាំពូជស្រូវស្រាលនេះ (សូម្បីក្នុងរដូវវស្សា) ដោយសារហេតុផលជាច្រើន។ ទី១ វាមានទិន្នផលខ្ពស់ណាស់ (ប្រមាណ ៥ តោន/ហិកតា) បើធៀបនឹងពូជស្រូវផ្សេង (ប្រមាណ ២,៥ តោន/ហិកតា) ជាពិសេស ស្រូវក្រអូប។ ទី២ តម្រូវការស្រូវ IR504 មានស្ថិរភាពជាងស្រូវដទៃ។ ថ្វីបើថ្លៃវាអាចឡើងចុះបន្តិចដែរទៅតាមរដូវ ប៉ុន្តែវាមានតម្រូវការជានិច្ចពីវៀតណាម។ កសិករនានាលើកថា ទោះបីលក់បានថ្លៃទាបក្ដី ប៉ុន្តែស្រូវនេះមានទិន្នផលខ្ពស់ អាចផ្ដល់ប្រាក់ចំណូលបានប្រសើរជាងពូជស្រូវផ្សេង។ ទី៣ កសិករកម្ពុជាដាំស្រូវ IR504 ដោយខ្ចីជីនិងថ្នាំសម្លាប់សត្វចង្រៃពីឈ្មួញវៀតណាម ហើយសន្យាថា នឹងលក់ផលស្រូវប្រមូលបានទៅឲ្យឈ្មួញនោះវិញដើម្បីសងបំណុល។ ឈ្មួញវៀតណាមយកការប្រាក់រហូតដល់ ២% ក្នុងមួយខែ។ ជីនិងថ្នាំសម្លាប់សត្វចង្រៃភាគច្រើនដែលប្រើនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា សុទ្ធតែនាំចូលពីវៀតណាម។

ថ្វីបើមានតម្រូវការខ្ពស់ពីវៀតណាម ប៉ុន្តែកសិករនៅភាគអាគ្នេយ៍ប្រាប់ថា គាត់រកចំណូលបានតិចតួចណាស់ពីស្រូវ។ អ្នកខ្លះនិយាយថា គាត់ដាំដុះវាសម្រាប់តែការប្រើប្រាស់ក្នុងគ្រួសារប៉ុណ្ណោះ ព្រោះមានជំនាញធ្វើស្រែតាំងពីដូនតាមក។ ក្រៅពីការដាំស្រូវ គាត់អាចរកបានការងារសំណង់ ការងាររោងចក្រ ទៅរត់ម៉ូតូឌុប ឬធ្វើចំណាកស្រុកទៅភ្នំពេញ ឬប្រទេសក្រៅ ហើយមានអ្នកខ្លះទៅកាប់ឈើ ឬនេសាទត្រី។

1 ស្រូវដំណើបត្រូវបានចាត់ចូលក្នុងប្រភេទស្រូវមានតម្លៃខ្ពស់ នៅក្នុងការសិក្សានេះ។

2 បរិមាណជី និងថ្នាំសម្លាប់សត្វចង្រៃ ត្រូវប្រើក្នុងការដាំស្រូវ IR504 មានរៀបរាប់លំអិតក្នុងផ្នែកបន្ទាប់នេះ។

កសិករនៅខេត្តភាគអាគ្នេយ៍បានលើកថា ជីវភាពគាត់នឹងត្រូវប៉ះពាល់ធ្ងន់ធ្ងរ បើសិនវៀតណាមឈប់ទិញស្រូវ ហើយគ្មានទីផ្សារផ្សេងសម្រាប់ជំនួស។ ប៉ុន្តែគាត់នៅតែបន្តដាំស្រូវ យ៉ាងហោចណាស់ក៏សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារដែរ។ ជាជម្រើសផ្សេង គាត់អាចធ្វើចំណាកស្រុកទៅធ្វើការក្នុងរោងចក្រ ឬរកការងារនៅក្នុងភូមិដូចជាការងារកសិកម្ម ឬការចិញ្ចឹមសត្វ ជាដើម។ គាត់បាននិយាយគួរឲ្យចាប់អារម្មណ៍ថា ផ្អែកតាមស្ថានភាពនិងដីជាតិដីនាបច្ចុប្បន្ន គាត់អាចផ្លាស់ប្តូរទៅដាំស្រូវក្រអូបបាន បើសិនវាមានទីផ្សារប្រកបដោយសុវត្ថិភាព។ "យើងអាចផ្លាស់ប្តូរ និងសម្របផលិតកម្មរបស់យើងទៅដាំពូជស្រូវណាក៏បាន ឲ្យតែមានទីផ្សារប្រកបដោយសុវត្ថិភាព" បើតាមសំដីកសិករជាច្រើននាក់នៅក្នុង FGDs។

## *តម្រូវការអង្ករនៅបណ្តាខេត្តភាគអាគ្នេយ៍ប្រទេសកម្ពុជា*

រូបភាព១៤ បង្ហាញពីលំហូរស្រូវ ដោយផ្អែកលើ KIIs និង FGDs។ លំហូរនេះស្រដៀងគ្នានឹង ខ្សែសង្វាក់តម្លៃអង្ករធម្មតាដែរ ប៉ុន្តែមានវាលក្ខណៈពិសេសខ្លះ។ ស្រូវវស្សាផលិតបានក្នុងតំបន់នេះ ភាគច្រើនគេលក់ទៅឲ្យរោងម៉ាស៊ីនកិនស្រូវក្នុងមូលដ្ឋាន ហើយបន្ទាប់ពីកិនរួច គេនាំចេញទៅប្រទេសផ្សេងៗក្រៅពីវៀតណាម និងថៃ ឬលក់សម្រាប់ការប្រើប្រាស់ក្នុងស្រុក។ ឈ្មួញវៀតណាមក៏ទិញស្រូវអង្ករវស្សាដែរ (ភាគច្រើនជាស្រូវ) ប៉ុន្តែក្នុងចំនួនតិច បើធៀបនឹងតម្រូវការស្រូវប្រាំងរបស់ពួកគេ។ ដើម្បីសម្រួលការជួញដូរ និងកាត់បន្ថយចំណាយលើការប្រមូលស្រូវ ឈ្មួញវៀតណាមតាមធម្មតាទិញតាមរយៈឈ្មួញកម្ពុជា។ ក្នុងករណីខ្លះ ជាពិសេសនៅតាមព្រំដែន ឈ្មួញវៀតណាមចូលមកកម្ពុជា ហើយទិញស្រូវដោយផ្ទាល់ពីកសិករ។

ឈ្មួញវៀតណាមចូលចិត្តទិញស្រូវសើម ជាជាងស្រូវស្ងួត ដូច្នេះកសិករកម្ពុជាតែងលក់ស្រូវរបស់គាត់ភ្លាមៗ បន្ទាប់ពីប្រមូលផលរួច។ ពួកឈ្មួញនិយាយថា ការហាលស្រូវដោយពន្លឺថ្ងៃមិនអាចទុកចិត្តបានទេ អាចនាំឲ្យស្រូវចុះគុណភាពនិងចោទបញ្ហាដល់ការស្តុកទុកដាក់។ ដំណើរការកែច្នៃនៅវៀតណាម (ហាល និងកិន) មានលក្ខណៈទំនើប និងថោកជាងនៅកម្ពុជា ដោយសារអគ្គិសនីថោកជាង ហើយហេដ្ឋារចនាសម្ព័ន្ធក៏ល្អជាង។ ចំណុចសំខាន់មួយទៀត គឺកសិករកម្ពុជាប្រមូលផលដោយប្រើម៉ាស៊ីន។ ពួកគាត់និយាយថា "យើងមិនអាចហាលស្រូវដោយពន្លឺថ្ងៃទៀតទេ ព្រោះយើងច្រូតកាត់ដោយប្រើម៉ាស៊ីន ហើយត្រូវចំណាយតែមួយថ្ងៃឬពីរថ្ងៃប៉ុណ្ណោះអាចប្រមូលផលស្រូវបានទាំងអស់ ដូច្នេះមិនមានកន្លែងគ្រប់គ្រាន់សម្រាប់ហាលស្រូវទេ រីឯអាកាសធាតុទៀតសោតក៏ប្រែប្រួលមិនទៀងទាត់ដែរ"។ ដូច្នេះទាំងឈ្មួញវៀតណាម និងកសិករកម្ពុជា តែងចូលចិត្តជួញដូរស្រូវសើមជាង។

ការពិភាក្សា KIIs ជាមួយឈ្មួញ និងរោងម៉ាស៊ីនកិនស្រូវ ផ្តល់លទ្ធផលគួរឲ្យចាប់អារម្មណ៍ថា ទីផ្សារចុងក្រោយនៃស្រូវប្រាំង ឬស្រូវ IR504 គឺ វៀតណាម។ វៀតណាមកំណត់ថ្លៃសម្រាប់ស្រូវនេះ នៅក្នុងខេត្តទាំងបី ពោលគឺ ឈ្មួញវៀតណាមកំណត់ថ្លៃមួយឲ្យឈ្មួញកម្ពុជា បន្ទាប់មកឈ្មួញកម្ពុជាកំណត់ថ្លៃកាន់តែទាបឲ្យកសិករនៅតាមភូមិ។ តាមធម្មតាក្នុងភូមិនីមួយៗមានឈ្មួញពីរបីនាក់ដែរ ប៉ុន្តែគេឲ្យថ្លៃសឹងតែដូចគ្នា គឺ "ពួកគេឃុបឃិតគ្នាកំណត់ថ្លៃស្រូវ" បើតាមសំដីរបស់កសិករម្នាក់ក្នុង FGD មួយ។ កសិករខ្លះនិយាយថា គាត់សប្បាយចិត្តបើសិនមានឈ្មួញវៀតណាមកាន់តែច្រើនចូលមកក្នុងភូមិដើម្បីប្រមូលស្រូវ ព្រោះវាអាចបង្កើនការប្រកួតប្រជែង។ ក្នុងភូមិ មិនមានសហករណ៍ ឬសមាគមកសិករសម្រាប់ជួយកសិករក្នុងការចរចាថ្លៃទេ។ កសិករលក់ស្រូវគាត់តែរៀងៗខ្លួន ដោយមានការពិភាក្សាខ្លះៗជាមួយអ្នកជិតខាងប៉ុណ្ណោះ។

ឈ្មួញស្រូវអង្ករបានឆ្លើយសម្ភាសន៍ប្រាប់ថា ចំនួនឈ្មួញក្នុងមូលដ្ឋានបានកើនឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗ ធ្វើឲ្យជំនួញរបស់គាត់មានការលំបាក និងថយចុះអត្រាចំណេញ។ ស្រូវ IR បានថ្លៃប្រមាណ ០,១៧ ទៅ ០,២០ ដុល្លារ/គ.ក រីឯស្រូវក្រអូបបានថ្លៃ ០,២០ ទៅ ០,២៥ដុល្លារ។ ពួកគាត់អះអាងថា ទំហំជួញដូររបស់ខ្លួន (ជាពិសេសស្រូវ IR504) ជាមួយវៀតណាម កើនឡើងជារៀងរាល់ឆ្នាំ។ អត្រាចំណេញសម្រាប់ស្រូវ IR504 និងស្រូវក្រអូប ប្រហាក់ប្រហែលគ្នាណាស់ ប៉ុន្តែទីផ្សារសម្រាប់ស្រូវ IR504 វាធំជាង និងងាយស្រួលជាង។ ឈ្មួញក៏បានលើកពីការលំបាកជាច្រើនក្នុងការជួញដូរដែរ ដូចជា ការហាមឃាត់របស់អាជ្ញាធរមូលដ្ឋានលើការដឹកជញ្ជូន ផ្លូវពិបាក ប្រាក់កម្រៃក្រៅផ្លូវការ និងការប្រែប្រួលអាកាសធាតុ។

រូបភាព១៤៖ លំហូរស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា




ប្រភព៖ អ្នកនិពន្ធរៀបចំឡើង ដោយផ្អែកលើការសង្កេតដល់កន្លែង

ឈ្មួញឆ្លើយសម្ភាសន៍បានបញ្ជាក់ថា ឈ្មួញវៀតណាមមកទិញស្រូវពីកម្ពុជា ដោយសារហេតុផលសំខាន់ៗបី៖ ទី១ អង្ករកម្ពុជាថោកជាងអង្ករវៀតណាម ដូច្នេះនៅសល់ចំណេញខ្លះក្រោយទូទាត់ចំណាយអស់ហើយ។ ទី២ ស្រូវកម្ពុជាជាពិសេសស្រូវ IR504 មានការប្រើជីគីមីនិងថ្នាំសម្លាប់សត្វចង្រៃតិចជាងស្រូវវៀតណាម។ ទី៣ វៀតណាមត្រួតត្រាលើទីផ្សារអង្ករមានតម្លៃទាប ដូច្នេះត្រូវការអង្ករច្រើនណាស់ដើម្បីបំពេញតាមតម្រូវការទីផ្សារ។

រោងម៉ាស៊ីនកិនស្រូវក្នុងមូលដ្ឋានបានបញ្ជាក់ថា ពួកគេមិនមានសមត្ថភាពស្រូបយកស្រូវនៅសល់បានទេ បើសិនវៀតណាមឈប់ទិញស្រូវ។ តាមការប៉ាន់ស្មាន សមត្ថភាពកិនស្រូវ[3] ក្នុងខេត្តទាំងបីនាបច្ចុប្បន្ន មានត្រឹមប្រមាណ ៥% នៃផលិតកម្មស្រូវសរុបប៉ុណ្ណោះ។ ពួកគេត្រូវការទុនបន្ថែម និងទីផ្សារអន្តរជាតិមានស្ថិរភាព ដើម្បីបង្កើនការទិញ និងសមត្ថភាពកិនស្រូវ។ គ្រប់រោងម៉ាស៊ីនកិនស្រូវឆ្លើយសម្ភាសន៍ បានខ្ចីប្រាក់ពីស្ថាប័នហិរញ្ញវត្ថុ ក្នុងកម្រិតពី ២០ ទៅ ៧០% នៃទុនបង្វិលរបស់ខ្លួន ដោយត្រូវបង់ការប្រាក់ជាមធ្យមប្រមាណ ១% ក្នុងមួយខែ។ ពួកគេសម្ងួត និងកិនស្រូវជាសំខាន់សម្រាប់ការនាំចេញ។អង្ករប្រមាណ ៧០ ទៅ ៨០% បានលក់ទៅឲ្យក្រុមហ៊ុននាំចេញ និងប្រមាណ ២០% សម្រាប់ការជួញដូរក្នុងស្រុក។ ពួកគេបានរៀបរាប់ពីការលំបាករបស់ខ្លួនថាមានជាអាទិ កង្វះទុនបង្វិល អត្រាការប្រាក់ខ្ពស់ ការបញ្ជាទិញមិនទៀងទាត់ ការបង់ប្រាក់ក្រៅផ្លូវការ ថ្លៃថាមពលខ្ពស់ និងកង្វះកម្លាំងពលកម្ម។

## ៥.៤ គោលនយោបាយស្រូវនៅកម្ពុជា

របៀបវារៈអភិវឌ្ឍន៍សំខាន់របស់រដ្ឋាភិបាលកម្ពុជា មានចែងក្នុង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ (RS-III) និងមាន ជាអាទិ៍ ការកែលំអកសិកម្មដើម្បីពង្រឹងនិងពង្រីកមូលដ្ឋានគ្រឹះសម្រាប់កំណើនសេដ្ឋកិច្ច ការពន្លឿនការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់កម្រិតជីវភាព (RGC 2013)។ កសិកម្មដើរតួនាទីសំខាន់ក្នុងការទ្រទ្រង់កំណើនសេដ្ឋកិច្ច ធានាឲ្យមានសមធម៌និងសន្តិសុខស្បៀង និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនៅជនបទ។ ក្រសួងកសិកម្ម បានអនុម័ត "ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្មឆ្នាំ២០១៤-២០១៨" ដែលមានយុទ្ធសាស្ត្របីមុខព្រួញ គឺ ១)ការបង្កើនផលិតភាព កាធ្វើពិពិធកម្ម និងការធ្វើពាណិជ្ជកម្មផ្នែកកសិកម្ម តាមរយៈវិធានការជាប់ទាក់ទងគ្នាចុះឡើង ដូចជា ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធ និងបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ជាដើម ២)ការផ្តល់សេវាផ្សព្វផ្សាយកសិកម្មកាន់តែបានល្អ ៣)ការកែលំអធាតុចូលកសិកម្ម កំណែទម្រង់ការគ្រប់គ្រងដីធ្លី ហិរញ្ញវត្ថុ ការផ្សព្វផ្សាយទីផ្សារ អង្គការកសិករ និងការកសាងនិងសម្រួបសម្រួលផ្នែកស្ថាប័ន (MAFF 2015c)។

3 ផ្អែកតាមការឆ្លើយសម្ភាសន៍របស់រោងម៉ាស៊ីនកិនស្រូវនៅតាមមូលដ្ឋាន ក្នុងខេត្តបានសិក្សាទាំងបី។

នៅឆ្នាំ២០១០ រដ្ឋាភិបាលបានដាក់អនុវត្តគោលនយោបាយសម្រាប់ជំរុញផលិតកម្មនិងការនាំចេញអង្ករ ដោយបានចេញវិធានការផ្តែកគោលនយោបាយសំខាន់ៗសម្រាប់ដំណាក់កាលនីមួយៗ រួមមាន ១)ផលិតកម្មស្រូវ ២)ការប្រមូល និងកែច្នៃស្រូវ ៣)ឡូជីស្ទិក និង ៤)ការផ្សព្វផ្សាយទីផ្សារ (SNEC 2010)។ ក្រសួងកសិកម្មបានធ្វើផែនការអនុវត្តយ៉ាងលំអិតមួយ ដើម្បីបង្កើនសេវាគាំទ្រ និងអន្តរាគមន៍ផ្សេងៗ ដូចជា ការផ្ទេរបច្ចេកវិទ្យានិងបច្ចេកទេសសមស្របទៅឲ្យកសិករ និងការប្រឹងប្រែងស្រាវជ្រាវបង្កើតពូជស្រូវដើម្បីធានាឲ្យវាកាន់តែសមស្របទៅនឹងលក្ខណៈដីនិងអាកាសធាតុ និងតម្រូវការទីផ្សារ។ គោលនយោបាយស្រូវដែលទើបរៀបចំឡើងវិញបានរួចរាល់នេះបញ្ជាក់ថា វិស័យស្រូវអង្ករកម្ពុជានៅខ្សោយណាស់ក្នុងការប្រកួតប្រជែងនៅអន្តរជាតិ និងមិនទាន់អាចបង្កើនផលិតភាព និងប្រាក់ចំណូលរបស់កសិករឲ្យបានជាទូទៅទេ។ ជាលទ្ធផល គោលនយោបាយស្រូវអង្ករថ្មីមួយត្រូវបានបង្កើតឡើង ដើម្បីកសាងបន្តលើលទ្ធផលសម្រេចបានដោយគោលនយោបាយស្រូវឆ្នាំ២០១០ សំដៅជួយឲ្យវិស័យស្រូវអង្ករនៅកម្ពុជាក្លាយជាអ្នកនាំមុខគេមួយក្នុងជំនួញអង្ករសកល និងជាប្រភពអាចទុកចិត្តបាននៃសន្តិសុខស្បៀង និងប្រាក់ចំណូលរបស់កសិករ។ គោលនយោបាយស្រូវថ្មីនេះ[4] ផ្អែកលើគោលការណ៍សំខាន់ៗដែលត្រូវមាន ការចូលរួម តម្លាភាព សមត្ថភាពប្រកួតប្រជែង និងចីរភាព។ គោលនយោបាយថ្មីសំដៅ គ្របដណ្តប់លើគ្រប់ទិដ្ឋភាព ដូចជា ការកែលំអផលិតកម្មតាមរយៈនវានុវត្តន៍ និងវិនិយោគមានអត្រាចំណេញធៀបនឹងចំណាយកម្រិតខ្ពស់ ការយល់ដឹងកាន់តែប្រសើរពីតម្រូវការ និងបរិយាកាសប្រកួតប្រជែង ការសម្របសម្រួលកាន់តែល្អក្នុងចំណោមអ្នកពាក់ព័ន្ធ ការមើលឃើញធំទូលាយ និងមានចក្ខុវិស័យច្បាស់ពីផ្លូវឈានទៅមុខ (ខ្លឹមសារលំអិតនៃគោនយោបាយស្រូវថ្មី មានចុះក្នុង ឧបសម្ព័ន្ធ៣)។

ក្រសួងកសិកម្មបានដឹងថាប្រព័ន្ធផ្សព្វផ្សាយកសិកម្មបច្ចុប្បន្នដែលផ្តោតភាគច្រើនលើស្រូវកំពុងជួបបញ្ហាជាច្រើន ដូចជា ការគាំទ្រនិងបទបញ្ញត្តិច្បាប់នៅមានកម្រិត និង កង្វះធនធានមនុស្ស មូលនិធិ បច្ចេកវិទ្យាថ្មីនិងសមស្រប សម្ភារសម្រាប់ធ្វើការផ្សព្វផ្សាយ និងជំនាញសម្របសម្រួល។ សកម្មភាពផ្សព្វផ្សាយដើរតួនាទីសំខាន់ក្នុងគោលនយោបាយរបស់រដ្ឋាភិបាល និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍកសិកម្ម។ ដើម្បីធ្វើទំនើបកម្ម និងលើកកម្ពស់ការធ្វើពាណិជ្ជកម្មក្រសួងកសិកម្មបានកសាងគោលនយោបាយផ្សព្វផ្សាយកសិកម្មមួយដើម្បីផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យា ទៅឲ្យកសិករ និងសហគមន៍ធ្វើកសិកម្ម និងតភ្ជាប់ពួកគេទៅនឹងទីផ្សារ។ គោលនយោបាយនេះចាំបាច់បំផុតសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយកសិកម្ម។ វាជាមូលដ្ឋានគ្រឹះ និងជាសេចក្តីណែនាំសម្រាប់ការផ្តល់សេវាផ្សព្វផ្សាយប្រកបដោយប្រសិទ្ធភាពដល់កសិករ (MAFF2015a)។

ការសិក្សានេះបានធ្វើ KIIs ជាមួយមន្ទីរជំនាញខេត្តសំខាន់ៗពីរ (កសិកម្ម និង ពាណិជ្ជកម្ម) ហើយនៅក្នុងកម្រងសំណួរអង្កេតគ្រួសារ មាននូវ ផ្នែកមួយស្តីពីសេវាផ្សព្វផ្សាយដែលកសិករបានទទួល ។ យោងតាមអ្នកផ្តល់ព័ត៌មានគន្លឹះមន្ទីរកសិកម្មខេត្តមានកម្មវិធីជាច្រើន ដូចជា ការបង្កើនផលិតកម្ម ការជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងការបណ្តុះបណ្តាលពីពូជស្រូវនិងដំណាំផ្សេងទៀត ការចិញ្ចឹមសត្វ និងខ្សែសង្វាក់តម្លៃផ្អែកកសិកម្ម។ ការផ្តល់សេវាផ្សព្វផ្សាយ កម្ចី និងអំណោយដល់កសិករ សុទ្ធតែជាសកម្មភាពចម្បងៗសម្រាប់ការអភិវឌ្ឍដំណាំរបស់មន្ទីរកសិកម្មខេត្ត។ ទោះជាយ៉ាងនេះក្តី មន្ត្រីឆ្លើយសម្ភាសន៍បានទទួលស្គាល់ថា សកម្មភាពរបស់មន្ទីរមិនបានគ្របដណ្តប់ដល់គ្រប់ភូមិក្នុងខេត្តរបស់ខ្លួនទេ ព្រោះហិរញ្ញវត្ថុនិងធនធានមនុស្សនៅមានកម្រិត។ អង្គការមិនមែនរដ្ឋាភិបាល(NGOs) វិស័យឯកជន និងដៃគូអភិវឌ្ឍនានា ក៏មានធ្វើសកម្មភាពផ្សព្វផ្សាយជាច្រើនដែរ។

រូបភាព១៥ បង្ហាញថា រហូតដល់ ៩០% នៃគ្រួសារបានធ្វើអង្កេតក្នុងខេត្តទាំងបី ធ្លាប់បានទទួលសេវាផ្សព្វផ្សាយយ៉ាងហោចណាស់ក៏ម្តងដែរ។ គ្រួសារប្រមាណ ១៧% បានទទួលសេវាផ្សព្វផ្សាយពីមន្ទីរជំនាញខេត្ត ប៉ុន្តែភាគច្រើន (៥៤,៥%) បានទទួលពី NGOs និងមានត្រឹមតែ ៦% ប៉ុណ្ណោះដែលបានទទួលពីឈ្មួញស្រូវ។

4 គោលនយោបាយនេះបានតាក់តែងឡើងនៅចុងឆ្នាំ២០១៦ និងអនុម័តចេញក្នុងឆ្នាំ២០១៧

ការគ្រប់គ្រងទឹក ជំងឺ និងសត្វចង្រៃ ជាសេវាផ្សព្វផ្សាយចម្បងៗផ្តល់ដោយ NGOs បើតាមគ្រួសារកសិកររាយការណ៍ប្រាប់ គឺជាសេវាផ្សព្វផ្សាយផ្តល់ដោយ NGOs ហើយសេវាផ្សព្វផ្សាយចម្បងៗផ្តល់ដោយមន្ទីរកសិកម្មខេត្ត រួមមាន ការគ្រប់គ្រងជំងឺនិងសត្វចង្រៃ ការដាក់ជីគីមី និងការជ្រើសរើសស្រូវពូជ (តារាងA5 ក្នុងឧបសម្ព័ន្ធ៣)។

រូបភាព១៥៖ គ្រួសារទទួលបានសេវាផ្សព្វផ្សាយយ៉ាងហោចណាស់ម្តង (%)




រូបភាព១៦៖ អ្នកផ្តល់សេវាផ្សព្វផ្សាយ (%)




យោងតាមមន្ទីរកសិកម្មខេត្ត មានពូជស្រូវ ១០ មុខដែលក្រសួងកសិកម្មចង់ផ្សព្វផ្សាយ ក្នុងនេះ ស្រូវស្រាល រួមមាន សែនពិដោរ IR66 និង ជលសា ស្រូវកណ្តាល រួមមាន ផ្ការំដួល ផ្ការមៀត ផ្ការំដេង និង ផ្កាចាន់សែនសរ ស្រូវធ្ងន់ រួមមាន ខា៤ ខា៦ និង រាំងជ័យ។

ក្នុងការអនុវត្តជាក់ស្តែង កសិករដាំស្រូវ IR504 ដោយផ្អែកលើតម្រូវការពីវៀតណាម។ វាជាស្រូវស្រាល អាចដាំបានគ្រប់រដូវនិងមានទិន្នផលខ្ពស់។មន្ត្រីមន្ទីរកសិកម្មខេត្តបាននិយាយថា"វាអាស្រ័យលើទីផ្សារ។យើងមិនអាចបង្ខំឲ្យគេដាំពូជស្រូវតាមការណែនាំរបស់ក្រសួងបានទេ ព្រោះយើងមិនអាចធានាទិញផលស្រូវរបស់គេបាន។ សព្វថ្ងៃកសិកម្មកំពុងជួបបញ្ហាប្រែប្រួលអាកាសធាតុ ដែលមន្ទីរកសិកម្មមិនអាចពិនិត្យតាមដានបានទាំងស្រុងទេ។ ដូច្នេះ កសិករគួរផ្លាស់ប្តូរផលិតកម្មរបស់ខ្លួនចេញពី ស្រូវ IR504 ទៅផលិតស្រូវអង្ករមានគុណភាពខ្ពស់ដែលរដ្ឋាភិបាលបានណែនាំនោះវិញ។ រដ្ឋាភិបាលបាននិងកំពុងស្វែងរកទីផ្សារសម្រាប់ស្រូវអង្ករប្រភេទនេះនៅប្រទេស ចិន និង ម៉ាឡេស៊ី"។

ដោយផ្អែកលើKIIsមន្ត្រីមកពីមន្ទីរពាណិជ្ជកម្មខេត្តបាននិយាយថាមន្ទីរមិនមានកម្មវិធីឬគម្រោងជាក់លាក់អ្វីដើម្បីផ្សព្វផ្សាយទីផ្សារសម្រាប់អង្ករទេ។ គោលនយោបាយ និងសកម្មភាពបច្ចុប្បន្ន តែងតែផ្តោតលើផលិតផលកសិកម្មគ្រប់មុខ។ សកម្មភាពចម្បងៗធ្លាប់បានធ្វើកន្លងមក រួមមាន ការរៀបចំតាំងពិពណ៌ផលិតផលកសិកម្មនៅរាជធានីភ្នំពេញ ឬការចូលរួមក្នុងការតាំងពិពណ៌នៅក្រៅប្រទេស។

# ៦. លទ្ធផលរកឃើញសំខាន់ៗតាមវិធីសាស្ត្របែបបរិមាណវិស័យ

កម្រងសំណួរអង្កេតគ្រួសារ មានគោលដៅចម្បងដើម្បី វិភាគពីស្ថានភាពជីវភាពកសិករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា។ ឆ្លងតាមកម្រងសំណួរនេះ ក្រុមស្រាវជ្រាវក៏អាចប្រៀបធៀបពី ចំណាយ និងផលចំណេញនៃពូជស្រូវខុសៗគ្នាដែរ។

ដើម្បីប្រៀបធៀបជីវភាពគ្រួសារ ក្រុមស្រាវជ្រាវបានបែងចែកគ្រួសារដោយផ្អែកតាមប្រភេទស្រូវដែលពួកគេកំពុងដាំ គឺមានគ្រួសារ ដាំតែស្រូវវស្សា ដាំតែស្រូវប្រាំង ឬ ដាំស្រូវទាំងពីរប្រភេទ។ ការបែងចែកនេះ ផ្អែកតាមពូជស្រូវ ដោយមិនគិតពីរដូវទេ។

ពាក្យ "ស្រូវវស្សា" និង "ស្រូវប្រាំង" ដែលកសិករប្រើជាទូទៅ និងជាធម្មតាក្នុងតំបន់ធ្វើអង្កេត សំដៅដល់ពូជស្រូវខុសៗគ្នា។ ស្រូវវស្សាសំដៅដល់ ពូជស្រូវណាដែលមានការលូតលាស់ផ្សារភ្ជាប់នឹងរយៈពេលមានពន្លឺថ្ងៃ និងលក្ខខណ្ឌផ្សេងទៀតនៃការដាំដុះ។ស្រូវទាំងនេះភាគច្រើនជាពូជស្រូវក្រអូប ឬស្រូវលេខ១។ស្រូវប្រាំងមានការលូតលាស់មិនផ្សារភ្ជាប់នឹងរយៈពេលមានពន្លឺថ្ងៃទេ ប៉ុន្តែត្រូវមានការស្រោចស្រព (CARDI 2011)។ ស្រូវប្រាំងអាចដាំក្នុងរដូវប្រាំងក៏បាន ក្នុងរដូវវស្សាក៏បាន ឲ្យតែមានប្រព័ន្ធស្រោចស្រពគ្រប់គ្រាន់។

ការសិក្សានេះក៏បានធ្វើវិភាគពីចំណាយ និងផលចំណេញនៃពូជស្រូវផ្សេងៗដែលគេបែងចែកប្រភេទវាទៅតាមតាមរយៈពេលដាំដុះ គឺមាន ស្រូវស្រាល ស្រូវកណ្ដាល និង ស្រូវធ្ងន់ ។ សូចនាករផ្សេងៗ ដូចជា ទិន្នផល បន្ទុកចំណាយ និងប្រាក់ចំណូល ត្រូវបានបង្កើតឡើងសម្រាប់ធ្វើការប្រៀបធៀប។ ដោយសារកសិករភាគច្រើននៅក្នុងតំបន់ធ្វើអង្កេតគាត់ដាំស្រូវ IR504 ជាសំខាន់នោះ ការសិក្សាក៏មានបំណងផ្ដោតលើស្រូវនេះដែរ។ ក្រុមស្រាវជ្រាវបានញែកស្រូវ IR504 ពីស្រូវស្រាលផ្សេងទៀត និងប្រៀបធៀបវាជាមួយស្រូវកណ្ដាល និងស្រូវធ្ងន់ ដើម្បីគណនាថាមួយណាផ្ដល់ផលចំណេញច្រើនជាងដល់កសិករ។

## ៦.១ លក្ខណៈនៃសំណាក

ផ្នែកនេះពិពណ៌នាពីលក្ខណៈនៃខេត្តបានចុះសិក្សា ភូមិជ្រើសរើស ស្ថានភាពក្រីក្ររបស់អ្នកភូមិ និងចំនួនផលស្រូវក្នុងមួយឆ្នាំ។ ការសិក្សាបានធ្វើឡើងនៅខេត្ត ព្រៃវែង ស្វាយរៀង និង តាកែវ ដោយមានសរុប ៦០០គ្រួសារសំណាក ឬ ២០០គ្រួសារក្នុងខេត្តនីមួយៗ។ ភូមិជ្រើសរើស ចែកចេញជា ៣ ក្រុម៖ ភូមិដាំតែស្រូវវស្សា និង ភូមិដាំតែស្រូវប្រាំង និង ភូមិដាំស្រូវវស្សាផងស្រូវប្រាំងវស្សាផង។ តារាង៤ បានបង្ហាញថា ៨០% នៃគ្រួសារសំណាកស្ថិតក្នុងភូមិស្រូវប្រាំង និង ២០% ស្ថិតក្នុងភូមិស្រូវវស្សា។ ក្នុងចំណោមគ្រួសារដាំស្រូវតាមខេត្តនីមួយៗ គ្រួសារដាំតែស្រូវប្រាំងគឺ នៅខេត្តព្រៃវែងមាន៥០% នៅខេត្តស្វាយរៀងមាន៥៧% និង នៅខេត្តតាកែវមាន៧៨%។

ភាពក្រីក្រអាចសំគាល់បានតាមលក្ខណៈដែលគ្រួសារមាន ឬគ្មានប័ណ្ណក្រីក្រ ហើយតាមនេះគេឃើញថា ៦៧% នៃគ្រួសារ គឺ មិនក្រីក្រទេ។ គួរឲ្យចាប់អារម្មណ៍ដែរដែល តារាង៤ បង្ហាញថា គ្រួសារដាំស្រូវប្រាំងមានជីវភាពប្រសើរជាងគ្រួសារដាំតែស្រូវវស្សា ឬដាំស្រូវទាំងពីរប្រភេទ។

ប្រមាណ ៤៣% នៃគ្រួសារឆ្លើយសម្ភាសន៍ ធ្វើស្រូវតែម្ដងក្នុងមួយឆ្នាំ, ៤១% ធ្វើស្រូវពីរដងក្នុងមួយឆ្នាំ, ១៦% ធ្វើស្រូវបីដងក្នុងមួយឆ្នាំ ហើយចំណុចគួរឲ្យភ្ញាក់ផ្អើល គឺមាន ០,៣% ធ្វើស្រែបានបួនដងក្នុងមួយឆ្នាំ។ ក្នុងចំណោមគ្រួសារឆ្លើយសម្ភាសន៍ មាន ៦២% ធ្វើតែស្រូវប្រាំង ១៩% ធ្វើតែស្រូវវស្សា និង ២០% ធ្វើស្រូវទាំងពីរប្រភេទ។ គ្រួសារដាំតែស្រូវវស្សាធ្វើស្រូវបានតែម្ដងក្នុងមួយឆ្នាំ រីឯគ្រួសារដាំតែស្រូវប្រាំងអាចធ្វើស្រូវបានរហូតដល់បីដង។

តារាង៤៖ ព័ត៌មានលំអិតលើសំណាក (%)

| | | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំទាំងពីរប្រភេទ | សរុប |
|---|---|---|---|---|---|
| ខេត្ត | ព្រៃវែង | 20 | 50 | 30 | 33 |
| | ស្វាយរៀង | 20 | 57 | 23 | 33 |
| | តាកែវ | 16 | 78 | 6 | 33 |
| ភូមិសំណាក | ស្រូវវស្សា | 92 | 0 | 8 | 20 |
| | ស្រូវប្រាំង | 0 | 77 | 23 | 80 |
| ប័ណ្ណក្រីក្រ | មានប័ណ្ណក្រីក្រ | 26 | 62 | 12 | 13 |
| | គ្មានប័ណ្ណក្រីក្រ | 18 | 62 | 21 | 87 |
| ចំនួនដំណាំស្រូវ/ឆ្នាំ | មួយដង | 43 | 53 | 4 | 43 |
| | ពីរដង | 0 | 68 | 32 | 41 |
| | បីដង | 0 | 71 | 29 | 16 |
| | បួនដង | 0 | 0 | 100 | 0.3 |
| **សរុប** | | **19** | **62** | **20** | **100** |

## ៦.២ ព័ត៌មានផ្នែកប្រជាសាស្ត្រ

តារាង៥ បង្ហាញពីលក្ខណៈប្រជាសាស្ត្រនៃគ្រួសារសំណាក។ គ្រួសារមានទំហំជាមធ្យម ៤,៤នាក់។ គ្រួសារដាំទាំងស្រូវប្រាំងនិងស្រូវវស្សា មានទំហំធំបន្តិចជាង គ្រួសារដាំតែស្រូវវស្សា ឬដាំតែស្រូវប្រាំង។ អត្រាសមាជិកគ្រួសារក្នុងបន្ទុក[5] (ចំនួនសមាជិកគ្រួសារអាយុពី ០-១៤ឆ្នាំ និងលើ៦៥ឆ្នាំ ចែកនឹងចំនួនប្រជាជនអាយុពី ១៥-៦៤ឆ្នាំ) ក្នុងចំណោមគ្រួសារធ្វើតែស្រូវវស្សា គឺខ្ពស់ជាង គ្រួសារធ្វើតែស្រូវប្រាំងឬធ្វើស្រូវទាំងពីរប្រភេទ។ គ្រួសារសំណាកភាគច្រើនមានបុរសមេគ្រួសារ។ មេគ្រួសារមានអាយុជាមធ្យមស្ថិតក្នុងចំណោម ប្រជាជនសកម្មក្នុងសេដ្ឋកិច្ច។

តារាង៥៖ ព័ត៌មានទូទៅលើគ្រួសារ (%)

| ព័ត៌មានផ្នែកប្រជាសាស្ត្រ | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | សរុប |
|---|---|---|---|---|
| ទំហំគ្រួសារ (ចំនួនមនុស្ស) | 4.3 | 4.4 | 4.6 | 4.4 |
| អត្រាសមាជិកក្នុងបន្ទុក | 0.66 | 0.61 | 0.61 | 0.62 |
| គ្រួសារមានមេគ្រួសារជាបុរស (%) | 83 | 93.2 | 88.1 | 90.3 |
| អាយុមេគ្រួសារ (ឆ្នាំ) | 53 | 46 | 51 | 48 |
| ចំនួនឆ្នាំសិក្សាអប់រំជាមធ្យមនៃមេគ្រួសារ | 5.5 | 5.5 | 4.9 | 5.3 |

កម្រិតអប់រំរបស់មេគ្រួសារ ជាសូចនាករសំខាន់នៃធនធានមនុស្សក្នុងគ្រួសារ ហើយអាចមានផលប៉ះពាល់ខ្លាំងទៅលើកម្រិតដែលគ្រួសារអាចបំពេញតម្រូវការក្នុងជីវភាពរបស់ខ្លួន និងគ្រប់គ្រងការលំបាក។ មេគ្រួសារបានទៅរៀនសាលាជាមធ្យមចំនួន ៥ ឆ្នាំ។ ដូច្នេះមេគ្រួសារភាគច្រើនបានរៀនត្រឹមតែ បឋមសិក្សាប៉ុណ្ណោះ។ ការសិក្សានេះក៏បានធ្វើចំណាត់ថ្នាក់គ្រួសារសំណាកទៅតាមកម្រិតអប់រំរបស់មេគ្រួសារ ហើយលទ្ធផលបង្ហាញថា ប្រមាណ ៥១,២% នៃមេគ្រួសារបានរៀនចប់បឋមសិក្សា។

5 អត្រាសមាជិកគ្រួសារក្នុងបន្ទុកគឺ ចំនួនសមាជិកគ្រួសារអាយុពី ០-១៤ឆ្នាំ និងលើ ៦៥ឆ្នាំ ចែកនឹងចំនួនប្រជាជនអាយុពី ១៥-៦៤ឆ្នាំ។

តារាង៦៖ កម្រិតអប់រំរបស់មេគ្រួសារ (%)

| កម្រិតអប់រំ | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | សរុប |
|---|---|---|---|---|
| មត្តេយ្យ | 11.6 | 11.1 | 10.2 | 11.0 |
| បឋមសិក្សា (១-៦ឆ្នាំ) | 54.5 | 48.7 | 55.9 | 51.2 |
| អនុវិទ្យាល័យ (៧-៩ឆ្នាំ) | 25.9 | 28.4 | 27.1 | 27.7 |
| វិទ្យាល័យ (១០-១២ឆ្នាំ) | 4.5 | 8.9 | 5.9 | 7.5 |
| សាកលវិទ្យាល័យ | 0.9 | 0.8 | 0.0 | 0.7 |
| ថ្នាក់បណ្តុះបណ្តាលវិជ្ជាជីវៈ | 0.9 | 1.1 | 0.9 | 1.0 |
| ថ្នាក់អក្ខរកម្ម | 1.8 | 1.1 | 0.0 | 1.0 |

ដីជាទ្រព្យមានតម្លៃជាងគេ សម្រាប់ប្រជាជនភាគច្រើនទាំងនៅទីក្រុង និងជនបទ។ គ្រួសារ ជាង ៩៨% បានរាយការណ៍ថា មានដីកសិកម្ម។ គ្រួសារធ្វើតែស្រូវប្រាំង តែងត្រូវការជួលដីបន្ថែមដើម្បីបង្កើនផលិតកម្ម ហើយជាងមួយភាគបួននៃគ្រួសារទាំងនេះបានធ្វើដូច្នេះ។ ប្រមាណ ៤% នៃគ្រួសារក្នុងក្រុមនីមួយៗ បានប្រើប្រាស់ដីដោយគ្មានបង់ថ្លៃ ។

រូបភាព១៧៖ កម្មសិទ្ធិដីគិតតាមភូមិ (%)




រូបភាព១៨៖ មុខរបរចម្បង (%)




ប្រភព៖ អង្កេតគ្រួសារបែបបរិមាណវិស័យក្នុងការស្រាវជ្រាវនេះ

កម្រងសំណួរបានកត់ត្រាទាំងមុខរបរចម្បង និងមុខរបរបន្ទាប់បន្សំផ្សេងៗ របស់មេគ្រួសារ។ រូបភាព២០ បង្ហាញពីមុខរបរចម្បង រីឯ តារាង៧ បង្ហាញពី មុខរបរបន្ទាប់បន្សំ។ មុខរបរចម្បងរបស់ប្រជាជនក្នុងបណ្តាខេត្តនៅភាគអាគ្នេយ៍ គឺការដាំដំណាំ ដោយមាន៦៤%ដាំសម្រាប់គោលដៅពាណិជ្ជកម្ម ១៨%ដាំសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងត្រឹម៦%ដែលមានមុខរបរចម្បងជាការងារក្នុងរោងចក្រកាត់ដេរ ឬការងារពាក់ព័ន្ធជំនួញ។ គ្រួសារភាគច្រើនដែលធ្វើស្រែសម្រាប់តែការប្រើប្រាស់ក្នុងគ្រួសារគាត់ដាំតែស្រូវវស្សាប៉ុណ្ណោះ រីឯគ្រួសារដែលធ្វើស្រែសម្រាប់គោលដៅពាណិជ្ជកម្ម គាត់ដាំតែស្រូវប្រាំង ឬដាំទាំងស្រូវវស្សានិងស្រូវប្រាំង។

តារាង៧៖ មុខរបរបន្ទាប់បន្សំ (%)

| មុខរបរ | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | សរុប |
|---|---|---|---|---|
| ដំណាំសម្រាប់បម្រើទីផ្សារ | 10.0 | 23.1 | 13.5 | 18.8 |
| ពលករផ្នែកកសិកម្ម ព្រៃឈើ និងនេសាទ | 4.3 | 7.0 | 24.4 | 9.5 |
| ពលករផ្នែកយករ៉ែ និងសាងសង់ | 16.4 | 4.9 | 10.9 | 8.3 |
| អ្នកលក់ក្នុងហាង | 5.7 | 7.7 | 3.4 | 6.6 |
| អ្នកនេសាទ អ្នកបរបាញ់ អ្នកដាក់អន្ទាក់ ដើម្បីចិញ្ចឹមពោះ | 3.6 | 7.2 | 4.2 | 6.0 |
| ពលករផ្នែកនេសាទ អ្នកបរបាញ់ | 0.0 | 8.6 | 0.8 | 5.5 |
| កសិករដាំដំណាំដើម្បីចិញ្ចឹមពោះ | 15.0 | 2.3 | 3.4 | 5.1 |
| ការចិញ្ចឹមសត្វ | 5.0 | 5.6 | 0.8 | 4.7 |
| ផលិតករសត្វចិញ្ចឹម | 3.6 | 4.2 | 5.0 | 4.2 |
| ការកែច្នៃស្បៀងអាហារ | 5.0 | 2.8 | 6.7 | 3.9 |
| លក់អាហារតាមដងផ្លូវ | 2.9 | 3.3 | 2.5 | 3.1 |
| ផ្សេងៗ | 28.5 | 23.1 | 24.4 | 24.5 |

ប្រភព៖ អង្កេតគ្រួសារបែបបរិមាណវិស័យក្នុងការស្រាវជ្រាវនេះ

តារាង៨ បង្ហាញពី ការប្រើប្រាស់ស្បៀងអាហារ និងការប្រើប្រាស់មិនមែនស្បៀងអាហារ នៃគ្រួសារក្នុងតំបន់ចុះអង្កេត។ ជាមធ្យម ការប្រើប្រាស់ស្បៀងអាហារ និងការប្រើប្រាស់មិនមែនស្បៀងអាហារ សរុបក្នុងមួយគ្រួសារក្នុងមួយថ្ងៃ មានចំនួន ១០.២ ដុល្លារ។ គ្រួសារធ្វើតែស្រូវវស្សា មានចំណាយតិចជាងគ្រួសារក្នុងក្រុមផ្សេងទៀត។ ចំណុចនេះស្របគ្នានឹងលទ្ធផលរកឃើញថា គ្រួសារធ្វើតែស្រូវវស្សា តែងផលិតស្រូវជាសំខាន់សម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ គ្រួសារដែលធ្វើស្រូវទាំងពីរប្រភេទ មានចំណាយច្រើនជាងគ្រួសារធ្វើតែស្រូវវស្សា ឬធ្វើតែស្រូវប្រាំង។

តារាង៨៖ ការប្រើប្រាស់ស្បៀងអាហារ និងការប្រើប្រាស់មិនមែនស្បៀងអាហារ ក្នុងមួយគ្រួសារ (ដុល្លារ/ថ្ងៃ)

| ការប្រើប្រាស់អាហារ និងរបស់មិនមែនអាហារ | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | សរុប |
|---|---|---|---|---|
| ការប្រើប្រាស់ស្បៀងអាហារប្រចាំថ្ងៃ | 4.8 | 5.4 | 5.7 | 5.3 |
| ការប្រើប្រាស់មិនមែនស្បៀងអាហារប្រចាំថ្ងៃ | 4.1 | 5 | 5.5 | 4.9 |
| សរុបការប្រើប្រាស់ស្បៀងអាហារ និងមិនមែនស្បៀងអាហារក្នុងមួយថ្ងៃ | 8.9 | 10.4 | 11.2 | 10.2 |

ប្រភព៖ អង្កេតគ្រួសារបែបបរិមាណវិស័យក្នុងការស្រាវជ្រាវនេះ

រូបភាព១៩៖ ចំណាយប្រើប្រាស់ក្នុងគ្រួសារ (%)



រូបភាព១៩ បង្ហាញថា ក្នុងចំណាយប្រើប្រាស់សរុប ការប្រើប្រាស់ស្បៀងអាហារ មាន ៤៨% ហើយការប្រើប្រាស់មិនមែនស្បៀងអាហារ មាន ៥២%។ ដូច្នេះ ចំណាយរបស់គ្រួសារជាស្បៀងអាហារ និងមិនមែនជាស្បៀងអាហារ វាសឹងតែដូចគ្នា។

រូបភាព២០៖ ប្រភពប្រាក់ចំណូលគ្រួសារ (%)




## ៦.៣ ប្រភពនៃប្រាក់ចំណូលគ្រួសារ

រូបភាព២០ បង្ហាញពី ចំណែកនៃប្រភពប្រាក់ចំណូលនីមួយៗរបស់គ្រួសារ នៅក្នុងប្រាក់ចំណូលសរុប។ យោងតាមអង្កេតគ្រួសារ ប្រាក់ចំណូលគ្រួសារ មានប្រភពចំណូល ៦ គឺ ការដាំស្រូវ ការដាំបន្លែ របរកសិកម្មផ្សេងទៀត ជំនួញ ការងារយកឈ្នួល និងប្រភពផ្សេងទៀត។ ប្រភពប្រាក់ចំណូលគ្រួសារធំបំផុតគឺ ការងារយកឈ្នួល ហើយបន្ទាប់មកគឺការដាំស្រូវ។ គួរកត់សំគាល់ថា ប្រាក់ចំណូលបានពីការដាំបន្លែ មានមិនដល់ ១% ទេ ហើយតួលេខនេះឆ្លុះបញ្ចាំងពីសមាមាត្រយ៉ាងតូចនៃគ្រួសារដាំបន្លែ។

រូបភាព២១ បែងចែកប្រភពប្រាក់ចំណូលគ្រួសារទៅតាម ប្រភេទគ្រួសារ។ ប្រភពប្រាក់ចំណូលធំបំផុតក្នុងគ្រប់គ្រួសារ គឺការងារយកឈ្នួល ប៉ុន្តែវាចំណែកតូចខ្លាំងណាស់សម្រាប់គ្រួសារធ្វើតែស្រូវប្រាំង បើធៀបនឹងគ្រួសារពីរប្រភេទទៀត។

រូបភាព២១៖ ប្រាក់ចំណូលបែងចែកតាមប្រភេទគ្រួសារ (%)



តារាង៩ បង្ហាញថា គ្រួសាររកចំណូលបានជាមធ្យម ៤៩៧ ដុល្លារ/ឆ្នាំ ពីការដាំស្រូវ។ ប្រភពចំណូលធំជាងគេ គឺការងារយកឈ្នួល ដែលផ្តល់ប្រមាណ ៨៨៣ ដុល្លារក្នុងមួយឆ្នាំ។ គ្រួសាររកចំណូលបានតិចណាស់ពីការដាំបន្លែ។

តារាង៩៖ ប្រាក់ចំណូលគ្រួសារ (ដុល្លារ/ឆ្នាំ)

| ប្រភពប្រាក់ចំណូល | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | មធ្យមភាគ |
|---|---|---|---|---|
| ស្រូវ | 170.4 | 686.9 | 211.3 | 496.9 |
| បន្លែ | 11 | 4.4 | 27.2 | 10.2 |
| របរកសិកម្មផ្សេងទៀត | 248.4 | 305 | 219.9 | 277.7 |
| ផ្សេងៗ | 634.8 | 425.5 | 406.9 | 460.9 |
| ជំនួញ | 321.2 | 383 | 373.2 | 369.5 |
| ការងារយកឈ្នួល | 1152.5 | 770.9 | 980 | 883.2 |

## ៦.៤ ផលិតកម្មបន្លែ និងធាតុចូល

ភាគរយនៃគ្រួសារមានដាំបន្លែប្រភេទណាមួយ មានចុះក្នុង រូបភាព២២ ក្នុងនេះ មានប្រមាណ ៣៧% ដាំបន្លែសម្រាប់ការប្រើប្រាស់ក្នុងផ្ទះ ឬ សម្រាប់ធ្វើពាណិជ្ជកម្ម។

រូបភាព២២៖ គ្រួសារមានដាំបន្លែ (%)




ប្រភេទបន្លែដាំដុះដោយគ្រួសារនៅក្នុងតំបន់សិក្សា មានបង្ហាញក្នុងតារាង១០។ បន្លែភាគច្រើនដាំនៅផ្ទះសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ និងមានគ្រួសារតែប្រមាណ ៤០% ដែលបានលក់បន្លែផ្សេងៗក្នុង ១២ខែកន្លងមក។ គ្រួសារធ្វើតែស្រូវប្រាំងដែលបានលក់បន្លែចេញមានតិចនាក់ជាង បើធៀបនឹងគ្រួសារពីរប្រភេទទៀត (រូបភាព២២)។ ការលក់បន្លែសរុបផ្តល់ជាមធ្យម ២៧,៦ដុល្លារ/ឆ្នាំ ដែលតិចតួចណាស់បើធៀបនឹងចំណូលបានពីដំណាំស្រូវ។ គ្រួសារធ្វើស្រូវទាំងពីរមុខ មានចំណូលបានពីការលក់បន្លែ ច្រើនជាងគ្រួសារធ្វើតែស្រូវវស្សា ឬស្រូវប្រាំង (តារាង១១)។ គ្រួសារលក់បន្លែក៏បានប៉ាន់ស្មានពី ចំណាយសរុបលើធាតុចូលដែរ (តារាង១២) ប៉ុន្តែមិនបានរាយការណ៍សម្រាប់បន្លែប្រើប្រាស់ក្នុងគ្រួសារទេ។ ជាមធ្យមនៅក្នុងតំបន់សិក្សា ចំណាយលើធាតុចូលក្នុងការដាំបន្លែមានប្រមាណ ៨,២ដុល្លារ/ឆ្នាំ រីឯថ្លៃលក់បន្លែបាន គឺ ២៧,៦ដុល្លារ/ឆ្នាំ ដូច្នេះ ប្រាក់ចំណេញមានប្រមាណ ១៩,៤ ដុល្លារ/ឆ្នាំ។ សរុបមកលទ្ធផលរកឃើញបង្ហាញថា គ្រួសារធ្វើតែស្រូវប្រាំងផ្តោតកម្លាំងលើការដាំដុះស្រូវជាងលើការដាំបន្លែ ក្នុងកម្រិតខ្លាំងជាងគេ បើធៀបនឹងគ្រួសារពីរប្រភេទទៀត។

តារាង១០៖ មុខបន្លែមានដាំដោយគ្រួសារសំណាក (%)

| បន្លែ | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | មធ្យមភាគ |
|---|---|---|---|---|
| ននោង | 19.05 | 26.24 | 16.43 | 21.07 |
| ត្រកួន | 19.48 | 14.89 | 19.25 | 17.63 |
| ត្រឡាច | 9.09 | 16.67 | 14.08 | 13.5 |
| ត្រសក់ | 7.79 | 7.45 | 7.98 | 7.71 |
| សណ្តែកទ្រើង | 8.23 | 6.74 | 3.76 | 6.34 |
| ល្ពៅ | 5.63 | 6.03 | 6.1 | 5.92 |
| ត្រប់ | 6.93 | 3.9 | 5.16 | 5.23 |
| បន្លែផ្សេងទៀត | 23.8 | 18.07 | 27.25 | 22.61 |

រូបភាព២៣៖ គ្រួសារបានលក់បន្លែដាំខ្លួនឯង ក្នុង ១២ខែ មុនពេលធ្វើអង្កេត (%)




តារាង១១៖ ថ្លៃលក់បានសរុប និង ចំណាយលើធាតុចូលសរុប សម្រាប់បន្លែ (ដុល្លារ/ឆ្នាំ)

| | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | មធ្យមភាគ |
|---|---|---|---|---|
| ថ្លៃលក់បានសរុប | 20.6 | 16.2 | 53.5 | 27.6 |
| ចំណាយលើធាតុចូលសរុប | 6.2 | 8.1 | 10.3 | 8.2 |
| ចំណេញសុទ្ធ | 14.4 | 8.1 | 43.2 | 19.4 |

តារាង១២៖ ធាតុចូលសម្រាប់បន្លែ (ដុល្លារ)

| ធាតុចូល | ដាំតែស្រូវវស្សា | ដាំតែស្រូវប្រាំង | ដាំស្រូវទាំងពីរប្រភេទ | មធ្យមភាគ |
|---|---|---|---|---|
| ពូជ | 2.5 | 4.0 | 2.1 | 3.1 |
| ជីគីមី | 1.2 | 1.8 | 2.7 | 1.9 |
| ថ្នាំសម្លាប់សត្វចង្រៃ | 0.2 | 1.0 | 0.3 | 0.6 |
| សាំង | 1.6 | 0.9 | 3.6 | 1.8 |
| ធាតុចូលផ្សេងទៀត | 0.7 | 0.4 | 1.6 | 0.8 |

## ៦.៥ បន្ទុកចំណាយ និងអត្ថប្រយោជន៍ក្នុងចំណោមដំណាំស្រូវ

### ៦.៥.១ ទំហំដី

តារាង១៥ ផ្តល់ព័ត៌មានពីទំហំដីគិតតាមពូជស្រូវទាំងបី គឺ ស្រូវស្រាល ស្រូវកណ្តាល និង ស្រូវធ្ងន់។[6] ផ្ទៃដីដាំដុះ និងផ្ទៃដីប្រមូលផល មានទំហំជាមធ្យមសឹងតែប្រហែលគ្នា គឺ ១,៧ ហិកតា ដែលបង្ហាញថា ការខូចខាតស្រូវមុនពេលប្រមូលផលមានតិចតួចណាស់ ត្រឹមប្រមាណ ១,៨% នៃដីដាំដុះសរុប។ ថ្វីបើទំហំជាមធ្យមនៃដីប្រមូលផលស្រូវកណ្តាលវាតូចជាង ស្រូវធ្ងន់ និងស្រូវស្រាល ប៉ុន្តែផ្ទៃដីដាំដុះមានការខូចខាតគិតជាភាគរយ ក៏តូចជាងដែរ។ ចំណុចនេះឆ្លុះបញ្ចាំងឲ្យឃើញថា គ្រួសារប្រើប្រាស់ពូជស្រូវស្រាលនិងស្រូវកណ្តាល តែងផ្តោតខ្លាំងជាងលើកសិកម្ម។

តារាង១៣៖ ទំហំដីគិតតាមរយៈពេលដាំដុះស្រូវ

| ទំហំដី | រយៈពេលខ្លី | រយៈពេលមធ្យម | រយៈពេលវែង | មធ្យមភាគ |
|---|---|---|---|---|
| ដីដាំដុះ (ហិកតា) | 2.07 | 0.90 | 0.98 | 1.7 |
| ដីប្រមូលផល (ហិកតា) | 2.04 | 0.89 | 0.95 | 1.7 |
| ការបាត់បង់ផលស្រូវ (គិតជា % នៃផ្ទៃដីដាំដុះសរុប) | 1.45 | 1.11 | 3.06 | 1.8 |

### ៦.៥.២ ពូជស្រូវ

រូបភាព២៤ ផ្តល់ព័ត៌មានពីពូជស្រូវផ្សេងៗ មានដាំដុះក្នុងតំបន់សិក្សា ដោយបែងចែកតាមរយៈពេលដាំដុះ។ ឈ្មោះពូជស្រូវនានា គឺហៅតាមការចងចាំរបស់កសិករ។ ស្រូវរយៈពេលខ្លីភាគច្រើនណាស់ ជាពូជ IR504 ហើយបន្ទាប់មកគឺពូជ IR ផ្សេងៗទៀត។ ស្រូវរយៈពេលមធ្យមជាងពាក់កណ្តាល ជាពូជ ក្រសាំងទាប បន្ទាប់មកគឺ IRដំណើប, ទ្រនុង និង ស្រូវតយ។ ពូជស្រូវរយៈពេលវែង រួមមាន ផ្ការំដួល ស្រូវដំណើប ឆ្មារល្អិត ក្រហមធ្ងន់ សូម៉ាលី ម៉ុមាង (រូបភាព២៤)។

រូបភាព២៤៖ ពូជស្រូវបែងចែកតាមរយៈពេល (%)




6 រយៈពេលដាំដុះស្រូវ គេកំណត់តាមចំនួនថ្ងៃរហូតដល់ការប្រមូលផល គឺមាន រយៈពេលខ្លី(៩៥ ថ្ងៃ សម្រាប់ស្រូវស្រាល), រយៈពេលមធ្យម (១០០-១៥០ ថ្ងៃ សម្រាប់ស្រូវកណ្តាល), រយៈពេលវែង(លើសពី ១៥០ ថ្ងៃ សម្រាប់ស្រូវធ្ងន់)។

រូបភាព២៥ បង្ហាញពីចំនួនថ្ងៃលូតលាស់រហូតដល់ទុំ នៃពូជស្រូវ IR504, ពូជស្រូវ IR ផ្សេងទៀត, ពូជស្រូវមិនមែន IR, នៅរដូវប្រាំង និងនៅរដូវវស្សា។ រយៈពេលលូតលាស់រហូតដល់ទុំនៃស្រូវ IR504 និងស្រូវ IR ផ្សេងទៀតគឺតិចជាង ១០០ ថ្ងៃ រីឯពូជស្រូវមិនមែន IR រយៈពេលនេះតែងខ្លីជាងច្រើនក្នុងរដូវប្រាំង បើធៀបនឹងការដាំដុះវាក្នុងរដូវវស្សា។

រូបភាព២៥៖ ចំនួនថ្ងៃរហូតដល់ទុំ




តារាង១៤ បង្ហាញថា ការព្រោះស្រូវ ជាវិធីដាំដុះចម្បងគេ ក្នុងតំបន់សិក្សា។ ការស្ទូងមិនសូវមានអនុវត្តទេ ហើយភាគច្រើនសម្រាប់តែស្រូវធ្ងន់ប៉ុណ្ណោះ។ ការព្រោះស្រូវ អាចកាត់បន្ថយទាំងពេលវេលា និងកម្លាំងពលកម្ម ប៉ុន្តែត្រូវប្រើស្រូវពូជអស់ច្រើនជាង។

តារាង១៤៖ វិធីសាបព្រោះ (%)

| ព្រោះ/ស្ទូង (%) | ស្រូវស្រាល | ស្រូវកណ្តាល | ស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| ព្រោះ | 99.6 | 99.2 | 98.9 | 99.4 |
| ស្ទូង | 0.4 | 0.8 | 1.1 | 0.6 |

## ៦.៥.៣ ទិន្នផលស្រូវ

ជាទូទៅ ទិន្នផលជាតួលេខសំខាន់សម្រាប់បង្ហាញពី ផលិតភាពនៃដំណាំស្រូវ។ ដូចមានបង្ហាញក្នុងតារាង១៥ ស្រូវស្រាលមានទិន្នផលមធ្យមខ្ពស់ជាងគេក្នុងចំណោមពូជស្រូវទាំងបីប្រភេទ។ ទិន្នផលក្នុងរដូវប្រាំង វាខ្ពស់ជាងទិន្នផលក្នុងរដូវវស្សា សម្រាប់ស្រូវទាំងពីរប្រភេទដែលអាចដាំដុះបានក្នុងរដូវទាំងពីរ (គ្មានកសិករណាធ្វើស្រូវធ្ងន់ក្នុងរដូវប្រាំងទេ)។ ទិន្នផលជាមធ្យមក៏មិនខុសគ្នាដែររវាងស្រូវកណ្តាល នឹងស្រូវធ្ងន់។ ក្នុងរដូវវស្សា ស្រូវស្រាលមានទិន្នផលខ្ពស់ជាងគេ។

តារាង១៥: ទិន្នផលស្រូវ (តោន/ហិកតា)

| រដូវ | ស្រូវស្រាល | ស្រូវកណ្តាល | ស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| រដូវវស្សា | 4.1 | 2.3 | 2.4 | 3.2 |
| រដូវប្រាំង | 4.5 | 3.1 | - | 4.5 |
| សរុប | 4.3 | 2.4 | 2.4 | 3.7 |

## ៦.៦ ធាតុចូលនៃដំណាំស្រូវ

ធាតុចូលសំខាន់ៗនៃដំណាំស្រូវ រួមមាន ពូជ ជី ថ្នាំសម្លាប់សត្វចង្រៃ និង កម្លាំងពលកម្ម។ ធាតុចូលដទៃទៀតអាចមាន ទឹក និង ថ្លៃជួលម៉ាស៊ីន។ តារាង១៦ បង្ហាញពី ការប្រើប្រាស់ធាតុចូលជាមធ្យមរាយការណ៍ឡើងដោយកសិករ។ ស្រូវស្រាលត្រូវប្រើពូជអស់ច្រើនជាងគេ (គិតជា គីឡូក្រាម/ហិកតា) រីឯស្រូវធ្ងន់ត្រូវការពូជតិចជាងគេ។

ស្រដៀងគ្នាដែរ កសិករទាំងនោះប្រើជីជាមូលដ្ឋានអស់ច្រើនជាងគេ។ ជីតែងត្រូវប្រើអស់ច្រើនជាងឆ្ងាយណាស់ក្នុងការដាំដុះក្នុងរយៈពេលខ្លី បើធៀបនឹងការដាំដុះក្នុងរយៈពេលវែង និងមធ្យម។ កសិករមិនអាចប៉ាន់ស្មានចំនួនពិតប្រាកដនៃថ្នាំសម្លាប់សត្វចង្រៃផ្សេងៗដែលគាត់ប្រើក្នុងស្រែរបស់ខ្លួនទេ។ ប៉ុន្តែគាត់បាននឹកឃើញពីចំណាយជាក់ស្តែង ដែលខ្ពស់ជាងគេជាខ្លាំងសម្រាប់ស្រូវស្រាល។ គ្រួសារខ្លះបានជួលកម្លាំងពលកម្មពីខាងក្រៅ ហើយចំណាយនេះសម្រាប់ស្រូវកណ្តាល វាខ្ពស់ជាងស្រូវប្រភេទផ្សេងទៀត ប៉ុន្តែគ្រួសារដែលជួលកម្លាំងពលកម្ម មានចំនួនភាគរយច្រើនជាងគេសម្រាប់ស្រូវស្រាល។

ចំណាយលើថ្លៃជួលម៉ាស៊ីន មានកម្រិតទាបជាងគេសម្រាប់ស្រូវកណ្តាល ប៉ុន្តែស្ទើរតែក្នុង ១០០% នៃដំណាំស្រូវគ្រប់ប្រភេទ មានការជួលគ្រឿងម៉ាស៊ីន។ ស្រូវស្រាលមានចំណាយខ្ពស់ជាងគេលើការផ្គត់ផ្គង់ទឹក ហើយចំនួនភាគរយនៃគ្រួសារដាំស្រូវស្រាលមានប្រើប្រើម៉ាស៊ីនបូមទឹក ក៏ខ្ពស់ជាងគេខ្លាំងដែរ។

តារាង១៦៖ ធាតុចូលសម្រាប់ផលិតកម្មស្រូវ

| ធាតុចូល | ស្រូវស្រាល | ស្រូវកណ្តាល | ស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| ពូជ (គីឡូក្រាម/ហិកតា) | 322.1 | 147.6 | 122.2 | 257.5 |
| ជីទ្រាប់បាត (គីឡូក្រាម/ហិកតា) | 111 | 93.5 | 78.5 | 94.5 |
| ជីបាចលើស្រូវ (គីឡូក្រាម/ហិកតា) | 349 | 216 | 198 | 301 |
| ជីប្រើប្រាស់សរុប (គីឡូក្រាម/ហិកតា) | 352 | 223 | 203 | 305 |
| ថ្នាំសម្លាប់សត្វចង្រៃ(ដុល្លារ/ហិកតា) | 116.7 | 39.7 | 21.3 | 94.5 |
| ចំណាយជួលកម្លាំងពលកម្ម (ដុល្លារ/ហិកតា) | 27.4 | 62.5 | 32.5 | 30.9 |
| ចំណាយជួលម៉ាស៊ីន (ដុល្លារ/ហិកតា) | 108.1 | 93.2 | 114.2 | 107.9 |
| សាំងសម្រាប់ម៉ាស៊ីនកសិកម្ម (ដុល្លារ/ហិកតា) | 21.3 | 23.5 | 17.1 | 20.9 |
| ចំណាយលើការផ្គត់ផ្គង់ទឹក (ដុល្លារ/ហិកតា) | 71.4 | 33.4 | 17.9 | 67.3 |
| ចំណាយលើការប្រើម៉ាស៊ីនបូមទឹក(ដុល្លារ/ហិកតា) | 45.5 | 30.3 | 17.9 | 43.5 |

តារាង១៧៖ គ្រួសារមានប្រើកម្លាំងពលកម្ម និងម៉ាស៊ីន (%)

| | ស្រូវស្រាល | ស្រូវកណ្តាល | ស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| ជួលពលកម្ម | 27.6 | 17 | 16.8 | 23.98 |
| ម៉ាស៊ីន | 100.0 | 98.5 | 99.6 | 99.76 |
| ម៉ាស៊ីនបូមទឹក | 80.5 | 31.8 | 11.2 | 59.39 |

តារាង១៨៖ ប្រភពទឹក (%)

| ប្រភពទឹក (ភាគរយ) | ស្រូវស្រាល | ស្រូវកណ្តាល | ស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| ប្រភពធម្មជាតិ (ទឹកបានពីទន្លេ/ស្ទឹង បឹង ស្រះ អូរ...) | 28 | 16 | 4 | 21 |
| ប្រព័ន្ធស្រោចស្រពរបស់រដ្ឋាភិបាល | 11 | 4 | 1 | 8 |
| ប្រព័ន្ធស្រោចស្រពឯកជន | 28 | 0 | 0 | 19 |
| ទឹកក្រោមដី | 18 | 4 | 1 | 12 |
| ទឹកភ្លៀង | 15 | 76 | 94 | 40 |

ប្រភពទឹកសម្រាប់កសិកម្មក្នុងតំបន់សិក្សា រួមមាន ទន្លេ/ស្ទឹង បឹង ប្រព័ន្ធស្រោចស្រពរបស់រដ្ឋាភិបាល ប្រព័ន្ធស្រោចស្រពឯកជន ទឹកក្រោមដី និងទឹកភ្លៀង។ ទឹកប្រើប្រាស់សម្រាប់កសិកម្ម ប្រមាណ ៤០% ជាទឹកភ្លៀង ហើយបន្ទាប់មកគឺ ទឹកបានពីប្រភពធម្មជាតិផ្សេងទៀត។ ស្រូវកណ្តាល និងស្រូវធ្ងន់ពឹងផ្អែកខ្លាំងលើទឹកភ្លៀង ហើយជាងពាក់កណ្តាលនៃទឹកប្រើប្រាស់សម្រាប់ស្រូវស្រាលបានពីប្រភពធម្មជាតិ និងប្រព័ន្ធស្រោចស្រពឯកជន។ ប្រភពទឹកមានប្រើប្រាស់តិចជាងគេ គឺប្រព័ន្ធស្រោចស្រពរបស់រដ្ឋាភិបាល។

### ៦.៦.១ ការលក់ស្រូវ

រូបភាព២៦ បង្ហាញពី ការលក់ស្រូវក្នុង ១២ ខែមុនពេលធ្វើអង្កេត។ គ្រួសារធ្វើស្រូវស្រាល តែងលក់ស្រូវច្រើនបំផុត ហើយគ្រួសារធ្វើស្រូវកណ្តាលតែងលក់ស្រូវតិចបំផុត ដែលមានន័យថា ពូជស្រូវកណ្តាលជាច្រើន គឺសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ គ្រួសារភាគច្រើនលក់ស្រូវសើម ដោយមានមិនដល់ ១០% ទេដែលលក់អង្ករ។

រូបភាព២៦៖ ការលក់ស្រូវ







តារាង១៩ ផ្តល់ការប្រៀបធៀបថ្លៃស្រូវមានពូជខុសៗគ្នា។ ស្រូវ និងអង្ករ មានថ្លៃខុសគ្នាច្រើន ហើយវាខុសគ្នាខ្លាំងបំផុតសម្រាប់ស្រូវធ្ងន់។

តារាង១៩៖ ថ្លៃឯកតាស្រូវ និងអង្ករ (រៀល/គីឡូក្រាម)

| ស្រូវ និងអង្ករ | ប្រភេទស្រូវស្រាល | ប្រភេទស្រូវកណ្តាល | ប្រភេទស្រូវធ្ងន់ | សរុប |
|---|---|---|---|---|
| ស្រូវវស្សា | 750 | 898 | 879 | 773 |
| ស្រូវប្រាំង | 843 | 1067 | 1015 | 933 |
| អង្ករ | 1700 | 1873 | 2287 | 2100 |

### ៦.៦.២ ចំណាយនិងផលចំណេញនៃការដាំស្រូវ IR504 និងពូជស្រូវផ្សេងទៀត

កសិករភាគច្រើននៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ធ្វើស្រូវប្រាំងក្នុងគោលបំណងធ្វើពាណិជ្ជកម្ម។ IR504 ជាពូជស្រូវស្រាលដែលគេដឹងជាទូទៅថា មានទិន្នផលខ្ពស់។ វាជាដំណាំដែលកសិករមានដាំច្រើនជាងគេក្នុងតំបន់នេះ។ នៅវៀតណាម ស្រូវ IR504 អាចផ្តល់ទិន្នផលបានរហូតដល់ ១០ តោន/ហិកតា ប្រសិនបើកសិករមានប្រើជីគីមី និងថ្នាំសម្លាប់សត្វចង្រៃច្រើន។ ប៉ុន្តែសម្ភាសន៍នៅវៀតណាមបានឲ្យដឹងថា ការដាំដុះបែបប្រពលវប្បកម្មនៃស្រូវនេះ នាំឲ្យខូចខាតដល់បរិស្ថាន ជាពិសេសធ្វើឲ្យទឹកនិងដីខូចគុណភាព។ ទោះយ៉ាងនេះក្តី ស្រូវ IR504 នៅតែកសិករនិយមដាំដុះ ទាំងនៅវៀតណាម និងកម្ពុជា ព្រោះមានទិន្នផលខ្ពស់ និងតម្រូវការច្រើនពីអ្នកទិញ។

តារាង២០ ប្រៀបធៀប ចំណាយនិងផលចំណេញនៃការដាំស្រូវ IR504 ជាមួយនឹងស្រូវកណ្តាល និងស្រូវធ្ងន់ផ្សេងៗ។ ស្រូវ IR504 ផ្តល់ផលចំណេញច្រើនជាងស្រូវកណ្តាល និងស្រូវធ្ងន់នានា ទោះបីវាមានថ្លៃទាបជាងក្តី។ ស្រូវកណ្តាលលក់បានថ្លៃខ្ពស់ជាងគេ ប៉ុន្តែបានផលចំណេញតិចជាងគេ។ ស្រូវ IR504 មានថ្លៃលក់ទាបក៏ពិតមែន ប៉ុន្តែកសិករអាចបានប្រាក់ចំណេញច្រើនជាងពីការដាំដុះវា ព្រោះវាមានទិន្នផលខ្ពស់។

តារាង២០៖ ការប្រៀបធៀបស្រូវ IR504 ជាមួយនឹងពូជស្រូវផ្សេងទៀត (វដ្តផលិតកម្មមួយ)

| ធាតុចូល | IR504 | | ស្រូវកណ្ដាល | | ស្រូវធ្ងន់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារ/ហ.ត | % | ដុល្លារ/ហ.ត | % | ដុល្លារ/ហ.ត | % | ដុល្លារ/ហ.ត | % |
| ពូជ | 88.1 | 15.6 | 46.1 | 15.3 | 38.6 | 14.0 | 69.7 | 15.3 |
| ជួលពលកម្ម | 7.7 | 1.4 | 10.7 | 3.6 | 5.5 | 2.0 | 7.5 | 1.7 |
| ទឹក | 26.4 | 4.7 | 1.4 | 0.5 | 0 | 0.0 | 16.3 | 3.6 |
| ម៉ាស៊ីនបូមទឹក | 39.4 | 7.0 | 9.2 | 3.1 | 2 | 0.7 | 25.7 | 5.7 |
| ម៉ាស៊ីនកសិកម្ម | 107.5 | 19.1 | 91.8 | 30.5 | 113.8 | 41.2 | 107.2 | 23.6 |
| ជី | 173.5 | 30.8 | 116.3 | 38.6 | 102.5 | 37.2 | 147.5 | 32.5 |
| ថ្នាំសម្លាប់សត្វចង្រៃ | 120.7 | 21.4 | 25.9 | 8.6 | 13.6 | 4.9 | 80.5 | 17.7 |
| សរុបធាតុចូល | 563.3 | 100.0 | 301.4 | 100.0 | 275.9 | 100.0 | 454.4 | 100.0 |
| ថ្លៃមធ្យម (ស្រូវសើម) (រៀល/គ.ក) | 749.7 | - | 898.5 | - | 879.4 | - | 776.6 | - |
| ធាតុចេញ | 827.2 | - | 508.9 | - | 487.4 | - | 697.4 | - |
| ប្រាក់ចំណេញ | 263.9 | - | 207.5 | - | 211.5 | - | 243 | - |

តារាង២០ បង្ហាញទៀតថា ស្រូវ IR504 ត្រូវការជីតិចជាងក៏ពិតមែន ប៉ុន្តែត្រូវមានការប្រើថ្នាំសម្លាប់សត្វចង្រៃច្រើនជាងពូជស្រូវផ្សេង។ ក្នុងដំណាំស្រូវ IR504 ជី និងថ្នាំសម្លាប់សត្វចង្រៃតំណាងឲ្យ ៥២% នៃចំណាយសរុបរបស់កសិករ រីឯសម្រាប់ស្រូវកណ្ដាល និងស្រូវធ្ងន់ វាមានត្រឹមតែ ៤៧ និង ៤២% ប៉ុណ្ណោះ។ ដំណាំស្រូវ IR504 ត្រូវប្រើធាតុចូលសរុបអស់ច្រើនជាខ្លាំងជាងស្រូវពីរប្រភេទទៀត។

ស្រូវ IR504 ផ្ដល់ផលចំណេញបានច្រើនជាង ស្រូវពីរប្រភេទទៀតក៏ពិតមែន ប៉ុន្តែចំណាយច្រើនលើជីនិងថ្នាំសម្លាប់សត្វចង្រៃ ជាសញ្ញាមិនល្អទេសម្រាប់គុណភាពអង្ករ។ តាមមតិក្រុមផ្ដល់គំនិតវៀតណាមផ្នែកកសិកម្ម IPSARD (វិទ្យាស្ថានផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់កសិកម្ម និងអភិវឌ្ឍន៍ជនបទ) ការដាក់ជាទៀងទាត់នូវជីគីមីនិងថ្នាំសម្លាប់សត្វចង្រៃ បង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស ហើយក្នុងរយៈពេលវែង ធ្វើឲ្យខូចខាតដល់ទឹកនិងដី និងអាចមានផលប៉ះពាល់អវិជ្ជមានដល់ប្រព័ន្ធអេកូឡូស៊ីទាំងមូល។

យោងតាមបទសម្ភាសន៍នានា មានការឲ្យយោបល់ថា កសិករគួរគិតគូរដាំស្រូវកណ្ដាល ជាជាង ស្រូវ IR504 ព្រោះស្រូវកណ្ដាលបានថ្លៃខ្ពស់ជាង និងបង្កគ្រោះថ្នាក់តិចជាងដល់សុខភាពមនុស្ស និងបរិស្ថាន។ ទី១ យោងតាម FGDs ជាមួយកសិករក្នុងខេត្តទាំងបី ការដាំដុះស្រូវកណ្ដាលមិនសូវប្រើកម្លាំងពលកម្មច្រើន ដូចស្រូវ IR504 នោះទេ ព្រោះកសិករមិនចាំបាច់ដាក់ជីនិងថ្នាំសម្លាប់សត្វចង្រៃញឹកញាប់ខ្លាំង ដូច្នេះសល់ពេលច្រើនសម្រាប់ការងារក្រៅកសិដ្ឋាន។ ទី២ កសិករនិយាយថា គាត់ដាំស្រូវ IR504 ព្រោះមានតម្រូវការពីវៀតណាម។ គាត់អាចផ្លាស់ប្ដូរទៅធ្វើស្រូវក្រអូបវិញ ជាពិសេសស្រូវកណ្ដាល ឲ្យតែមានទីផ្សារសម្រាប់វា។

## សារសំខាន់ៗពីនាគីពាក់ព័ន្ធ

### ខាងវៀតណាម

**វិស័យសាធារណៈ**
- រដ្ឋាភិបាលវៀតណាមកំពុងរៀបចំរចនាសម្ព័ន្ធ វិស័យកសិកម្មឡើងវិញ។
- ការរៀបចំរចនាសម្ព័ន្ធឡើងវិញត្រូវមានការអនុវត្តសេចក្តីសម្រេចចិត្តនិងគោលនយោបាយជាច្រើន
- វិសាលភាពនៃគោលនយោបាយឡើងវិញនេះ និងការយល់ដឹងរបស់កសិករ នៅមានកម្រិត។
- ក្នុងរយៈពេលខ្លី នឹងមិនមានការប៉ះទង្គិចអ្វីដល់តម្រូវការស្រូវអង្ករមានតម្លៃទាបពីកម្ពុជាឡើយ។

**វិស័យឯកជន**
- អ្នកនាំចេញរកបានចំណេញកាន់តែច្រើនពីការនាំចេញអង្ករមានតម្លៃខ្ពស់។
- ពួកគេចង់ឲ្យរដ្ឋាភិបាលស្វែងរកទីផ្សារថ្មីៗសម្រាប់អង្ករមានតម្លៃខ្ពស់ ប៉ុន្តែរក្សាទុកទីផ្សារអង្ករមានតម្លៃទាបដែលមានស្រាប់។

### ឈ្មួញ រោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញកម្ពុជា

- នៅក្នុងតំបន់សិក្សា រោងម៉ាស៊ីនកិនស្រូវមានខ្នាតតូច និងសមត្ថភាពទាបក្នុងការកិនស្រូវ។
- ហេដ្ឋារចនាសម្ព័ន្ធ (ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព) មិនទាន់មានគ្រប់គ្រាន់ និងមិនទាន់មានគុណភាពល្អ។
- អគ្គិសនីមានថ្លៃខ្ពស់ និងការផ្គត់ផ្គង់មិនសូវទៀងទាត់ ធ្វើឲ្យរាំងស្ទះដល់ការបង្កើតរោងចក្រកិនស្រូវខ្នាតធំ។
- រោងម៉ាស៊ីនកិនស្រូវមិនអាចស្រូបយកស្រូវនៅសល់បានទេ បើសិនវៀតណាមឈប់ទិញវា។
- រោងម៉ាស៊ីនកិនស្រូវត្រូវការទុនបន្ថែមដើម្បីទិញស្រូវច្រើនថែមទៀត និងពង្រីកសមត្ថភាពកែច្នៃ។

### កសិករកម្ពុជា

- បើសិនវៀតណាមឈប់ទិញចូល កសិករកម្ពុជានឹងជួបការលំបាក។ ពួកគេនឹងដាំពូជស្រូវផ្សេងដែលមានតម្រូវការ ឬក៏ទៅធ្វើការក្នុងរោងចក្រនៅទីក្រុងឬក្រៅប្រទេស។
- ពួកគេអាចបន្តដាំស្រូវសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។
- ទឹកមានច្រើនពេកឬតិចពេក និងថ្លៃស្រូវទាបនិងឡើងចុះភ្លាមៗមិនទៀងទាត់ ជាឧបសគ្គចម្បងដែលកសិករត្រូវប្រឈមមុខ ។
- កសិករស្នើឲ្យរដ្ឋាភិបាល ១)ស្វែងរកទីផ្សារមានសុវត្ថិភាព ឬ ២)ទិញស្រូវរបស់គាត់។
- គាត់អាចផ្លាស់ប្តូរទៅផលិតពូជស្រូវអ្វីក៏បាន ឲ្យតែមានទីផ្សារមានសុវត្ថិភាព។

### វិស័យសាធារណៈ និងសមាគម នៅកម្ពុជា

- ក្រសួងកសិកម្ម អាចជួយផ្តល់បច្ចេកទេសផលិតកម្មដល់កសិករ ប៉ុន្តែសមត្ថភាពកសាងចំណងទាក់ទងទីផ្សារនៅមានកម្រិត។
- រដ្ឋាភិបាលចង់ណែនាំកសិករឲ្យដាំស្រូវក្រអូបឬស្រូវមានតម្លៃខ្ពស់ ប៉ុន្តែពិបាកនឹងជំរុញគាត់ ព្រោះស្រូវ IR504 មានតម្រូវការខ្ពស់ពីវៀតណាម។
- គួរបែងចែកធនធានមនុស្សនិងហិរញ្ញវត្ថុបន្ថែមទៀតដល់មន្ទីរកសិកម្មខេត្ត។
- បើសិនវៀតណាមឈប់ទិញស្រូវមានតម្លៃទាប មន្ទីរកសិកម្មខេត្តគួរលើកទឹកចិត្តកសិករឲ្យដាំស្រូវមានតម្លៃខ្ពស់ និងឲ្យរោងម៉ាស៊ីនកិនស្រូវ និងអ្នកនាំចេញចូលរួមក្នុងការស្វែងរកទីផ្សារថ្មីៗ។
- មន្ទីរពាណិជ្ជកម្មខេត្ត មានគោលនយោបាយពាណិជ្ជកម្មជាទូទៅមួយ ប៉ុន្តែមិនទាន់មានគោលនយោបាយអ្វីជាក់លាក់ដើម្បីស្វែងរកទីផ្សារថ្មីៗ សម្រាប់ស្រូវអង្ករទេ។

# ៧. ការពិភាក្សា៖ ការវិភាគអ្នកពាក់ព័ន្ធ

ក្នុងការសិក្សានេះ មានសម្មតិកម្មចម្បងៗពីរ។ ទី១ រដ្ឋាភិបាលវៀតណាមបាននិងកំពុងរៀបចំគោលនយោបាយស្រូវឡើងវិញ ដើម្បីផ្លាស់ប្តូរការផ្តោតលើស្រូវមានតម្លៃទាប ទៅផ្តោតលើស្រូវមានតម្លៃខ្ពស់វិញ។ ទី២ កសិករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជាធ្វើស្រូវ IR504 ជាសំខាន់ ប៉ុន្តែស្រូវនេះពឹងផ្អែកខ្លាំងលើតម្រូវការពីឈ្មួញវៀតណាម។ ក្នុងនេះក្រុមស្រាវជ្រាវបានរកឃើញថា៖

ទី១ ការសិក្សាលើឯកសារមានស្រាប់ និងបទសម្ភាសន៍ជាមួយអ្នកតំណាងក្នុងវិស័យសាធារណៈនិងឯកជននៅវៀតណាម បង្ហាញថា សម្មតិកម្មទី១ ពិតជាត្រឹមត្រូវ ទោះបីមានការអនុវត្តបែបណាក្តី។ យោងតាម KIIs រដ្ឋាភិបាលវៀតណាម កំពុងធ្វើពិពិធកម្មមុខដំណាំ ដោយផ្លាស់ប្តូរទៅផ្តោតលើពូជស្រូវមានតម្លៃខ្ពស់ និងដំណាំផ្សេងទៀតដូចជាបន្លែ ឬផ្លាស់ប្តូរទៅផ្តោតលើការចិញ្ចឹមសត្វ ឬចិញ្ចឹមត្រី។ ប្រព័ន្ធនាំចេញអង្ករបស់វៀតណាមក៏កំពុងផ្លាស់ប្តូរដែរ។ យោងតាម KIIs ក្រុមហ៊ុននាំចេញខ្លះកំពុងចាប់ផ្តើមនាំចេញអង្ករមានតម្លៃខ្ពស់ ហើយរកបានប្រាក់ចំណេញប្រសើរជាងមុន។ កសិករវៀតណាមមួយចំនួនក៏កំពុងគិតគូរផ្លាស់ប្តូរដំណាំស្រូវរបស់ខ្លួន ប៉ុន្តែមិនទាន់មានច្រើននាក់ទេដែលបានផ្លាស់ប្តូររួចហើយ។ កសិករនៅដីសណ្តទន្លេមេគង្គ នៅតែបន្តធ្វើស្រូវមានតម្លៃទាប ព្រោះគាត់ធ្លាប់ដាំវាជាយូរឆ្នាំ ហើយតម្រូវការទីផ្សារក៏នៅតែមាន។ សរុបមក ទាំងតួអង្គក្នុងវិស័យសាធារណៈ និងឯកជន បានបញ្ជាក់ថា គោលនយោបាយនេះនៅថ្មីថ្មោង និងត្រូវការពេលវេលាច្រើនដើម្បីដាក់អនុវត្ត គឺ អាចរហូតដល់រយៈពេលមធ្យមឯណោះ ទើបរដ្ឋាភិបាលមានកំណត់ផែនការជាក់លាក់ ដោយស្វែងរកទីផ្សារថ្មីៗមានស្ថិរភាពល្អ និងជួយកសិករឲ្យទទួលបានព័ត៌មានគ្រប់គ្រាន់ ហើយសម្របខ្លួនទៅតាមនោះ។ ដូច្នេះក្នុងរយៈពេលខ្លី ឈ្មួញវៀតណាមទំនងនៅតែបន្តទិញស្រូវអង្ករមានតម្លៃទាបពីប្រទេសកម្ពុជា។

ទី២ FGDs ជាមួយកសិករ ហើយនិង KIIs ជាមួយឈ្មួញក្នុងមូលដ្ឋាននៅកម្ពុជា មន្ទីរកសិកម្មខេត្ត និងមន្ទីរពាណិជ្ជកម្មខេត្ត បង្ហាញថា សម្មតិកម្មទី២ ក៏ត្រឹមត្រូវដែរ។ វៀតណាមជាអ្នកទិញចម្បងនៅក្នុងខេត្តបានចុះសិក្សាទាំងបី។ ទីផ្សារស្ទើរតែមានលក្ខណៈផ្តាច់មុខ ព្រោះវៀតណាមជាអ្នកទិញចម្បងតែមួយ។ កសិករកម្ពុជាផលិតទាំងស្រូវវស្សា(ក្រអូប ឬមានតម្លៃខ្ពស់) និងស្រូវប្រាំង(មានតម្លៃទាប)។ ស្រូវប្រាំងគេដាំដុះសម្រាប់ធ្វើពាណិជ្ជកម្ម រីឯស្រូវវស្សាសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារជាសំខាន់ ប៉ុន្តែស្រូវប្រើមិនអស់ក៏លក់ដូរដែរ។ មានកសិករតិចនាក់ណាស់ដែលដាំបន្លែ។ ប្រសិនបើឈ្មួញវៀតណាមបញ្ឈប់ការទិញរបស់ពួកគេ ជីវភាពកសិករនៅភាគអាគ្នេយ៍ប្រទេសកម្ពុជានឹងរងផលប៉ះពាល់អវិជ្ជមានជាខ្លាំង។

ទី៣ រោងម៉ាស៊ីនកិនស្រូវ និងឈ្មួញនានាក្នុងតំបន់សិក្សា មិនមានសមត្ថភាពស្រូបយកផលស្រូវលើសអស់ទេ ប្រសិនបើវៀតណាមឈប់ទិញ។ រោងម៉ាស៊ីនកិនស្រូវកំពុងត្រូវការទុនបង្វិល និងកម្ចីមានការប្រាក់ទាប ដើម្បីពង្រីកសមត្ថភាពរបស់ខ្លួន។ មានរោងម៉ាស៊ីនកិនស្រូវធំៗពីរបីនៅកម្ពុជាដែរ ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធនិងរបៀបរៀបចំផ្នែកឡូជីស្ទិកមិនបានគ្រប់គ្រាន់ ពួកគេមិនអាចប្រមូលស្រូវថែមទៀតប្រកបដោយប្រសិទ្ធភាពបានទេ។ ម្យ៉ាងទៀត ដោយសារកសិករចំណាយពេលតិចជាងមុនក្នុងការប្រមូលផលស្រូវ ដូច្នេះឈ្មួញនិងរោងម៉ាស៊ីនកិនស្រូវត្រូវពង្រីកការទិញរបស់ខ្លួនក្នុងរដូវប្រមូលផល ដោយត្រូវមានកន្លែងស្តុកធំ និងសមត្ថភាពខ្ពស់ក្នុងការសម្ងួត និងកិនស្រូវ។

ទី៤ វិស័យសាធារណៈនៅកម្ពុជាមើលឃើញពីសារៈសំខាន់នៃទីផ្សារសម្រាប់កសិផល ហើយកំពុងស្វែងរកទីផ្សារថ្មីៗ ដើម្បីធ្វើពិពិធកម្មចេញពីប្រទេសជិតខាង។ ចិនជាប្រទេសមានជោគជ័យមួយក្នុងការស្វែងរកទីផ្សារអង្ករថ្មីៗ។ រដ្ឋាភិបាលបានលើកទឹកចិត្តកសិករឲ្យដាំស្រូវក្រអូបដែលមានរយៈពេលមធ្យម ដោយបានកំណត់ស្រូវ ១០ ពូជដែលកសិករគួរដាំសម្រាប់នាំចេញ។

# ៨. សេចក្តីសន្និដ្ឋាន

ការរេចរឹលអស់ធនធានធម្មជាតិ ការបំពុលបរិស្ថាន សមត្ថភាពប្រកួតប្រជែងខ្សោយ ការផ្លាស់ប្តូរតម្រូវការក្នុងស្រុកនិងក្រៅប្រទេស ឧស្សាហូបនីយកម្មឆាប់រហ័ស នគរូបនីយកម្ម និងការប្រែប្រួលអាកាសធាតុ បានក្លាយជាក្តីបារម្ភខ្លាំងសម្រាប់រដ្ឋាភិបាលវៀតណាម។ កត្តាទាំងនេះបានជំរុញឲ្យរដ្ឋាភិបាលត្រូវរៀបចំគោលនយោបាយជាតិផ្នែកសេដ្ឋកិច្ច និងកសិកម្មឡើងវិញ។ សម្ភាសន៍ជាមួយអ្នកកសាងគោលនយោបាយវៀតណាម បង្ហាញថា ផលិតកម្មបែបប្រពលវប្បកម្មនូវស្រូវអង្ករមានគុណភាពទាប និងទិន្នផលខ្ពស់ ដោយប្រើជីគីមីនិងថ្នាំសម្លាប់សត្វចង្រៃច្រើនណាស់មិនមែនជាជម្រើសអាចរស់រានបានទៀតទេ ព្រោះវាបង្កើនចំណាយផលិតកម្ម កាត់បន្ថយតម្លៃអង្ករ និងមានការបំពុលដីនិងទឹកជាខ្លាំង។ គោលនយោបាយថ្មីលើកទឹកចិត្តកសិករវៀតណាម ឲ្យផ្តុំកម្លាំងលើពូជស្រូវមានតម្លៃខ្ពស់ និងគិតគូរផ្លាស់ប្តូរទៅដាំដំណាំផ្សេងដូចជាបន្លែ ឬទៅចិញ្ចឹមសត្វ ឬចិញ្ចឹមត្រី។ មានការដាក់អនុវត្តគ្រឿងលើកទឹកចិត្តជាច្រើនហើយ ប៉ុន្តែសកម្មភាពផ្នែកគោលនយោបាយវានៅខ្សោយ និងមានតិច ដោយសារភាពរឹងកំព្រឹសនៃផលិតកម្ម កសិករនៅខ្វះការយល់ដឹងពីគោលនយោបាយថ្មីៗ និងកង្វះធនធានសម្រាប់ការដាក់អនុវត្តគោលនយោបាយ។ ទីផ្សារជាកត្តាសំខាន់បំផុត ដោយត្រូវមានទីផ្សារថ្មីៗមានស្ថិរភាពល្អសម្រាប់ជំនួស ទីផ្សារអង្ករគុណភាពទាបសព្វថ្ងៃ។ សម្ភាសន៍ជាមួយកសិករនៅខេត្ត An Giang បង្ហាញថា ជាង ៥០% នៃកសិករក្នុងតំបន់ដីសណ្តទន្លេមេគង្គដាំស្រូវមានទិន្នផលខ្ពស់ និងគុណភាពទាប រួមទាំង IR504 ផងដែរ។ ប៉ុន្តែពួកគាត់អាចផ្លាស់ប្តូរទៅដាំដំណាំថ្មីបាន ឲ្យតែមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់មានបច្ចេកទេសថ្មី និងជាពិសេសទីផ្សារមានស្ថិរភាព។កិច្ចសន្យាមុនពេលដាំដុះអាចជួយឲ្យកសិករទទួលបានថ្លៃខ្ពស់។ អង្ករមានគុណភាពខ្ពស់ ជួយឲ្យអ្នកនាំចេញទទួលបានអត្រាចំណេញធំជាង ប៉ុន្តែពួកគាត់មានយោបល់ថារដ្ឋាភិបាលមិនគួរបោះបង់ចោលទាំងស្រុងនូវទីផ្សារអង្ករគុណភាពទាបដែលមានស្រាប់នោះទេ។ សរុបមក បំណងធ្វើការផ្លាស់ប្តូរផលិតកម្មស្រូវពីពូជមានគុណភាពទាប ទៅប្រើពូជមានគុណភាពខ្ពស់វិញ ប្រហែលមិនអាចសម្រេចបានក្នុងរយៈពេលខ្លីទេ។ ដូច្នេះ តម្រូវការស្រូវកម្ពុជាពីវៀតណាម នឹងមិនធ្លាក់ចុះយ៉ាងគំហុកទេក្នុងអនាគតដ៏ខ្លីខាងមុខនេះ។

ផលិតកម្មស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា ពឹងផ្អែកខ្លាំងលើតម្រូវការពី វៀតណាមដែលក្នុងឋានៈជាអ្នកទិញចម្បង អាចជះឥទ្ធិពលខ្លាំងទៅលើថ្លៃស្រូវ។ មានឈ្មួញកម្ពុជាតូចៗពីរបីនាក់ដែរដែលធ្វើប្រតិបត្តិការនៅតាមភូមិដោយប្រមូលទិញ និងលក់ស្រូវទៅឲ្យទាំងរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា និងឈ្មួញវៀតណាម ប៉ុន្តែស្រូវលក់ទៅឲ្យរោងម៉ាស៊ីនកិនស្រូវកម្ពុជា មានចំនួនភាគរយតូចណាស់ ។ ឈ្មួញវៀតណាមមួយចំនួនតូចទៅដល់វាលស្រែមុនពេលស្រូវទុំបន្តិចដើម្បីកំណត់ថ្លៃត្រូវច្រូតកាត់ សម្រាប់កសិករកម្ពុជា។ ក្នុងករណីនេះ កសិករខ្លះលក់ស្រូវរបស់ខ្លួនដោយផ្ទាល់ទៅឲ្យឈ្មួញវៀតណាម។

កសិករក្នុងតំបន់ធ្វើអង្កេត ដាំទាំងស្រូវវស្សា(ស្រូវក្រអូប) និងស្រូវប្រាំង។ ស្រូវប្រាំងគេផលិតជាសំខាន់សម្រាប់ធ្វើពាណិជ្ជកម្ម រីឯស្រូវវស្សាគឺសម្រាប់ការប្រើប្រាស់ក្នុងគ្រួសារ។ មានគ្រួសារមួយចំនួនតូចដែរ ដែលជួញដូរផលស្រូវវស្សាលើសពីតម្រូវការរបស់ខ្លួន។ ស្រូវប្រាំងភាគច្រើនណាស់ជាពូជ IR504 រីឯស្រូវវស្សាភាគច្រើនជាពូជស្រូវក្រអូប។ កសិករក្នុងតំបន់អង្កេត តែងលក់ស្រូវវស្សារបស់ខ្លួនដោយគ្មានការកែច្នៃបង្កើតតម្លៃបន្ថែមអ្វីទេ ដែលនាំឲ្យស្រូវនៅតែលក់បានថ្លៃទាប។ មានកសិករតិចនាក់ណាស់ដាំបន្លែ។

វិបត្តិតម្រូវការស្រូវពីវៀតណាម នឹងមានផលប៉ះពាល់អវិជ្ជមានដល់គ្រួសារដែលពឹងផ្អែកជាសំខាន់លើចំណូលបានពីដំណាំស្រូវ។ប្រមាណ២០%នៃគ្រួសារក្នុងអង្កេតទទួលបានជាង៥០%ចំណូលរបស់ខ្លួនពីដំណាំស្រូវ។ប្រជាជនទាំងនេះនឹងត្រូវប៉ះពាល់យ៉ាងខ្លាំង ប្រសិនបើឈ្មួញវៀតណាមឈប់ទិញស្រូវ។ ប៉ុន្តែសម្រាប់អ្នកឯទៀត ផលប៉ះពាល់ប្រហែលមិនសូវធ្ងន់ធ្ងរទេ។ នៅក្នុងអង្កេត គ្រួសារភាគច្រើនបានចាត់ទុកការដាំស្រូវជាមុខរបរចម្បងរបស់ខ្លួន ហើយមុខរបរចម្បងទី២ គឺការងារក្នុងរោងចក្រកាត់ដេរ និងការលក់ដូរ។ គួរឲ្យភ្ញាក់ផ្អើលដែរដែល ដំណាំស្រូវមិនមែនជាប្រភព

ចំណូលចម្បងរបស់គ្រួសារ ព្រោះផ្ដល់ប្រមាណតែ ២០% នៃចំណូលសរុបប៉ុណ្ណោះ។ ប្រភពចំណូលចម្បងគេ គឺការងារជានិយោជិតដែលផ្ដល់ប្រមាណ ៣៥% នៃចំណូលសរុប រីឯចំណូលបានពីការលក់បន្លែ មានត្រឹម ០,៤% ប៉ុណ្ណោះ។

សម្ភាសន៍ជាមួយឈ្មួញក្នុងមូលដ្ឋានបង្ហាញថា សមត្ថភាពកែច្នៃរបស់រោងម៉ាស៊ីនកិនស្រូវក្នុងមូលដ្ឋាននៅមានកម្រិត។ ពួកគេសារភាពថា មិនមានសមត្ថភាពស្រូបយកស្រូវនៅសល់បានទេប្រសិនបើតម្រូវការពីវៀតណាមជួបវិបត្តិ។ សមត្ថភាពសម្ងួត និងកិនស្រូវរបស់ពួកគេ នៅទាបខ្លាំងណាស់ ធៀបនឹងផលិតកម្មសរុបក្នុងតំបន់សិក្សា។ នៅកម្ពុជាមានរោងម៉ាស៊ីនកិនស្រូវធំៗខ្លះដែរ ប៉ុន្តែដោយសារហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ និងប្រព័ន្ធឡូជីស្ទិកខ្សោយ ពួកគេមិនអាចប្រមូលផលស្រូវលើសប្រកបដោយប្រសិទ្ធភាពបានទេ។

ការសិក្សាបានប្រៀបធៀប បន្ទុកចំណាយនិងផលចំណេញនៃដំណាំស្រូវនៅភាគអាគ្នេយ៍ប្រទេសកម្ពុជា។ លទ្ធផលអង្កេតបង្ហាញថា ស្រូវ IR504 (ស្រូវស្រាល) ផ្ដល់ផលចំណេញខ្ពស់ជាងគេដល់កសិករ បន្ទាប់មកគឺ ពូជស្រូវកណ្ដាល និងស្រូវធ្ងន់ផ្សេងៗ។ ស្រូវ IR504 មានទិន្នផលខ្ពស់ ក៏ពិតមែន ប៉ុន្តែវាមានបន្ទុកចំណាយខ្ពស់ផ្នែកសេដ្ឋកិច្ចនិងបរិស្ថាន ព្រោះការប្រើជាតិគីមីកសិកម្ម វាបំពុលដី និងទឹក និងកាត់បន្ថយគុណភាពនិងតម្លៃផលិតផលកសិកម្ម។ ដោយផ្អែកលើ FGDs ជាមួយកសិករ និង KIIs ជាមួយអ្នកកសាងគោលនយោបាយ កសិករគួរផ្លាស់ប្ដូរចេញពីស្រូវ IR504 ទៅដាំពូជស្រូវកណ្ដាលវិញព្រោះអាចលក់បានថ្លៃជាងជិតបីដង ប្រសិនបើកសិករលក់វាជាស្រូវស្ងួត ឬជាអង្ករ។ ដូច្នេះដើម្បីបានផលចំណេញផ្នែកសេដ្ឋកិច្ចក្នុងរយៈពេលវែង និងចីរភាពនៃផលិតកម្មស្រូវ គួរលើកស្ទួយពូជ ស្រូវកណ្ដាល ព្រមទាំងតម្រូវការនិងថ្លៃទីផ្សារមានស្ថិរភាពល្អ។

# ៩. ការផ្តល់យោបល់ផ្នែកគោលនយោបាយ

ផ្អែកលើសម្ភាសន៍នានា ការសិក្សានេះផ្តល់ជាយោបល់ថាៈ

ក្នុងរយៈពេលខ្លី ដើម្បីជៀសវាងវិបត្តិផ្នែកតម្រូវការ រដ្ឋាភិបាលកម្ពុជាគួរមានកិច្ចព្រមព្រៀងទ្វេភាគីជាមួយវៀតណាម ជាពិសេស ជាមួយរដ្ឋបាលបណ្តាខេត្តតាមព្រំដែន ដើម្បីយ៉ាងហោចណាស់រក្សាបាននូវស្ថានភាពបច្ចុប្បន្ន និងទីផ្សារនាំចេញស្រូវអង្ករ។ ហើយដើម្បីរក្សារចនាសម្ព័ន្ធផលិតកម្មសម្រាប់រយៈពេលបន្ទាប់ទៀត ជាការចាំបាច់ត្រូវបង្កើនប្រសិទ្ធភាពផលិតកម្ម ជំនះភាពទន់ខ្សោយផ្សេងៗនៃប្រព័ន្ធផលិតកម្ម និងកែលំអខ្សែសង្វាក់តម្លៃស្រូវផ្នែកខាងលើ។

យោងតាមស្ថានភាពបច្ចុប្បន្ន រដ្ឋាភិបាលគួរធ្វើពិពិធកម្មផលិកម្មស្រូវក្នុងតំបន់អង្កេតនានា។ ទិន្នន័យមិនទាន់មានគ្រប់គ្រាន់ទេដើម្បីបញ្ជាក់ថា ការដាំដុះបន្លែនៅក្នុងតំបន់មានផលចំណេញ។ ដូច្នេះក្នុងការសិក្សាផ្សេងៗថែមទៀត គួរព្យាយាមកំណត់លទ្ធភាពសម្រាប់ការផ្លាស់ប្តូរទៅដាំដំណាំផ្សេងទៀតក្នុងតំបន់នោះ។

ការបណ្តុះបណ្តាលកសិករលើការប្រើប្រាស់ជី សំខាន់ខ្លាំងណាស់ ហើយជាការសំខាន់ដែរ គួរលើកទឹកចិត្តគាត់ឲ្យដាំពូជស្រូវកណ្តាលវិញ។

ការលក់ស្រូវសើមជាការខាតបង់សម្រាប់កសិករ ហើយការនាំចេញស្រូវសើមជាការខាតបង់សម្រាប់ប្រទេសជាតិ។ ក្នុងរយៈពេលវែង កម្ពុជាគួរទាញយកចំណេញពីឧត្តមភាពរបស់ខ្លួនលើ ប្រទេសនាំចេញយូរឆ្នាំមកហើយ ដូចជាវៀតណាមជាដើម។កម្ពុជាមានបរិស្ថាននៅស្អាតហើយការប្រើប្រាស់ជាតិគីមីក៏មិនទាន់មានធ្ងន់ធ្ងរពេកដែរ ដូច្នេះនៅមានស្ថានភាពអំណោយផលដើម្បីផលិតស្រូវពូជប្រពៃណីមានតម្លៃខ្ពស់ ដែលអាចទទួលបានលក្ខខណ្ឌអនុគ្រោះពីសហភាពអឺរ៉ុប (EU)។ ដើម្បីជំរុញផលិតកម្មស្រូវក្រអូប គួរធ្វើវិនិយោគច្រើនៗលើហេដ្ឋារចនាសម្ព័ន្ធ ដូចជា ប្រព័ន្ធស្រោចស្រពការដឹកជញ្ជូន និងសមត្ថភាពកិនស្រូវ។ ប៉ុន្តែដើម្បីទាញយកផលប្រយោជន៍ពីទីផ្សារថ្មីៗ ក្នុងពេលដែលសមត្ថភាពក្រុមហ៊ុនកម្ពុជានៅមានកម្រិត ហើយហេដ្ឋារចនាសម្ព័ន្ធក៏នៅខ្សោយ វិធីសាស្ត្រប្រសើរបំផុតគឺ ការទាក់ទាញសហគ្រាសវៀតណាមឲ្យមកធ្វើវិនិយោគលើផលិតកម្មស្រូវនៅកម្ពុជា ដើម្បីកែលំអសមត្ថភាពស្តុកនិងកែច្នៃ និងជួយអ្នកនាំចេញកម្ពុជាឲ្យកាន់តែសកម្ម និងក្លាហានឡើង ក្នុងការបង្កើនការនាំចេញអង្ករមានតម្លៃបន្ថែមខ្ពស់។

ក្នុងរយៈពេលវែង ទីផ្សារសម្រាប់អង្ករក្រអូបត្រូវតែធ្វើពិពិធកម្ម និងមានសុវត្ថិភាព។ ក្នុងពេលដែលវៀតណាមកំពុងរៀបចំគោលនយោបាយស្រូវឡើងវិញដោយផ្លាស់ប្តូរទៅផ្តោតលើស្រូវមានតម្លៃខ្ពស់នោះកម្ពុជាអាចបន្ស៊ីផលិតកម្មរបស់ខ្លួនដោយផលិតកាន់តែច្រើននូវស្រូវក្រអូបមានតម្លៃខ្ពស់ ដើម្បីបំពេញតាមតម្រូវការពីវៀតណាម។ កសិកម្មតាមកិច្ចសន្យាគួរតែជំរុញជាទូទៅ ដើម្បីពង្រឹងសុវត្ថិភាពទីផ្សារផលិតផលកសិកម្ម។ សមត្ថភាពខ្សោយរបស់សហគ្រាសកម្ពុជា នាំឲ្យពួកគេលំបាកនឹងរីកលូតលាស់បានឆាប់រហ័ស។ ដូច្នេះក្នុងពេលខាងមុខនេះ ជាការប្រសើរគួរអភិវឌ្ឍអង្គការកសិករ ព្រោះបទពិសោធន៍នៅអន្តរជាតិបង្ហាញថា អង្គការកសិករសំខាន់ណាស់សម្រាប់ជួយទ្រទ្រង់ឲ្យការធ្វើកសិកម្មតាមកិច្ចសន្យាមានចីរភាពល្អ។

រដ្ឋាភិបាលគួរយកចិត្តទុកដាក់លើគោលនយោបាយសម្រាប់ការអភិវឌ្ឍនិងការពារទីផ្សារ និង សហប្រតិបត្តិការធ្វើវិនិយោគ ជាជាងការផ្តល់ឧបត្ថម្ភធនដល់ផលិតកម្ម។

# ឯកសារយោង

ADB. 2014. “Key Indicators for Asia and the Pacific 2014.” Asian Development Bank. https://www.adb.org/publications/key-indicators-asia-and-pacific-2016.

AusAid, and World Bank. 2012. “TURNING CAMBODIAN RICE INTO WHITE GOLD.” Washington, DC. https://openknowledge.worldbank.org/bitstream/handle/10986/22533/Cambodia000Ric0rice0into0white0gold.pdf?sequence=1&isAllowed=y.

CARDI. 2011. “Rice Varieties Released by the Varietal Recommendation Committee of Cambodia (1990 - 2000).” Cambodia Agricultural Research and Development Institute.

Dang, Kim Son. 2014. “Agriculture Sector Structure and Restructuring.” Power Point Slide presented at the LMPPI Inception Workshop, Ho Chi Minh, Vietnam, November 13.

Dwight, Wilder, and Tran Quan. 2014. “Grain and Feed Annual Report.” USDA-United States Department of Agriculture. https://gain.fas.usda.gov/Recent%20GAIN%20Publications/Grain%20and%20Feed%20Annual_Hanoi_Vietnam_4-8-2014.pdf.

ILO. 2014. *Key Indicators of the Labour Market (KILM)* (version Eighth Edition). Geneva: International Labour Organization.

IRRA (Catographer). 2010. “Crop Area Map of Cambodia in 2010.” IRRA.

MAFF. 2015a. “Agriculture Extension Policy in Cambodia.” Ministry of Agriculture, Forestries, and Fisheries.

———. 2015b. “Annual Report.” Ministry of Agriculture, Forestries, and Fisheries.

———. 2015c. “Agricultural Sector Strategic Development Plan 2014-2018.” Ministry of Agriculture, Forestries, and Fisheries.

———. 2016. “Annual Report.” Ministry of Agriculture, Forestries, and Fisheries.

RGC. 2013. “Rectangular Strategy for Growth Employment, Equity and Efficiency Phase III.” Royal Government of Cambodia.

SNEC. 2010. “Policy Document on the Promotion of Paddy Rice Production and Export of Milled Rice.” Surprime National Economic Councils.

Tran, Cong Thang, and Bao Linh Dinh. 2015. “Rice Policy Review in Vietnam.” *FFTC Agricultural Policy Platform (FFTC-AP)*. April 13. http://ap.fftc.agnet.org/ap_db.php?id=406.

Tran, Cong Thang, and Le Hoa Nguyen. 2015. “Restructuring Crop Production In Vietnam.” *FFTC Agricultural Policy Platform (FFTC-AP)*. June 23. http://ap.fftc.agnet.org/ap_db.php?id=457.

Tran, Cong Thang, and Huy Phuc Vu. 2016. “Vietnam’s Rice Policy Review.” *FFTC Agricultural Policy Platform (FFTC-AP)*. October 31. http://ap.fftc.agnet.org/ap_db.php?id=704.

UN Comtrade. 2017. “Download Trade Data | UN Comtrade: International Trade Statistics.” Accessed January 5. https://comtrade.un.org/data/.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ១៖ ការប្រមូលទិន្នន័យ និងការជ្រើសយកសំណាក

ការប្រមូលទិន្នន័យនៅកម្ពុជា: វិធីសាស្ត្របរិមាណវិស័យ កម្រងសំណួរសម្រាប់គ្រួសារ

រូបភាពA1: ផែនទីតំបន់សិក្សា




កម្រងសំណួរបែបបរិមាណវិស័យមានការរចនារៀបចំស្របតាម គោលដៅនៃការសិក្សានេះ។ ដោយសារការស្រាវជ្រាវផ្តោតលើភាគអាគ្នេយ៍ប្រទេសកម្ពុជាជាប់ព្រំប្រទល់ជាមួយវៀតណាម គេបានជ្រើសយកសម្រាប់ការប្រមូលទិន្នន័យនូវខេត្តបីគឺ តាកែវ ព្រៃវែង និង ស្វាយរៀង ដែលតាំងពីដើមរៀងមកតែងមានជំនួញស្រូវទាំងផ្លូវការ និងក្រៅផ្លូវការជាមួយវៀតណាម ជាពិសេសស្រូវអង្កររដូវប្រាំង។

ក្រុមស្រាវជ្រាវនេះបានជ្រើសរើសដោយចៃដន្យ៦០០គ្រួសារ មកធ្វើសម្ភាសន៍ឬ២០០គ្រួសារក្នុងខេត្តនីមួយៗ។ ការជ្រើសយកសំណាក មានពីរជំហាន។ ទី១ ស្រុក ៥ ត្រូវបានជ្រើសរើសដោយមានគោលដៅពីខេត្តនីមួយៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃ ការដាំស្រូវជាបន្តមានការស្រោចស្រព ការដាំស្រូវពីរដងមានការស្រោចស្រព ការដាំស្រូវមួយដងមានការស្រោចស្រព និងការដាំស្រូវពឹងលើទឹកភ្លៀង ដោយប្រើមូលដ្ឋានទិន្នន័យផែនទី (IRRA 2010)។ ស្រុកមានការស្រោចស្រពតែងដាំស្រូវប្រាំង រីឯស្រុកដាំស្រូវមួយដងពឹងលើទឹកភ្លៀងតែងដាំស្រូវវស្សា។ ទោះបីការសិក្សានេះផ្តោតលើស្រូវប្រាំងក្តី ក៏ក្រុមស្រាវជ្រាវបានព្យាយាមធ្វើសម្ភាសន៍កសិករដាំស្រូវវស្សាដែរ សម្រាប់ធ្វើការប្រៀបធៀប។ តាមនេះ មានការជ្រើសយក ៣ ស្រុកដាំស្រូវប្រាំង និង ២ ស្រុកដាំស្រូវវស្សា ពីក្នុងខេត្តនីមួយៗ។[7] ទី២ ក្នុងស្រុកដាំស្រូវប្រាំងនីមួយៗ មានការជ្រើសយក ២ ភូមិដោយចៃដន្យ ហើយក្នុងស្រុកដាំស្រូវវស្សានីមួយៗ មានការជ្រើសយក

7 មានស្រុកមួយទៀត និងភូមិមួយទៀតក្នុងខេត្តព្រៃវែង ដែលក្រុមស្រាវជ្រាវបានជ្រើសយកបន្ថែមក្នុងពេលធ្វើអង្កេត ព្រោះបានដឹងថា កសិករនៅភូមិមួយនៅស្រុកពាមជរ មិនដាំស្រូវប្រាំងទេ។

ភូមិដាំស្រូវវស្សាមួយ និងភូមិដាំស្រូវប្រាំងមួយ។ ប៉ុន្តែដោយអង្កេតដល់កន្លែងបង្ហាញថា កសិករនៅក្នុងភូមិដាំស្រូវប្រាំងមួយ ក្នុងស្រុកដាំស្រូវប្រាំងមួយ (ពាមជរ) មិនមានដាំស្រូវប្រាំងនោះ ក្រុមស្រាវជ្រាវក៏បានជ្រើសយកថែមទៀតនូវ ភូមិមួយទៀត ក្នុងស្រុកមួយទៀត នៅខេត្តព្រៃវែង។

ចំនួនគ្រួសារធ្វើសម្ភាសន៍ ត្រូវបានជ្រើសយកស្មើៗគ្នានិងដោយចៃដន្យពីក្នុងភូមិទាំង១០ ពោលគឺ ២០គ្រួសារក្នុងមួយភូមិ ត្រូវជា ២០០គ្រួសារក្នុងមួយខេត្ត ឬ ៦០០គ្រួសារក្នុងទាំងបីខេត្ត។ ក្នុងពេលចុះធ្វើការដល់កន្លែង អ្នកធ្វើអង្កេតដែលស្ថិតក្រោមការត្រួតពិនិត្យដោយផ្ទាល់ពីក្រុមស្រាវជ្រាវCDRI បានជ្រើសរើសគ្រួសារដោយចៃដន្យក្នុងភូមិនីមួយៗ។

តារាងA1៖ ការជ្រើសយកសំណាកសម្រាប់សម្ភាសន៍គ្រួសារ

| ខេត្ត | ស្រុក | ឃុំ | ភូមិ | គ្រួសារ |
|---|---|---|---|---|
| ព្រៃវែង | កំចាយមារ | ក្រញូង | អង្រ្គងទី២ | 20 |
| | | ស្មោងជើង | ធ្នង់ខាងលិច | 20 |
| | កំពង់ត្របែក | ពាមមន្ទារ | តាកែវ | 20 |
| | | ប្រាសាទ | ចំបក់ | 20 |
| | ពាមជរ | កោះចេក | ស្ពាន | 20 |
| | ពារាំង | ព្រៃញ្ញៅ | សំរាប | 20 |
| | | ព្រៃស្មៀត | ព្រៃស្មៀត | 20 |
| | ព្រះស្តេច | ព្រះស្តេច | អន្លង់ចារ | 20 |
| | | សេនារាជឧត្តម | សំនយ | 20 |
| | ស្វាយអន្ទរ | អង្គរទ្រេត | អង្គរទ្រេត | 20 |
| ស្វាយរៀង | ចន្ទ្រា | សំរោង | ចេក | 20 |
| | | ទួលស្តី | ទួលស្តី | 20 |
| | កំពង់រោទិ៍ | សំយ៉ោង | ឫស្សីលៀប | 20 |
| | | ថ្មី | ជប់ព្រីង | 20 |
| | រមាសហែក | កំពង់ត្រាច | តាខុប | 20 |
| | | ម្រាម | ម្រាមខាងជើង | 20 |
| | ស្វាយជ្រុំ | តាសួស | តាប៉ | 20 |
| | | ស្វាយធំ | ចំរេះ | 20 |
| | ស្វាយទៀប | ពពែក | ស្វាយគយ | 20 |
| | | រមាំងថ្កោល | ក្រញូង | 20 |
| តាកែវ | អង្គរបុរី | បាស្រែ | ពួនកក | 20 |
| | | ព្រៃផ្គាំ | ព្រៃផ្គាំ គ | 20 |
| | បូរីជលសា | ដូងខ្ពស់ | ដូងខ្ពស់ | 20 |
| | | គោកពោធិ៍ | កំពង់យោល | 20 |
| | គិរីវង់ | សោម | ដើមរំដែល | 20 |
| | | សោម | ពងទឹក | 20 |
| | កោះអណ្តែត | ក្រពុំឈូក | ត្រពាំងតាអ៊ុយ | 20 |
| | | ព្រៃខ្លា | ជំរុំ | 20 |
| | ទ្រាំង | សំបួរ | ព្រៃផ្តៅ | 20 |
| | | ធ្លក | ស្វាយ | 20 |
| **សរុប** | | | | **600** |

### សម្ភាសន៍អ្នកផ្តល់ព័ត៌មានគន្លឹះ នៅផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃស្រូវ

ទីប្រឹក្សាស្រាវជាវពីរនាក់មកពី CPS បានធ្វើសម្ភាសន៍ KIIs ជាមួយ រោងម៉ាស៊ីនកិនស្រូវ អ្នកនាំចេញ សមាគមកិនស្រូវ មន្ត្រីរដ្ឋាភិបាល (MAFF, NSEC, MoC ...) ដើម្បីប្រមូលព័ត៌មានស្តីពីផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃស្រូវ។ អ្នកស្រាវជ្រាវនៃ CDRI ក៏មានចូលរួមធ្វើសម្ភាសន៍ទាំងនេះដែរតាមការចាំបាច់។ CPS បានសហការជាមួយ CDRI រចនារៀបចំ KIIs ឡើង ដោយបានជ្រើសរើសអ្នកផ្តល់ព័ត៌មានគន្លឹះមានបទពិសោធន៍ ចំណេះដឹងជ្រៅជ្រះក្នុងវិស័យស្រូវអង្ករនៅប្រទេសកម្ពុជា ចំនួន ១០នាក់មកធ្វើសម្ភាសន៍។ សំណាក ចែកចេញជាបីក្រុម៖ សមាគមស្រូវ និងដៃគូអភិវឌ្ឍន៍នានា, ស្ថាប័នសាធារណៈ, និងរោងម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញ។ សំណាកនេះ បានរចនារៀបចំឡើងដើម្បីដាក់បញ្ចូលអ្នកដើរតួនាទីសំខាន់ៗដែលអាចប្រមើលឃើញពីផលប៉ះពាល់ទៅលើកសិករនៃ ការផ្លាស់ក្នុងបទបញ្ញត្តិច្បាប់ និងការកសាងនិងអនុវត្តជាក់ស្តែងនូវគោលនយោបាយ។ សម្ភាសន៍នីមួយៗមានរយៈពេលប្រមាណ ៩០នាទី ធ្វើទល់មុខគ្នាមានលំនាំដូចការជួបពិភាក្សា និងធ្វើមួយលើកចប់។ អ្នកសួរសម្ភាសន៍មានពីរនាក់ ដែលផ្លាស់ប្តូរគ្នាធ្វើការកត់ត្រា និងសួរសំណួរ។ មិនមានការផ្តល់សំណួរឲ្យ មុនពេលជួបសម្ភាសន៍ទេ។

តារាងA2៖ បញ្ជីអ្នកឆ្លើយសម្ភាសន៍សម្រាប់ផ្នែកខាងលើនៃខ្សែសង្វាក់តម្លៃស្រូវ

| ប្រភេទ | | អ្នកឆ្លើយសម្ភាសន៍ | ឆ្នាំបង្កើត |
|---|---|---|---|
| សមាគមរោងម៉ាស៊ីនកិនស្រូវ និងដៃគូអភិវឌ្ឍន៍ | | | |
| 1 | សហព័ន្ធស្រូវកម្ពុជា | លោក សុខ ពុទ្ធីវុធ (ប្រធាន) | 2014 |
| 2 | កម្មវិធីខ្សែសង្វាក់តម្លៃស្រូវកម្ពុជា (CAVAC) | លោក Pieter Ypma (អ្នកគ្រប់គ្រងកម្មវិធី) | 2010 |
| ស្ថាប័នសាធារណៈ | | | |
| 3 | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | លោក ងិន ឆាយ (ប្រធាននាយកដ្ឋានដំណាំស្រូវ) | NA |
| 4 | ក្រសួងពាណិជ្ជកម្ម | ឯ.ឧ ថាវ សុខមុនី ជំនួយការរដ្ឋមន្ត្រី | NA |
| រោងម៉ាស៊ីនកិនស្រូវ/អ្នកនាំចេញ | | | |
| 5 | អង្គរអប្សរា | លោក អ៊ិត វិចិត្រ (អតីតនាយក) | 2014 |
| 6 | Boost Riche Cambodia | លោក David Van (នាយក) | 2014 |
| 7 | Crystal Rice Kampuchea | លោក ថាប ម៉ារ៉ែន និង លោក ស៊ឹម សុភា (អ្នកគ្រប់គ្រងរដ្ឋបាល និងអ្នកគ្រប់គ្រងផ្សាយលក់) | 2014 |
| 8 | ហ្គោលដិនដូនកែវរ៉ាយស៍ | (អ្នកគ្រប់គ្រងផ្នែកនាំចេញ) | 2012 |
| 9 | ហ្គោលដេនរ៉ាយស៍ | លោក សុក ហាច (អគ្គនាយក) | 2009 |
| 10 | Signatures of Asia | លោក ចាន់ វណ្ណៈ (អគ្គនាយក) | 2013 |

### សម្ភាសន៍ *KIIs* ជាមួយផ្នែកខាងចនៃខ្សែសង្វាក់តម្លៃស្រូវ និង *FGDs*

ក្រុមស្រាវជ្រាវ CDRI បានធ្វើ ១៥ សម្ភាសន៍ KIIs ជាមួយបីផ្នែកសំខាន់ៗ នៅក្នុងតំបន់សិក្សា។ ទី១ បានធ្វើ KII ជាមួយ មន្ត្រីម្នាក់នៃមន្ទីរកសិកម្មខេត្តនីមួយៗ និងមន្ទីរពាណិជ្ជកម្មខេត្តនីមួយៗ ដែលជាស្ថាប័នចម្បងពីរមានទំនួលខុសត្រូវដោយផ្ទាល់ក្នុងការលើកកម្ពស់ផលិតកម្មស្រូវអង្ករនិងទីផ្សារអង្ករ (សរុប ៦ KIIs)។ ទី២ ក្រុមស្រាវជ្រាវ CDRI បានធ្វើសម្ភាសន៍ជាមួយរោងម៉ាស៊ីនកិនស្រូវពីរក្នុងខេត្តនីមួយៗ ដើម្បីបានព័ត៌មានពីសមត្ថភាពកិនស្រូវ និងលទ្ធភាពទិញស្រូវរបស់ពួកគេ ហើយបានយល់ដឹងកាន់តែច្បាស់ពីស្ថានភាពពិតក្នុងតំបន់សិក្សា។ ទី៣ បានធ្វើសម្ភាសន៍ជាមួយឈ្មួញស្រូវម្នាក់ក្នុងខេត្តនីមួយៗ (សរុប ៣នាក់) ដែលមានបទពិសោធន៍ធ្វើជំនួញជាមួយវៀតណាម។

ដើម្បីទទួលបានព័ត៌មានស៊ីជម្រៅគុណវិស័យលើតំបន់សិក្សា ក្រុមស្រាវជ្រាវ CDRI ក៏បានធ្វើការពិភាក្សាតាមក្រុមស្នូល (FGD) ៣ លើកក្នុងខេត្តនីមួយៗ (សរុប ៩ FGDs)។ ក្នុង FGD នីមួយៗ មានកសិករចូលរួមយ៉ាងហោចណាស់ ៨នាក់។

តារាងA3៖ សម្ភាសន៍ KIIs និង FDGs នៅក្នុងតំបន់សិក្សា

| ប្រភេទ | | ចំនួនអ្នកឆ្លើយសម្ភាសន៍ | សរុប |
|---|---|---|---|
| KIIs | | | |
| 1 | មន្ទីរពាណិជ្ជកម្មខេត្ត | មួយនាក់ក្នុងខេត្តនីមួយៗ | 3 |
| 2 | មន្ទីរកសិកម្មខេត្ត | មួយនាក់ក្នុងខេត្តនីមួយៗ | 3 |
| 3 | ម្ចាស់រោងម៉ាស៊ីនកិនស្រូវ | ពីរនាក់ក្នុងខេត្តនីមួយៗ | 6 |
| 4 | ឈ្មួញស្រូវនិងអង្ករ | មួយនាក់ក្នុងខេត្តនីមួយៗ | 3 |
| FGDs | | | |
| | FGDs | បី FGDs ក្នុងខេត្តនីមួយៗ | 9 |

### *ការប្រមូលទិន្នន័យនៅវៀតណាម: KIIs ជាមួយតំណាងនៃវិស័យសាធារណៈ និងក្រុមផ្តល់គំនិតផ្នែកស្រាវជ្រាវ*

ដោយមានការជួយសម្របសម្រួលពី LMPPI អ្នកស្រាវជ្រាវពីរនាក់ (មកពី CDRI ម្នាក់ និង CPS ម្នាក់) បានទៅវៀតណាមដើម្បីធ្វើសម្ភាសន៍ KIIs ជាមួយអ្នកកសាងគោលនយោបាយនិងអ្នកស្រាវជ្រាវវៀតណាម។ ក្រុមស្រាវជ្រាវ CDRI ទទួលបន្ទុករចនារៀបចំកម្រងសំណួរ KIIs។ LMPPI បានរៀបចំការជួបសម្ភាសន៍ផ្លូវការបីលើក និងការហូបអាហារថ្ងៃត្រង់ធ្វើការមួយលើក នៅក្រុងហាណូយ។ បណ្ឌិត Nguyen Van Giap ជាអ្នកស្រាវជ្រាវនៃ LMPPI បានជូនដំណើរអ្នកស្រាវជ្រាវមកពីកម្ពុជាទាំង ២ នាក់ទៅក្រុងហាណូយ ហើយពួកគេបានចំណាយពេលពេញមួយថ្ងៃនៅទីនោះដើម្បីជួបអ្នកពាក់ព័ន្ធទាំងបីប្រភេទ។ ជំនួបនានាបានប្រព្រឹត្តទៅក្នុងបរិយាកាសមិត្តភាព ដោយបានលទ្ធផលល្អ និងព័ត៌មានច្រើន។ ជាក់ស្តែងមានការចែករំលែកគ្នានូវ ព័ត៌មានលំអិតជាច្រើនទាក់ទងនឹង គោលនយោបាយ ផលិតកម្ម និងទីផ្សារកសិកម្មនិងស្រូវអង្ករ នៅវៀតណាម និងកម្ពុជា។

តារាងA4៖ សម្ភាសន៍ជាមួយវិស័យសាធារណៈនៅវៀតណាម

| អ្នកឆ្លើយសម្ភាសន៍ | មុខងារ | ស្ថាប័ន | ជំនួប |
|---|---|---|---|
| លោកស្រី Pham Thi Kim Dung | អ្នកស្រាវជ្រាវ | IPSARD | KII និងការពិភាក្សា |
| បណ្ឌិត Tran Cong Thang | អគ្គនាយករង | IPSARD | បទបង្ហាញ, KII, និងការពិភាក្សា |
| បណ្ឌិត Dang Kim Sun | អគ្គនាយក | IPSARD | អាហារថ្ងៃត្រង់ធ្វើការ និងការពិភាក្សា |

### *KII ជាមួយវិស័យឯកជន*

ក្រុមស្រាវជ្រាវនៃសាកលវិទ្យាល័យ AGU ដឹកនាំដោយ បណ្ឌិត Kien Van Nguyen បានជួយជ្រោមជ្រែងក្រុមស្រាវជ្រាវ CDRI ក្នុងការសិក្សាស្រាវជ្រាវនៅវៀតណាម។ អ្នកផ្តល់ព័ត៌មានគន្លឹះនៅវៀតណាមចែកចេញជា ៣ ក្រុម៖ អ្នកផលិតស្រូវអង្ករ ឈ្មួញស្រូវអង្ករ និង អ្នកនាំចេញអង្ករ។ CDRI ទទួលបន្ទុករចនារៀបចំកម្រងសំណួរ KII។ ក្រុម AGU ទទួលបន្ទុកបកប្រែកម្រងសំណួរ KII ពីអង់គ្លេសទៅវៀតណាម និងអនុវត្ត ១១ សម្ភាសន៍ គឺមាន ៥ KIIs ជាមួយអ្នកផលិតស្រូវអង្ករ ៣ KIIsជាមួយឈ្មួញស្រូវអង្ករ និង ៣ KIIs ជាមួយអ្នកនាំចេញអង្ករ។

# ឧបសម្ព័ន្ធ២
# គោលនយោបាយកសិកម្ម និងគោលនយោបាយស្រូវវៀតណាម

កសិកម្មបានដើរតួនាទីគួរឲ្យកត់សម្គាល់ក្នុង សេដ្ឋកិច្ចវៀតណាម។ ផលិតកម្មស្រូវអង្ករបានរួមចំណែកយ៉ាងច្រើនដល់ ការរីកលូតលាស់វិស័យនេះ។ ដំណាំស្រូវជាប្រភពចំណូលចម្បងសម្រាប់ប្រជាជននៅតាមជនបទ ព្រោះ ៧០% នៃគ្រួសារនៅជនបទ (ប្រមាណ ៩ លានគ្រួសារ) ធ្វើការដាំដុះស្រូវ។ តាំងពីទសវត្សរ៍១៩៨០ មក ដោយមានគោលដៅចិញ្ចឹមប្រជាជនយ៉ាងច្រើន (ជាង ៥០ លាននាក់ក្នុងទសវត្សរ៍១៩៨០ និងប្រមាណ ៩៣ លាននាក់ក្នុងឆ្នាំ២០១៦) គោលនយោបាយស្រូវពីមុនបានផ្តល់អាទិភាពលើផលិតកម្មស្រូវ ដោយផ្តោតខ្លាំងលើបរិមាណ និងពូជស្រូវមានទិន្នផលខ្ពស់។ វិនិយោគលើប្រព័ន្ធស្រោចស្រពជា ចំណុចផ្តោតចម្បងមួយរបស់រដ្ឋាភិបាលវៀតណាមនៅពេលនោះ។ បន្ទាប់ពីបានដាំដុះស្រូវតាមបែបប្រពលវប្បកម្មប្រមាណ ៣ ទសវត្សរ៍កន្លងមក វៀតណាមបានក្លាយជាប្រទេសនាំចេញអង្ករនាំមុខគេក្នុងពិភពលោក។ ប៉ុន្តែក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ផលិតកម្ម និងទិន្នផលស្រូវ មិនមានកំណើនទៀតទេ។ ការរេចរឹលអស់ធនធានធម្មជាតិ ការបំពុលបរិស្ថាន សមត្ថភាពប្រកួតប្រជែងខ្សោយ ការផ្លាស់ប្តូរតម្រូវការនៅអន្តរជាតិនិងក្នុងស្រុក ឧស្សាហូបនីយកម្មយ៉ាងលឿន នគរូបនីយកម្ម ការប្រែប្រួលអាកាសធាតុ ជាកត្តាសំខាន់ៗជំរុញឲ្យវៀតណាមរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសេដ្ឋកិច្ច និងគោលនយោបាយកសិកម្មរបស់ខ្លួន (Dang 2014)។

បណ្ឌិត Dang Kimsun ក្នុងបទបង្ហាញរបស់ខ្លួនស្តីពី រចនាសម្ព័ន្ធវិស័យកសិកម្ម និងការរៀបចំវាឡើងវិញ (២០១៤) បានគូសបញ្ជាក់ថា មានការរៀបចំគួរឲ្យកត់សម្គាល់ឡើងវិញនូវវិស័យកសិកម្មវៀតណាម គឺមានតាំងពី ដំណាំ សត្វចិញ្ចឹម ជលវប្បកម្ម ព្រៃឈើ ផលិតកម្មអំបិល រហូតដល់ ការកែច្នៃស្បៀងអាហារ និងឧស្សាហកម្មនៅជនបទ។ ដោយសារមានការប្រកួតប្រជែងយ៉ាងតឹងតែង និងការផ្លាស់ប្តូរយ៉ាងលឿននៃតម្រូវការពិភពលោក វៀតណាមមិនអាចផ្តោតតែលើផលិតកម្មស្រូវអង្ករមួយមុខបានទេ ប៉ុន្តែត្រូវកែតម្រូវទៅតាមទីផ្សារ។ ដូច្នេះត្រូវមានគោលនយោបាយជាប្រព័ន្ធ តាំងពី ការផ្គត់ផ្គង់ធាតុចូល ការដាំដុះស្រូវ ការកែច្នៃ ការស្តុក និងការធ្វើពាណិជ្ជកម្ម ដែលសុទ្ធតែជា ផ្នែកសំខាន់ៗនៃការរៀបចំគោលនយោបាយកសិកម្មឡើងវិញ។

ខ្លឹមសារនៃគម្រោងការរៀបចំវិស័យកសិកម្មឡើងវិញ

| |
|---|
| រៀបចំដំណាំដាំដុះឡើងវិញ: ផ្តោតលើ ការអភិវឌ្ឍផលិតកម្ម ការធ្វើកសិកម្មខ្នាតធំជាលក្ខណៈប្រមូលផ្តុំ និងមានគួបផ្សំដោយការកែច្នៃ ការស្តុក និងការធ្វើពាណិជ្ជកម្ម។ |
| រៀបចំការចិញ្ចឹមសត្វឡើងវិញៈ ផ្តោតលើ ការធ្វើកសិកម្មជាលក្ខណៈប្រមូលផ្តុំ កសិដ្ឋានធំៗតាមគ្រួសារ កសិដ្ឋានធំៗផ្សេងទៀត ការអនុវត្តប្រើ វិទ្យាសាស្រ្តនិងបច្ចេកវិទ្យា(S&T) និង ការធានាសុវត្ថិភាពស្បៀងអាហារ។ |
| រៀបចំជលវប្បកម្មឡើងវិញៈ ផ្តោតលើ កសិកម្មបែបប្រពលវប្បកម្មដោយមានផលិតផលសំខាន់ៗ អនុវត្តស្តង់ដាអន្តរជាតិ លើកកម្ពស់ការនេសាទតាមសមុទ្រ។ |
| រៀបចំផ្នែកព្រៃឈើឡើងវិញៈ ផ្តោតលើ ការបង្កើនតម្លៃសេដ្ឋកិច្ច ដោយមានការអភិរក្សព្រៃឈើ ការការពារបរិស្ថាននិងជីវៈចម្រុះ និងការសម្របខ្លួនតាមការប្រែប្រួលអាកាសធាតុ។ |
| រៀបចំផលិតកម្មអំបិលឡើងវិញៈ ផ្តោតលើ ផលិតកម្មខ្នាតឧស្សាហកម្ម យន្តកម្ម ប្រព័ន្ធស្វ័យប្រវត្ត និងការកែលំអគុណភាពនិងប្រសិទ្ធភាព។ |
| រៀបចំឧស្សាហកម្មកែច្នៃ និងឧស្សាហកម្មជនបទឡើងវិញៈ ផ្តោតលើ ការបង្កើនតម្លៃបន្ថែម និងការពារបរិស្ថាននៅជនបទ។ |

ប្រភព៖ Dang 2014; Decision 899/QĐ-TTg dated 10 June 2013

បណ្ឌិត Tran Cong Thang, Vu Huy Phuc, Dinh Thi Bao, និង Nguyen Le Hao បានបោះពុម្ពផ្សាយអត្ថបទបីក្នុងឆ្នាំ២០១៥ និង២០១៦ ដែលពិនិត្យបូកសរុបឡើងវិញពី គោលនយោបាយកសិកម្មនិងស្រូវ នៅវៀតណាម។ ឯកសារទាំងនេះបានព្យាយាមបូកសរុបសេចក្ដីសម្រេច និង គោលនយោបាយទាំងអស់ ដែលជះឥទ្ធិពលដោយផ្ទាល់ និងដោយប្រយោលទៅលើការអភិវឌ្ឍវិស័យស្រូវនៅវៀតណាម ហើយបានបង្ហាញពីការយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើវិស័យកសិកម្ម ជាពិសេស វិស័យស្រូវ។ គោលនយោបាយគាំទ្រជាច្រើនក៏ត្រូវបានអនុម័តចេញ និងធ្វើបច្ចុប្បន្នភាពជាបន្តបន្ទាប់ ដើម្បីគាំទ្រដល់វិស័យនេះ និងដោះស្រាយបញ្ហាប្រឈមផ្សេងៗ។ ឯកសារក៏បានគូសបញ្ជាក់ពី ចំណុចខ្លាំង និងចន្លោះខ្វះខាតនៃគោលនយោបាយទាំងនេះដែរ។ ជាទូទៅអ្នកនិពន្ធបានធ្វើចំណាត់ថ្នាក់គោលនយោបាយវៀតណាមជាបីប្រភេទ គឺមាន ផលិតកម្មស្រូវអង្ករ ពាណិជ្ជកម្មស្រូវអង្ករ ការអភិវឌ្ឍខ្សែសង្វាក់តម្លៃ។ ផ្នែកខាងក្រោមនេះជា សេចក្ដីសង្ខេបនៃការពិនិត្យបូកសរុប ក្នុងឯកសារទាំងបី៖

**គោលនយោបាយផលិតកម្មស្រូវអង្ករ៖** ដើម្បីសម្រេចបានសន្តិសុខស្បៀង និងគោលដៅនាំចេញ រដ្ឋាភិបាលវៀតណាមបានសម្រេចចិត្តរក្សាទុកដីកសិកម្មនៅត្រឹមប្រមាណ ៤ លានហិកតា។ តាមនេះ រដ្ឋាភិបាលបានលៃចែកថវិកាសម្រាប់ផលិតកម្មស្រូវបានធ្វើឯកទេសកម្ម (២២ដុល្លារ/ហិកតា/ឆ្នាំ) និង ផលិតកម្មស្រូវតាមធម្មតា (៤,៤ដុល្លារ/ហិកតា/ឆ្នាំ)។ សម្រាប់វិស័យនេះ ក៏មានការធ្វើវិនិយោគធំៗសម្បើមទៅលើហេដ្ឋារចនាសម្ព័ន្ធនៅជនបទ ដូចជា ប្រព័ន្ធស្រោចស្រព និងផ្លូវថ្នល់ ជាដើម រហូតដល់ ១៧៥,៤៤ លានដុល្លារក្នុងឆ្នាំ២០០៩ និង ប្រមាណ ៨៧,៧២លានដុល្លារ/ឆ្នាំ ចាប់តាំងពីឆ្នាំ២០១០ មក។ ដើម្បីលើកទឹកចិត្តសហគ្រាសឯកជនឲ្យធ្វើវិនិយោគកាន់តែច្រើន រដ្ឋាភិបាលវៀតណាមទទួលចេញ ២០% នៃថ្លៃឈ្នួលដី និងចំណាយធ្វើការផ្គត់ផ្គង់ទឹក ក្នុងរយៈពេលប្រាំឆ្នាំដំបូង បន្ទាប់ពីមានការសាងសង់ជាមូលដ្ឋាន។ ទឹកសម្រាប់កសិកម្មមិនមានការគិតថ្លៃទេនៅវៀតណាម។ រដ្ឋាភិបាលបានលើកលែងបុគ្គលនិងគ្រួសារនានាពីកាតព្វកិច្ចបង់ថ្លៃទឹកកសិកម្ម ហើយត្រូវចំណាយថវិការដ្ឋ និងថវិកាខេត្តប្រមាណ ២៨០,៧០៤ លានដុល្លារ/ឆ្នាំ សម្រាប់រ៉ាប់រងបន្ទុកនេះ។ ធាតុចូលនិងសម្ភារកសិកម្ម ក៏ទទួលបានជំនួយគាំទ្រពីរដ្ឋាភិបាលដែរ។ ក្នុងពេលមានគ្រោះធម្មជាតិ និងផ្ទុះជំងឺផ្សេងៗ រដ្ឋាភិបាលជួយផ្ដល់ពី ៥០ ទៅ ៧០% នៃតម្លៃសម្ភារកសិកម្ម។ រដ្ឋាភិបាលក៏ជួយរ៉ាប់រង ៧០% នៃតម្លៃរានដីក្នុងឆ្នាំដំបូង និង ១០០% នៃតម្លៃគ្រាប់ពូជ ក្នុងឆ្នាំដំបូងនៃការដាំដុះស្រូវដែរ និង ៧០% នៃចំណាយលើគ្រាប់ពូជ ក្នុងករណីមានការកែប្រែដីពីដំណាំផ្សេងៗ ទៅផលិតស្រូវវិញ។ កសិករដាំស្រូវនៅវៀតណាមអាចទទួលបានឥណទានមានការប្រាក់អនុគ្រោះពីរដ្ឋាភិបាល។ អត្រាការប្រាក់ប្រចាំឆ្នាំលើកម្ចីមិនលើសពី ៣០៧,០២ ដុល្លារ/ហិកតា សម្រាប់ការទិញធាតុចូល ដូចជា ជី ថ្នាំសម្លាប់សត្វចង្រៃ ជាដើម គឺ ៤%។ កសិករក៏អាចទទួលបានឥណទានរយៈពេលវែង (រហូតដល់ ២៤ ខែ) សម្រាប់ការទិញបរិក្ខារ និងម៉ាស៊ីនកសិកម្មដែរ។

**គោលនយោបាយពាណិជ្ជកម្មផ្នែកកសិកម្ម៖** រដ្ឋាភិបាលវៀតណាមនឹងជួយរ៉ាប់រង ៥០% នៃចំណាយផ្សព្វផ្សាយផ្នែកកសិកម្មនៅលើប្រព័ន្ធផ្សព្វផ្សាយ ៥០% នៃចំណាយតាំងពិពណ៌ និង ១០០% នៃចំណាយលើការសាងសង់ និងតុបតែងរោងនៅក្នុងពិពណ៌ពាណិជ្ជកម្ម។ ដើម្បីបង្កើនគុណភាពអង្ករនាំចេញ មានការកំណត់ស្តង់ដារខ្លះសម្រាប់ក្រុមហ៊ុននាំចេញរបស់វៀតណាម ដូចជា ក្រុមហ៊ុនត្រូវមានកន្លែងស្តុកស្របតាមជំនាញឯកទេសសម្រាប់ដាក់ស្រូវឲ្យបានចាប់ពី ៥.០០០ តោនឡើងទៅ និងមានសមត្ថភាពកិនស្រូវយ៉ាងហោចណាស់ ១០ តោន/ថ្ងៃ។ គួរកត់សំគាល់ថា រដ្ឋាភិបាលវៀតណាមបានកំណត់អត្រាពន្ធនាំចូលអនុគ្រោះ ០% សម្រាប់អង្ករ និងថ្នាំជក់គ្រប់ប្រភេទដែលនាំចូលពីកម្ពុជា និងឡាវ។ ដើម្បីគ្រប់គ្រងការឡើងចុះថ្លៃភ្លាមៗ រដ្ឋាភិបាលបានប្រកាសចេញនូវ ថ្លៃអង្ករទាបបំផុតអាចអនុវត្តបាននៅកសិដ្ឋាន និងនៅច្រកព្រំដែននាំចេញ។ ថ្លៃអង្ករទាបបំផុតនៅកសិដ្ឋាន ត្រូវបានកំណត់ឡើងដោយផ្អែកលើ បន្ទុកចំណាយផលិតស្រូវដែលប្រែប្រួលខុសគ្នាទៅតាមតំបន់ ដោយមានទុកអត្រាចំណេញ ៣០% សម្រាប់កសិករ។ ស្រដៀងគ្នាដែរ ថ្លៃទាបបំផុតសដម្រាប់អង្ករនាំចេញ ត្រូវបានកំណត់ឡើងដោយផ្អែកលើ ថ្លៃមធ្យមដែលក្រុមហ៊ុននាំចេញនានារាយការណ៍ឡើង។

**គោលនយោបាយអភិវឌ្ឍន៍ខ្សែសង្វាក់តម្លៃៈ** គោលនយោបាយនេះសំដៅជំរុញផលិតកម្មខ្នាតធំ ការអភិវឌ្ឍសហគ្រាស ការគាំទ្រអង្គការកសិករ និងកិច្ចសន្យានាំចេញកសិផល។ រដ្ឋាភិបាលវៀតណាម ផ្តល់ជំនួយគាំទ្រចំនួនមួយលើកសម្រាប់ការទិញគ្រាប់ពូជមានការបញ្ជាក់គុណភាពត្រឹមត្រូវ (ជំនួយអតិបរមាត្រឹម ៣០% នៃតម្លៃគ្រាប់ពូជ) និងសម្រាប់ការស្តុកទុកបីខែ (១០០% នៃបន្ទុកចំណាយ)។ រដ្ឋាភិបាលវៀតណាមក៏ជួយគាំទ្រសហគ្រាស ដោយលើកលែងនូវការបង់កម្រៃ/ឈ្នួល លើការប្រើប្រាស់ដីសម្រាប់បង្កើតរោងចក្រកែច្នៃកសិផល ឃ្លាំង និងផ្ទះសម្រាប់កម្មករកសិកម្ម។ គោលនយោបាយនេះ ក៏មានការជួយរ៉ាប់រង ៥០% នៃចំណាយសម្រាប់ការបណ្តុះបណ្តាលកសិករដែរ។ ទោះយ៉ាងនេះក្តី សហគ្រាសត្រូវមានកិច្ចសន្យាជាមួយសហគ្រាសមួយផ្សេងទៀត ដើម្បីធ្វើការផ្គត់ផ្គង់ធាតុចូល និងសម្ភារកសិកម្មដល់កសិករក្នុងគម្រោងប្រើដីធំដែរ។

## *ការរៀបចំដំណាំឡើងវិញ*

គួរកត់សម្គាល់ថា ការខូចរេចរឹលគុណភាពដីបន្ទាប់ពីមានការធ្វើកសិកម្មបែបប្រពលវប្បកម្មជាយូរឆ្នាំ និងការប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វចង្រៃច្រើនលើសកម្រិត ក៏ដូចជាការផ្លាស់ប្តូរតម្រូវការក្នុងពិភពលោក និងក្នុងស្រុក បានជំរុញរដ្ឋាភិបាលវៀតណាមឲ្យផ្តល់អាទិភាពខ្ពស់ដល់គុណភាពស្រូវអង្ករ ជាជាងបរិមាណ។ ការផ្លាស់ប្តូរផលិតកម្មចេញពីពូជស្រូវមានតម្លៃទាប (គុណភាពទាប) ទៅពូជស្រូវមានតម្លៃខ្ពស់ (ស្រូវក្រអូប ឬ ស្រូវដំណើប) គឺជាអាទិភាពកំពូលមួយសព្វថ្ងៃនេះ។ ទោះបីពូជស្រូវគុណភាពខ្ពស់មានទិន្នផលទាបជាងពូជស្រូវគុណភាពទាបក្តី ប៉ុន្តែវាមានថ្លៃខ្ពស់ជាងច្រើននៅលើទីផ្សារក្នុងស្រុក និងអន្តរជាតិ។ ចំណុចសំខាន់មួយទៀត ពូជស្រូវគុណភាពខ្ពស់ ត្រូវការជីគីមីនិងថ្នាំសម្លាប់សត្វចង្រៃតិចជាង ដូច្នេះអាចកាត់បន្ថយទាំងចំណាយផលិតកម្ម និងការខូចខាតដល់បរិស្ថាន។

Tran and Nguyen (2015) ក្នុងអត្ថបទស្តីពីការរៀបចំផលិតកម្មដំណាំឡើងវិញនៅវៀតណាម បានគូសបញ្ជាក់ពីសារៈសំខាន់នៃការរៀបចំផលិតកម្មដំណាំក្នុងប្រទេសឡើងវិញ ក្រោយពីបានផ្តោតលើបរិមាណជាយូរឆ្នាំតាមការប្រើប្រាស់ច្រើនៗនូវវត្ថុធាតុគីមីកសិកម្ម។ ផលិតកម្មដំណាំលើដីស្រែពីបុរាណត្រូវតែធ្វើពិពិធកម្ម ដើម្បីឲ្យកសិករអាចរកចំណូលបានកាន់តែច្រើន និងកែលំអជីវភាពរបស់ខ្លួន។ មកទល់បច្ចុប្បន្ន មានគោលនយោបាយមួយចំនួនបានអនុម័តនិងដាក់អនុវត្តរួចហើយ ទោះបីនៅមានបញ្ហាខ្លះក្នុងការអនុវត្តក្តី ដូចជា គោលនយោបាយ លើកទឹកចិត្តឲ្យកសិករដាំ និងវិនិយោគបន្ថែមលើដំណាំមានតម្លៃខ្ពស់ និង លើកទឹកចិត្តឲ្យមានការតភ្ជាប់និងសហការគ្នារវាងផលិតកម្ម និងការប្រើប្រាស់ផលិតផលកសិកម្ម។ ដើម្បីរៀបចំផលិតកម្មដំណាំឡើងវិញ មានការបង្កើត ៧ គណៈកម្មាធិការដឹកនាំការងារសម្រាប់ជួយដល់រដ្ឋមន្ត្រីក្នុងបញ្ហាពាក់ព័ន្ធនឹង ការដាំកាហ្វេឡើងវិញ, ការអភិវឌ្ឍន៍ប្រកបដោយចីរភាព, ការអភិវឌ្ឍផលិតកម្មផ្លែឈើក្នុងតំបន់នៅភាគអាគ្នេយ៍ ការអភិវឌ្ឍដំណាំតែប្រកបដោយចីរភាព ការរៀបចំដំណាំស្រូវឡើងវិញក្នុងតំបន់ដីសណ្តទន្លេមេគង្គ របៀបអនុវត្តកសិកម្មល្អនៅវៀតណាម (VietGAP) និងការរៀបចំដំណាំស្រូវឡើងវិញ។ ជាលទ្ធផល កសិករនៅខេត្ត Cuu Long ក្នុងតំបន់ដីសណ្តទន្លេមេគង្គ បានកែប្រែដីស្រែ ៨៧.៣១០ ហិកតា ទៅដាំដំណាំផ្សេងៗវិញ។ រីឯកសិករនៅភាគខាងជើងបានសម្រេចចិត្តដាំដំណាំបន្ទាប់បន្សំ ជំនួសស្រូវវិញ នៅលើដី ១០.០០០ ហិកតា។ ការផ្លាស់ប្តូរនេះបានធ្វើឲ្យកសិករមានប្រាក់ចំណូលនិងជីវភាពកាន់តែប្រសើរឡើង។

សម្ភាសន៍ជាមួយអ្នកកសាងគោលនយោបាយវៀតណាមនានា បានបង្ហាញដូចៗគ្នាពី បំណងមុតមាំរបស់រដ្ឋាភិបាលដើម្បីធ្វើការផ្លាស់ប្តូរពីដំណាំស្រូវមានតម្លៃទាប ទៅដាំស្រូវមានតម្លៃខ្ពស់ ឬ ដំណាំមានតម្លៃខ្ពស់ផ្សេងទៀត។ ពួកគេយល់ថា ការដាំតែស្រូវមានទិន្នផលខ្ពស់ប៉ុន្តែមានតម្លៃទាប មិនអាចជួយលើកស្ទួយជីវភាពកសិករបានទេ ហើយវាបំផ្លាញបរិស្ថានថែមទៀត។ ពួកគេនិយាយថា ទោះបីមានគោលនយោបាយគាំទ្រជាច្រើនក្តី ក៏កសិករនៅតែទទួលបានអត្រាចំណេញតូចបំផុតពីផលិតកម្មស្រូវអង្ករ រីឯឈ្មួញនិងអ្នកនាំចេញនានាអាចរកបានប្រាក់ចំណេញយ៉ាងច្រើន។ ថ្លៃស្រូវនៅកសិដ្ឋានទាបខ្លាំងពេក ធ្វើឲ្យកសិករមិនអាចទទួលបានប្រាក់ចំណេញសមរម្យទេ។ អ្នកកសាងគោលនយោបាយសារភាពថា ទោះបីវៀតណាមមាននាំចេញអង្ករយ៉ាងច្រើនទៅទីផ្សារអន្តរជាតិក្តី ប៉ុន្តែទទួលបានអត្រាចំណេញតូច បើធៀបនឹង ផលិតផលកសិកម្មផ្សេងទៀត។ ពួកគេសង្កេតឃើញថា អ្នកនាំចេញវៀតណាមមានអំណាច

ចរចាតិចណាស់ ក្នុងទីផ្សារអង្ករអន្តរជាតិដែលមានការប្រកួតប្រជែងយ៉ាងខ្លាំងនេះ។ ដំណើរការការនាំចេញអង្ករ ក៏ស្មុគស្មាញ និងមានចំណាយខ្ពស់ដែរ ហើយប្រទេសខ្លះដូចជា ហ្វីលីពីន ជាដើម តម្រូវឲ្យ ក្រុមហ៊ុននាំចេញរបស់បរទេសធ្វើការដេញថ្លៃដើម្បីទទួលបានកូតានាំចូលអង្ករ ដែលធ្វើឲ្យថ្លៃអង្ករធ្លាក់ចុះរហូតដល់ចំណុចស្មើដើមគ្មានចំណេញ។

សរុបមក ក្នុងសម្ភាសន៍ និងការពិភាក្សានានា អ្នកកសាងគោលនយោបាយវៀតណាម និងអ្នកស្រាវជ្រាវពីគោលនយោបាយស្រូវ តែងស្របមតិគ្នារហូតថា ដោយសារមានការខូចរេចរឹលបរិស្ថានធ្ងន់ធ្ងរ និងសម្ពាធទីផ្សារថ្មីៗ វៀតណាមគួរងាកចេញពីផលិតកម្មបែបប្រពលវប្បកម្មនៃស្រូវមានតម្លៃទាប ហើយធ្វើពិពិធកម្មទៅផលិតស្រូវមានតម្លៃខ្ពស់ឬដំណាំមានតម្លៃខ្ពស់ឬផលិតផលកសិកម្មផ្សេងទៀត។ប៉ុន្តែទាំងអស់គ្នាបានបញ្ជាក់នូវក្តីបារម្ភពីដំណើរការផ្លាស់ប្តូរចំណុចផ្តោតនេះដែលអាចត្រូវការពេលច្រើនឆ្នាំ ទើបអាចបំផុសការយល់ដឹងបានគ្រប់គ្រាន់ក្នុងចំណោមកសិករ។ ការដាក់អនុវត្តគោលនយោបាយនានាក៏ត្រូវការធនធានច្រើនដែរ។ Tran and Nguyen (2015) បានគូសបញ្ជាក់ពី កំហិតមួយលើគោលនយោបាយរៀបចំដំណាំឡើងវិញ ពោលគឺ កសិករមានការយល់ដឹងមិនបានស្មើគ្នាពីគោលនយោបាយ។ មូលនិធិសម្រាប់គាំទ្រការអនុវត្តគោលនយោបាយក៏មិនមានគ្រប់គ្រាន់ដែរ ជាពិសេសសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធស្រោចស្រព។ ម្យ៉ាងទៀត ទីផ្សារសម្រាប់ការផ្លាស់ប្តូរដំណាំ វាមិនទាន់មានស្ថិរភាពទេ និងមិនអាចស្រូបយកផលិតកម្មខ្នាតធំបានឡើយ។ បណ្ឌិត Dang Kimsun ជាអ្នកផ្តល់ព័ត៌មានគន្លឹះបានកត់សំគាល់ស្រដៀងគ្នាថា ពេលខ្លះគេពិបាកនឹងផ្លាស់ប្តូរគំនិត និងអត្តចរិតរបស់ប្រជាជន (កសិករ) ជាពិសេសបើសិនគាត់ធ្លាប់ធ្វើអ្វីមួយជាយូរឆ្នាំ ហើយមានទីផ្សារ និងបណ្តាញជាស្រេច។ ដូច្នេះ ការផ្លាស់ប្តូរខ្សែសង្វាក់តម្លៃស្រូវទាំងមូល ដើម្បីអាចផ្លាស់ប្តូរផលិតកម្ម និងទីផ្សារក្នុងពេលជាមួយគ្នា ត្រូវប្រើពេលវេលា និងធនធានច្រើន។

# ឧបសម្ព័ន្ធ៣
# គោលនយោបាយស្រូវថ្មីនៅកម្ពុជា

គោលនយោបាយស្រូវថ្មី បានតាក់តែងឡើងក្នុងឆ្នាំ២០១៦ និងគ្រោងអនុម័តចេញក្នុងឆ្នាំ២០១៧។ ឯកសារនេះផ្អែកលើគោលការណ៍សំខាន់ៗនៃការចូលរួម តម្លាភាព ការប្រកួតប្រជែង និងចីរភាព។ គោលនយោបាយថ្មីនេះគ្របដណ្តប់លើទិដ្ឋភាពជាច្រើន ដូចជា ការកែលំអផលិតកម្មតាមរយៈ នវានុវត្តន៍ ការវិភាគច្រើនៗពីចំណាយនិងផលចំណេញនៃគម្រោងវិនិយោគ ការយល់ដឹងកាន់តែប្រសើរពីតម្រូវការនិងការប្រកួតប្រជែង ការសម្របសម្រួលកាន់តែរឹងប៉ឹងក្នុងចំណោមអ្នកពាក់ព័ន្ធ ការកសាងរូបភាពធំសរុបគ្នា ការផ្តល់ចក្ខុវិស័យច្បាស់ ដើម្បីឲ្យវិស័យស្រូវអាចឈានទៅមុខជាវិជ្ជមាន។

- **បង្កើតវេទិកាមួយសម្រាប់ការចែករំលែកព័ត៌មាន និងការពិនិត្យតាមដានការអនុវត្តគោលនយោបាយ៖** ព័ត៌មានអំពីវិស័យស្រូវមានលក្ខណៈ ដាច់ដោយដុំ មិនពេញលេញ ជារឿយៗមិនអាចទុកចិត្តបាន មិនមានការផ្សព្វផ្សាយទូលំទូលាយ មានការវិភាគម្តងម្កាល និង កម្រមានការពិភាក្សាល្អិតល្អន់។ លក្ខណៈនេះបានកាត់បន្ថយឱកាសធ្វើការសម្រេចចិត្តផ្នែកគោលនយោបាយដោយផ្អែកលើភស្តុតាង និងនាំឲ្យមានប្រតិកម្មខ្លាំងហួសតបនឹងព័ត៌មានផ្សេងៗដែលជួនកាលមានការផ្ទៀងផ្ទាត់អន់ណាស់ផង។ គោលនយោបាយស្រូវថ្មីត្រូវមានការបង្កើតវេទិកាផ្លូវការមួយសម្រាប់ការចូលរួម ដើម្បីចែករំលែកព័ត៌មាន និងពិនិត្យតាមដានការអនុវត្តគោលនយោបាយ។ វេទិកានោះហៅថា វេទិកាគោលនយោបាយស្រូវ (RPP) ដែលមានការចូលរួមពីតំណាងរបស់រដ្ឋាភិបាល (ក្រសួងហិរញ្ញវត្ថុ ក្រសួងកសិកម្ម និង ក្រសួងពាណិជ្ជកម្ម) វិស័យឯកជន និងកសិករ។ វេទិកាគោលនយោបាយស្រូវ នឹងជួយជំរុញកិច្ចសន្ទនារវាងអ្នកពាក់ព័ន្ធនានា លើបញ្ហាទាក់ទងនឹងការអនុវត្តគោលនយោបាយស្រូវ។ គោលបំណងជារួម គឺការបង្កើតវប្បធម៌សន្ទនា និងការចែករំលែកព័ត៌មាន ជាជាងការប្រឈមមុខគ្នា។

- **កសាងចក្ខុវិស័យរួមគ្នាមួយផ្អែកលើ អង្ករក្រអូបគុណភាពខ្ពស់និងតម្លៃខ្ពស់៖** កម្ពុជាត្រូវមានចក្ខុវិស័យច្បាស់លាស់មួយសម្រាប់វិស័យស្រូវអង្ករ។ ក្រៅពីលក្ខណៈជាប្រភពចម្បងនៃសន្តិសុខស្បៀងសម្រាប់ប្រទេសជាតិ អង្ករនៅកម្ពុជាក៏អាចដើរតួសំខាន់ក្នុងការនាំចេញ និងការអភិវឌ្ឍជនបទដែរ។ ចក្ខុវិស័យនេះសំដៅជំរុញកម្ពុជាឲ្យក្លាយជាអ្នកនាំចេញអង្ករក្រអូបនាំមុខគេមួយ។ ចក្ខុវិស័យនេះមិនប្រទាំងប្រទេសគ្នាជាមួយ មុខងារសន្តិសុខស្បៀងនៃវិស័យស្រូវអង្ករទេ។ គោលនយោបាយថ្មីនេះមានវិសាលភាពចង្អៀតជាង គោលនយោបាយកំណត់ឡើងនៅឆ្នាំ២០១០។

- **ប្រមូលព័ត៌មានទីផ្សារលើអតិថិជន និងអ្នកប្រកួតប្រជែង៖** ជារឿយៗណាស់គេគិតថា កម្ពុជាមានសមត្ថភាពប្រកួតប្រជែងខ្សោយ។ គំនិតនេះផុសឡើងជាសំខាន់ដោយសារកម្ពុជាមាន ផលិតភាពទាបនៅកម្រិតកសិដ្ឋាន ការគ្រប់គ្រងអន់ខ្សោយលើខ្សែសង្វាក់ផ្គត់ផ្គង់ នវានុវត្តន៍នៅខ្សត់ ឡូជីស្ទិកខ្សោយ កង្វះសកម្មភាពលើកស្ទួយឈ្មោះពាណិជ្ជកម្ម ឧបសគ្គរាំងស្ទះក្នុងប្រព័ន្ធក្រោយការប្រមូលផល និងតម្លៃថាមពលខ្ពស់។ កត្តាទាំងនេះ នាំឲ្យកម្ពុជាទទួលបានចំណែកទីផ្សារតូចណាស់សម្រាប់អង្ករនាំចេញទៅអន្តរជាតិ។ ក្នុងការប្រកួតប្រជែងត្រូវមាន ចំណេះដឹងមាំទាំពីចំណង់ចំណូលចិត្តរបស់អតិថិជន។ គោលនយោបាយថ្មីនេះតម្រូវឲ្យមានការបង្កើត អង្គភាពប្រមូលព័ត៌មានទីផ្សារស្រូវអង្ករនៅក្នុង សហព័ន្ធស្រូវអង្ករកម្ពុជា (CRF)។ អង្គភាពនេះត្រូវប្រមូល វិភាគ ចងក្រងឯកសារព័ត៌មានលើទីផ្សារ និងអ្នកប្រកួតប្រជែង សម្រាប់ចែកចាយទៅឲ្យអ្នកពាក់ព័ន្ធនានា។

- **បង្កើនផលិតភាពតាមរយៈប្រព័ន្ធនវានុវត្តន៍ផ្សេងៗដែលទទួលបានមូលនិធិគ្រប់គ្រាន់៖** កម្ពុជាត្រូវពង្រឹងប្រព័ន្ធស្រាវជ្រាវ ផ្សព្វផ្សាយ និងអប់រំ ដើម្បីលើកកម្ពស់នវានុវត្តន៍នៅគ្រប់ដំណាក់កាលនៃខ្សែសង្វាក់តម្លៃ។ វិស័យនេះត្រូវមានគួបផ្សំជាមួយគ្នានូវ ការពង្រីកដី ការបង្កើនទិន្នផល និង កំណើនកត្តាសរុបនៃផលិតភាព ដែលនាំឲ្យមានកំណើន

ប្រាក់ចំណូលសម្រាប់កសិករ និងតួអង្គផ្សេងទៀតក្នុងខ្សែសង្វាក់តម្លៃ។ ទាំងអស់នេះ ត្រូវមានកិច្ចប្រែងប្រែងមោះមុតប្រកបដោយនវានុវត្តន៍នៃវិស័យសាធារណៈ និងឯកជន តាមរយៈរបៀបអនុវត្តន៍មានប្រសិទ្ធភាពខ្ពស់នៅគ្រប់កម្រិត។ ដូច្នេះរដ្ឋាភិបាលត្រូវទទួលស្គាល់ និងផ្តល់រង្វាន់ដល់តួអង្គប្រកបដោយនវានុវត្តន៍ក្នុងវិស័យឯកជន ដែលអាចចូលរួមលើកស្ទួយលទ្ធផលជាទូទៅក្នុងវិស័យនេះ។

- **លើកកម្ពស់ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់នៃឧស្សាហកម្មកិនស្រូវ៖** តួអង្គសំខាន់ៗក្នុងខ្សែសង្វាក់ផ្គត់ផ្គង់ រួមមានរោងម៉ាស៊ីនកិនស្រូវកសិករនិងឈ្មួញ។រោងម៉ាស៊ីនកិនស្រូវជាទូទៅនៅកម្ពុជាប្រើវិធីបែបបុរាណក្នុងការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់។ពួកគេទទួលស្រូវពីអ្នកប្រមូលទិញ ឈ្មួញតូចតាច ឈ្មួញធំៗ និងរោងម៉ាស៊ីនកិនស្រូវតូចៗដែលមិនអាចធានាគុណភាព កំណត់ពេល និងកម្រិតថ្លៃ ដើម្បីបំពេញតាមការបញ្ជាទិញពីអន្តរជាតិ និងស្តង់ដាគុណភាពទេ។ កសិកម្មតាមកិច្ចសន្យាក្នុងវិស័យស្រូវអង្ករ ស្ទើរតែមិនមានសោះ។ ដើម្បីពង្រឹងខ្សែសង្វាក់ផ្គត់ផ្គង់ គោលនយោបាយមានគោលដៅបង្កើតកម្មវិធីមួយដើម្បី លើកកម្ពស់ការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់របស់រោងម៉ាស៊ីនកិនស្រូវ និងកសិករជួយគាំទ្រការបង្កើតកសិកម្មតាមកិច្ចសន្យាប្រកបដោយជោគជ័យ កម្រិតគោលនៃលទ្ធផលខ្សែសង្វាក់ផ្គត់ផ្គង់ និងការពិនិត្យតាមដានភាពជឿនលឿនការងារ និងការកំណត់លក្ខខណ្ឌផ្ទៃក្នុងតឹងរ៉ឹង នៅក្នុងសហព័ន្ធស្រូវអង្ករកម្ពុជាសម្រាប់អ្នកនាំចេញ និងរោងម៉ាស៊ីនកិនស្រូវដែលចូលរួមក្នុងអាជីវកម្មនាំចេញ ដើម្បីឲ្យមានប្រព័ន្ធផ្អែកលើភស្តុតាង។

- **កែលំអហេដ្ឋារចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃអង្ករ តាមរយៈ វិនិយោគមានប្រសិទ្ធភាពចំណាយ៖** ហេដ្ឋារចនាសម្ព័ន្ធនៃខ្សែសង្វាក់តម្លៃរួមមាន ប្រព័ន្ធស្រោចស្រពនិងរំដោះទឹក ទីផ្សារ ឃ្លាំង ការដឹកជញ្ជូន ( ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក កំពង់ផែ ) ថាមពល និង ប្រព័ន្ធក្រោយការប្រមូលផល។ វិនិយោគជាច្រើនក្នុងពេលកន្លងមក ទាំងរបស់វិស័យសាធារណៈ និងរបស់ឯកជន គេតែងគិតថាជាការខ្ជះខ្ជាយ ឬគ្មានប្រសិទ្ធភាព និងគួរឲ្យសោកស្តាយព្រោះធនធាននៅមានកម្រិតសម្រាប់វិនិយោគបែបនេះ។ គោលនយោបាយស្រូវថ្មី មានរួមបញ្ចូលនូវ វិធានការនានាសម្រាប់ធានាឲ្យមានការវាយតម្លៃត្រឹមត្រូវលើជម្រើសគម្រោងនានាមុនពេលធ្វើវិនិយោគ ការពិនិត្យលំអិតឡើងវិញ និងការធ្វើវិនិយោគតាមក្រោយជាទៀងទាត់លើការថែទាំ និងសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន ក្នុងវិនិយោគនាពេលអនាគត ដើម្បីសម្រេចបាន អត្រាចំណេញធៀបនឹងចំណាយ កម្រិតខ្ពស់បំផុត។

- **កសាងផែនការមេរួមគ្នារលូនគ្នាល្អ និងធានាឲ្យមានមូលនិធិគ្រប់គ្រាន់៖** ត្រូវមានផែនការសកម្មភាពរលូនគ្នាមួយក្នុងចំណោមអ្នកពាក់ព័ន្ធផ្សេងៗ។ផែនការនេះសំខាន់ណាស់សម្រាប់បង្ហាញរូបភាពធំនិងសរុប លប់បំបាត់ការងារលើសនិងតម្រឹមសកម្មភាពអ្នកពាក់ព័ន្ធសំខាន់ៗ។ ឧទាហរណ៍ ផែនការមេក៏អាចមានរួមបញ្ចូលនូវ ការផ្តល់មតិផ្សេងៗ ដោយផ្តោតលើតំបន់ភូមិសាស្ត្រជាក់លាក់មួយចំនួន និងមានគោលដៅច្បាស់លាស់សម្រាប់ការផលិតស្រូវអង្ករមានគុណភាពជាក់លាក់។ ប្រសិនបើមានខេត្តជាក់លាក់ណាមួយ ឬតំបន់រួមគ្នាសម្រាប់ពីរខេត្តឬពីរតំបន់ឡើងទៅ គេរកឃើញថា មានឧត្តមភាពប្រៀបធៀបក្នុងការផលិតស្រូវមានពូជជាក់លាក់ណាមួយនោះ គឺត្រូវមានការលៃចែក ថវិកា សេវា ឡូជីស្ទិក និងធាតុចូលផ្សេងទៀត ទៅឲ្យខេត្តឬតំបន់នោះ ដើម្បីធានាឲ្យបានផលចំណេញខ្ពស់បំផុត។ វិធីនេះធ្វើឲ្យ សកម្មភាពក្រោយការផលិតកាន់តែមានប្រសិទ្ធភាពចំណាយឡើង។

តារាងA5៖ ប្រភពនៃសេវាផ្សព្វផ្សាយ មតិណែនាំ និងជំនួយគាំទ្រ ទទួលបានដោយកសិករ (%)

| ប្រភេទនៃរបៀបអនុវត្ត ព័ត៌មាន ឬជំនួយគាំទ្រ | ប្រភពនៃសេវាផ្សព្វផ្សាយ មតិណែនាំ និងជំនួយគាំទ្រ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | អ្នកជិតខាង | អាជ្ញាធរមូលដ្ឋាន | NGO | មិត្តភក្តិ | ហាងក្នុងស្រុក | ឈ្មួញស្រូវអង្ករ | មន្ទីរកសិកម្មខេត្ត | សិក្សាខ្លួនឯង | ឈ្មួញវៀតណាម | សរុប | n |
| ការគ្រប់គ្រងជំងឺ/សត្វចង្រៃបំផ្លាញស្រូវ | 6.4 | 2.36 | 49.83 | 5.72 | 5.05 | 5.72 | 22.22 | 0 | 2.69 | 100 | 297 |
| ការដាំជាជួរ | 8.81 | 1.26 | 55.97 | 2.52 | 0 | 0 | 31.45 | 0 | 0 | 100 | 159 |
| ការកែលំអពូជស្រូវ | 15.98 | 2.37 | 41.42 | 5.92 | 0 | 10.06 | 23.08 | 0 | 1.18 | 100 | 169 |
| ការជ្រើសរើសពូជស្រូវ | 21.29 | 1.61 | 42.97 | 3.61 | 0.4 | 6.83 | 21.29 | 0.4 | 1.61 | 100 | 249 |
| ការដាក់ជីគីមី | 6.02 | 0.67 | 55.52 | 4.68 | 3.68 | 7.69 | 18.39 | 0 | 3.34 | 100 | 299 |
| ការធ្វើជីកំប៉ុស/គ្រប់គ្រងសំណល់សរីរាង្គ | 2.84 | 1.7 | 60.8 | 7.95 | 0 | 0.57 | 26.14 | 0 | 0 | 100 | 176 |
| ការគ្រប់គ្រងប្រព័ន្ធស្រោចស្រព | 7.14 | 4.76 | 54.76 | 4.76 | 0 | 1.19 | 27.38 | 0 | 0 | 100 | 84 |
| ការគ្រប់គ្រងទឹកសម្រាប់ស្រូវ | 15.83 | 5.76 | 43.17 | 5.76 | 0 | 1.44 | 25.9 | 0 | 2.16 | 100 | 139 |
| ការសម្ងួតក្រោយពេលប្រមូលផល | 28.57 | 0 | 42.86 | 4.76 | 0 | 3.57 | 20.24 | 0 | 0 | 100 | 84 |
| កន្លែងស្តុក | 16.9 | 1.41 | 46.48 | 11.27 | 0 | 0 | 23.94 | 0 | 0 | 100 | 71 |
| ការគ្រប់គ្រងសត្វចង្រៃក្រោយពេលប្រមូលផល | 22.78 | 2.53 | 44.3 | 10.13 | 0 | 1.27 | 18.99 | 0 | 0 | 100 | 79 |
| មតិណែនាំពីថ្លៃផលស្រូវ | 31.34 | 0.75 | 18.66 | 8.21 | 1.49 | 32.09 | 2.99 | 0 | 4.48 | 100 | 134 |
| មតិណែនាំពីថ្លៃធាតុចូល | 27.43 | 0 | 31.86 | 8.85 | 1.77 | 21.24 | 2.65 | 0 | 6.19 | 100 | 113 |
| ការផ្សព្វផ្សាយទីផ្សាររួមគ្នា/លក់ជាក្រុម | 30 | 10 | 50 | 10 | 0 | 0 | 0 | 0 | 0 | 100 | 10 |
| ព័ត៌មានលើកន្លែងលក់ចេញ | 62.16 | 0 | 13.51 | 10.81 | 0 | 8.11 | 2.7 | 0 | 2.7 | 100 | 37 |
| ឥណទានពីធនាគារក្នុងស្រុកមីក្រូហិរញ្ញវត្ថុឬក្រុមសន្សំ | 2.38 | 0.48 | 96.2 | 0.48 | 0 | 0 | 0 | 0 | 0.48 | 100 | 421 |
| សរុប | 12.97 | 1.63 | 54.46 | 5.08 | 1.23 | 6.03 | 16.86 | 0.04 | 1.71 | 100 | 2,521 |

ប្រភព៖ អង្កេតគ្រួសារបែបបរិមាណវិស័យសម្រាប់ការសិក្សានេះ

## បញ្ជីឯកសារពិភាក្សារបស់វិទ្យាស្ថាន CDRI


១១២. *រ័ត្ន វឌ្ឍនា Abdelkrim Araarz, ស្រ៊ី ប៊ុប្ផារ័ត្ន និង ផាន់ដាលីស* (មីនា ២០១៧). *The Dynamics of Microcredit Borrowings in Cambodia.* ជាភាសាអង់គ្លេស *Published online by PEP at www.pep-net.org/dynamics-microcredit-borrowings-cambodia-march-2017*

១១១. *អៀ សុធី ស៊ឹម សុខចេង និងខៀវ ភារម្យ* (មីនា ២០១៦). *Cambodia Macroeconomic Impacts of Public Consumption on Education – A Computable General Equilibrium Approach.* ជាភាសាអង់គ្លេស *Published online by PEP at www.pep-net.org/sites/pep-net.org/files/typo3doc/pdf/files_events/2016_Manila_conference/final_report/MPIA-12804-Conference_Version.pdf*

១១០. *វង់ ម៉ាន់* (ធ្នូ ២០១៦). *Progress and Challenges of Deconcentration in Cambodia: The Case of Urban Solid Waste Management.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០៩. *សំ ស្រីមុំ គី ចាន់និមល Keum Kyungwoo, សារុំ ម៉ូលីដែត និង សុខ រក្សា* (ធ្នូ ២០១៦). *Common Pool Resources and Climate Change Adaptation: Community-based Natural Resource Management in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៨. *លី តឹម* (មករា ២០១៦). *Leadership Pathways for Local Women: Case Studies of Three Communes in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៧. *ឈឹម ឈន់ ប៊ុត ប៉ូរ៉ា និង អៀ សុធី* (កញ្ញា ២០១៥). *Effect of Labour Movement on Agricultural Mechanisation in Cambodia.* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

១០៦. *ឈឹម ឈន់ តុង គឹមស៊ុន, Ge Yu, Timothy Ensor and Barbara McPake* (កញ្ញា ២០១៥). *Impact of Health Financing Policies on Household Spending: Evidence from Cambodia Socio-Economic Surveys 2004 and 2009.* ជាភាសាអង់គ្លេស មាននៅក្នុងគេហទំព័រ https://cdri.org.kh។

១០៥. *រ័ត្ន វឌ្ឍនា និង លន់ពិដ* (សីហា ២០១៥). *សុខាភិបាល និងការអប់រំ នៅប្រទេសកម្ពុជា៖ គោលនយោបាយ ស្ថាប័ន និងការអនុវត្ត (Health and Education in Cambodia: Policies, Institutions and Practices)* ជាភាសាអង់គ្លេស មាននៅក្នុងគេហទំព័រ https://cdri.org.kh។

១០៤. *ស៊ុំ ស្រីមុំ និង ខៀវ ភារម្យ (សីហា ២០១៥). Contract Farming in Cambodia: Different Models, Policy and Practice.* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០៣. *ឈឹម ឈន់ តុង គឹមស៊ុន, Ge Yu, Timothy Ensor and Barbara McPake (មិថុនា ២០១៥). Catastrophic Payments and Poverty in Cambodia: Evidence from Cambodia Socio-Economic Surveys 2004, 2007, 2009, 2010 and 2011.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០២. *អេង នេត្រា វង់ ម៉ាន់ និង ហ៊ិត ណារី (មិថុនា ២០១៥). Social Accountability in Service Delivery in Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១០១. *អ៊ូ ស៊ីវហួច (មេសា ២០១៥). A Rights-Based Approach to Development: A Cambodian Perspective.* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

១០០. សំ ស្រីមុំ ជាមួយ អ៊ុច ឈួង *(មីនា ២០១៥).* ការអនុវត្ត និងចន្លោះខ្វះខាតផ្នែកបច្ចេកវិទ្យាកសិកម្ម ក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ *(Agricultural Technological Practices and Gaps for Climate Change Adaptation)* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៩៩. ផៃ សុខចេង និង តុង គឹមស៊ុន (ធ្នូ ២០១៤) *Public Spending on Education, Health and Infrastucture and Its Inclusiveness in Cambodia: Benefit Incidence Analysis* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៩៨. Srinivasa MADHUR (ធ្នូ ២០១៥) *Cambodia's Skill Gap: An Anatomy of Issue and Policy Options* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ ភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៩៧. គឹម សួ, ចែម ផល្លា, សូ សុវណ្ណារិទ្ធ, គឹម ស៊ាន ស៊ូម៉ាត្រា, ប៊ុច សុខេម (សីហា ២០១៤) *Methods and Tools Applied for Climate Change Vulnerability and Adaptation Assessment in Cambodia's Tonle Sap Basin* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៩៦. គឹម ស៊ាន ស៊ូម៉ាត្រា និង ហួត ណាវី (សីហា ២០១៤), *Cambodian State: Developmental, Neoliberal? A Case Study of the Rubber Sector* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩៥. ថេង វុទ្ធី, កែវ សុជាតិ, នូ កែវសុទ្ធា, ស៊ុំ ស្រីមុំ និង ខៀវ ភិរម្យ (សីហា ២០១៤), *Impact of Farmer Organisations on Food Security: The Case of Rural Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៩៣. ហេង សីហា, វង់ ម៉ាន់, និង ឈាត ស្រ៊ាង ដោយមានជំនួយពី ឈួន ណារ៉េត (កក្កដា ២០១៤), *The Enduring Gap: Decentralisation Reform and Youth Participation in Local Rural Governance* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៩៣. ណាំង ភិរុណ, សំ ស្រីមុំ, លន់ ពេជ្រតារា (មិថុនា ២០១៤), *Adaptation Capacity of Rural People in the Main Agro-Ecological Zones in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩២. ផាន់ ដាលីស (មិថុនា២០១៤) *Links between Employment and Poverty in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩១. ថេង វុទ្ធី, ខៀវ ភិរម្យ និង ផុន ដារី (មេសា ២០១៤), *Development of the Fertiliser Industry in Cambodia: Structure of the Market, Challenges in the Demand and Supply Sidesand the Way Forward* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៩០. ការបោះពុម្ពផ្សាយរបស់ CDRI (មករា ២០១៤), *ASEAN 2030: Growing Together for Economic Prosperity–the Challenges (Cambodia Background Paper)* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៨៩. ណាំង ភិរុណ និង អ៊ួច ឈួង (មករា ២០១៤), *Gender and Water Governance: Women's Role in Irrigation Management and Development in the Context of Climate Change* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៨. ឈាត ស្រ៊ាង (ធ្នូ ២០១៣), *Impact of Decentralisation on Cambodia's Urban Governance* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៧. គឹម សេតារា និង Joakim Öjendal ដោយមានជំនួយពី ឈួន ណារ៉េត (វិច្ឆិកា 2013), *Gatekeepers in Local Politics: Political Parties in Cambodia and their Gender Policy* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៨៦. សែន វិចិត្រ, រស់ សុវាចា និង ហៀង ធីរ៉ាភមរី (តុលា ២០១៣), *Anatomy of Higher Education Governance in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៥. អ៊ូ ស៊ីវហួច និង គឹម សេតារា (សីហា ២០១៣), *20 Years' Strengthening of Cambodian Civil Society: Time for Reflection* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៤. អ៊ូ ស៊ីវហួច (សីហា ២០១៣), *Sub-National Civil Society in Cambodia: A Gramscian Perspective* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨៣. តុង គឹមស៊ុន, លន់ ពិដេ និង ស្រ៊ី បុប្ផារ័ត្ន ដោយមានជំនួយពី ប៉ុន ដូរីណា (សីហា ២០១៣) *Levels and Sources of Household Income in Rural Cambodia 2012* មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។

៨២. ណាំង ភិរុណ (កក្កដា ២០១៣), *Climate Change Adaptation and Livelihoods in Inclusive Growth: A Review of Climate Change Impacts and Adaptive Capacity in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៨១. ហ៊ីង វុត្ថា (មិថុនា), *Leveraging Trade for Economic Growth in Cambodia* ជាភាសាអង់គ្លេស តម្លៃ ១,៥០ ដុល្លារ។

៨០. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Binding Constraints on Economic Growth in Cambodia: A Growth Diagnostic Approach* មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។

៧៩. លន់ ពិដេរ (មីនា ២០១៣), *The Role of Rural Credit during the Global Financial Crisis: Evidence From Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៨. តុង គឹមស៊ុន និង ផៃ សុខចេង (មីនា ២០១៣), *The Role of Income Diversification during the Global Financial Crisis: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៧. សាំង ច័ន្ទហង្ស (មីនា ២០១៣), *Household Vulnerability to Global Financial Crisis and Their Risk Coping Strategies: Evidence from Nine Rural Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៦. ហ៊ីង វុត្ថា (មីនា ២០១៣), *Impact of the Global Financial Crisis on the Rural Labour Market: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៥. តុង គឹមស៊ុន (មីនា ២០១៣), *Impact of the Global Financial Crisis on Poverty: Evidence from Nine Villages in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៤. Ngin Chanrith (March 2013), *Impact of the Global Financial Crisis on Employment in SMEs in Cambodia មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧៣. Hay Sovuthea (April 2013), *Government Response to Inflation Crisis and Global Financial Crisis មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧២. ហែម សុចិត្ត (មេសា ២០១៣), *Impact of the Global Financial Crisis on Cambodian Economy at Macro and Sectoral Levels មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។*

៧១. គីម សេតារ៉ា, Joakim Öjendal, ឈួន ណារ៉េត និង លី តឹម (ធ្នូ ២០១៣) *ការវិភាគខាងយេនឌ័រលើកំណែទម្រង់វិមជ្ឈការនៅកម្ពុជា* ជាភាសាខ្មែរ តម្លៃ ៨.០០០ រៀល អង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៧០. ហ៊ីង វុត្ថា, សាំង ច័ន្ទហង្ស និង យៀង សុធី (សីហា ២០១២), *Baseline Survey for Socioeconomic Impact Assessment: Greater Mekong Sub-region Transmission Project* មានក្នុងគេហទំព័រវិទ្យាស្ថាន CDRI។

៦៩. *ការបោះពុម្ពរបស់ CDRI (មីនា ២០១២), Understanding Poverty Dynamics: Evidence from Nine Villages in Cambodia ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។*

៦៨. វ័ន្ធ វឌ្ឍនា *(មីនា ២០១២), Sectoral Composition of China's Economic Growth, Poverty Reduction and Inequality: Development and Policy Implications for Cambodia ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។*

៦៧. Keith Carpenter ដោយមានជំនួយពី ប៉ុន ដូរីណា (*កុម្ភៈ ២០១២*), *A Basic Consumer Price Index for Cambodia 1993–2009 ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៦៦. តុង គឹមស៊ុន (*កុម្ភៈ ២០១២*), *Analysing Chronic Poverty in Rural Cambodia Evidence from Panel Data ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។*

៦៥. រស់ បានសុខ, ណាំង ភិរុណ និង ឈឹម ឈុន (តុលា ២០១៣), *Agricultural Development and Climate Change: The Case of Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ ដុល្លារ។*

៦៤. តុង គឹមស៊ុន និងស្រ៊ី បុប្ផារត្ន (វិច្ឆិកា ២០១១), *Poverty and Evironment Links: The Case of Rural Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៦៣. ហេង សីហា, គឹម សេតារ៉ា និងសូ សុខប៊ុនធឿន(តុលា ២០១១), *Decentralised Governance in Hybrid Polity: Localisation of Decentralisation Reform in Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៦២. ជា ជូ, ណាំង ភិរុណ, Isabelle Whitehead, Phillip Hirsch និង Anna Thompson (តុលា ២០១១), *Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៦១. *រស់ បណ្ឌេត, លី តឹម និង Anna Thompson (កញ្ញា ២០១១), Catchment Governance and Cooperation Dilemmas: A Case Study from Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៦០. *ការបោះពុម្ពរបស់ CDRI (តុលា ២០១១), Poverty Dynamics Study: Evidence from Nine Villages in Cambodia ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។*

៥៩. *ចែម ផល្លា, Philip Hirsch និង សុមេធ ប៉ាវ៉ាឌី (កញ្ញា ២០១១), Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៨. ហ៊ីង វុត្ថា លន់ ពិដេ និង ផាន់ ដាលីស (តុលា ២០១១) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា៖ លក្ខណៈសម្គាល់ បញ្ហាប្រឈម និងការរៀបចំច្បាប់គ្រប់គ្រង* ជាភាសាខ្មែរ តម្លៃ ១០.០០០ រៀល អង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៧. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *The Impact of Irrigation on Household Assets* ជាភាសាអង់គ្លេស តម្លៃ ២,០០ដុល្លារ។

៥៦. តុង គឹមស៊ុន ហែម សុចិត្ត និង Paulo Santos (កក្កដា ២០១១), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥៥. កឹម សុធន ឈឹម ឈន់ ថេង វុទ្ធី និង សូ សុវណ្ណារិទ្ធ (កក្កដា ២០១១), *Policy Coherence in Agricultural and Rural Development: Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៥៤. ណាំង ភិរុណ ខៀវ ដាវ៉ារី, Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១), *លើកកម្ពស់អភិបាលកិច្ច ធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ភាសាខ្មែរ ១២.០០០រៀល។

៥៣. Chann Sopheak, Nathan Wales and Tim Frewer (August 2011), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia* ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៥២. អ៊ូច ច័ន្ទតាវ៉ានី សាំង ច័ន្ទហង្ស និង ផាន់ ដាលីស (សីហា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា* ជាភាសាអង់គ្លេស តម្លៃ ៣,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល។

៥១. Christopher Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths (មិថុនា ២០១១), *Irrigation Water Productivity in Cambodian Rice System* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៥០. ប៉ក់ គឹមជឿន (ឧសភា ២០១១), *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់* ជាភាសាអង់គ្លេសតម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៤៩. ចែម ផល្លា និង សុមេធ ប៉ាវ៉ាឌី (ឧសភា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

៤៨. ការបោះពុម្ពរបស់CDRI (សីហា 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៧. ជា ជូ (សីហា 2010), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia* ជាភាសាអង់គ្លេស តម្លៃ ២,៥០ដុល្លារ។

៤៦. ការបោះពុម្ពរបស់ CDRI (ធ្នូ 2009), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៥. ការបោះពុម្ពរបស់ CDRI (ធ្នូ 2009), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam* ជាភាសាអង់គ្លេស តម្លៃ ១,៥០ដុល្លារ។

៤៤. ច័ន្ទ សុផល (ធ្នូ ២០០៩) *ផលប្រយោជន៍ និងចំណាយនៃទេសន្តរប្រវេសន៍កម្លាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៤៣. ហ៊ីង វុត្ថា និង បណ្ឌិត ធន់ វឌ្ឍនា (ធ្នូ ២០០៩) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤២. ធន់ វិមាលា អ៊ូ ស៊ីវហួច អេង នេត្រា និង លី តឹម (តុលា 2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces* ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤១. ហ៊ីង វុត្ថា និង Hossein Jalilian (មេសា ២០០៩) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាននៅតាមបណ្តាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ៣,០០ដុល្លារ។

៤០. អេង នេត្រា និង David Craig (មីនា ២០០៩), *Accountability and Human Resource Management in Decentralised Cambodia* (Working Paper No. 40) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៩. ហ៊ែង វុទ្ធី និង David Craig, *Accountability and Planning in Decentralised Cambodia* (Working Paper No. 39) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៨. ប៉ក់ គឹមជឿន និង David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* (Working Paper No. 38) ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៧. ចែម ផល្លា និងអ្នកផ្សេងទៀត (ឧសភា 2008), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review* ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *ចំណាកស្រុករបស់យុវជន និងនគរូបនីយកម្ម នៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣៦) ជាភាសាខ្មែរ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,៥0ដុល្លារ។

៣៥. គឹម-សេតារ៉ា និង Joakim Öjendal (ឧសភា ២០០៧) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* (ឯកសារពិភាក្សាលេខ៣៥) ជាភាសាអង់គ្លេស តម្លៃ ៤,00ដុល្លារ។

៣៤. ប៉ក់-គឹមជឿន ហ៊ែង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារ៉ា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាភាសាអង់គ្លេស ៦,00ដុល្លារ។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33) ជាភាសាអង់គ្លេស តម្លៃ ៨.០០ដុល្លារ។

៣២. K. A. S. Murshid និង ទួត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣១) ជាភាសាខ្មែរ តម្លៃ ៥.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,៥0ដុល្លារ។

៣០. Caroline Hughes និង គឹម-សេតារ៉ា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរតម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១៣,៥0ដុល្លារ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាយីទីងត្រីពីបឹងទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសម្រាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសម្រាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្ដីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅ ជនបទ៖ ការសិក្សាលើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ១០.០០ដុល្លារ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិនិងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតម្លៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសា ខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស តម្លៃ ១០.០០ដុល្លារ។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល។

២១. Bhargavi Ramamurthy ស៊ិក-បូរ័ក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្ដោតលើបញ្ហាដីធ្លី កម្លាំងពលកម្ម និងការចិញ្ចឹមជីវិត នៅជនបទ* (ឯកសារពិភាក្សាលេខ ២១) តម្លៃ ៨.០០០រៀល។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ិច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតម្លៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៩. ច័ន្ទ-សុផល ទេព-សារ៉ាវី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សារ៉ាវី ប៉ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតម្រូវចំពោះវិបត្តិ* (ឯកសារពិភាក្សា លេខ១៨) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៧,០០ដុល្លារ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៉ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៨,០០ដុល្លារ។

១៦. ស៊ិក បូរ័ក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្តុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យ វិភាគដោយគ្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,០០ដុល្លារ។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកម្ពស់អភិបាលកិច្ចសម្រាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សា លេខ ១៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេសអាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៤,៥០ដុល្លារ។

១១. ច័ន្ទ-សុផល និង សូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការអភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកឃិនRDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ ៤.៥០០រៀល ជាភាសាអង់គ្លេស ៤,៥០ដុល្លារ។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៧. McAndrew,JohnP. (ធ្នូ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុងភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០,០០ដុល្លារ។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍ កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល ជាភាសាអង់គ្លេស តម្លៃ ៩,០០ដុល្លារ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ច តំបន់សម្រាប់ការអភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៦,០០ដុល្លារ។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកឃិនឌ្រូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ិដឹលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារ ពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៧,៥០ដុល្លារ។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២) ជាភាសាខ្មែរ ៤.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

១. Kannan,K.P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សម្រាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលម្អ* (ឯកសារពិភាក្សា លេខ ១) ជាភាសាខ្មែរ តម្លៃ ៤.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ 56 ផ្លូវ 315 ខ័ណ្ឌទួលគោក

✉ ប្រអប់សំបុត្រលេខ 622 ភ្នំពេញ កម្ពុជា

☎ (855-23) 881-384/881-701/881-916/883-603/012 867-278

(855-23) 880-734

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

តម្លៃ ១០.០០០រៀល

9 789996 389115